វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង
*Working Together for Positive Change*

# ករណីអភិវឌ្ឍន៍នៅតំបន់ព្រៃឡង់៖

## តើប្រជាជនទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍនៅទីនោះដែរឬទេ ?







ភ្នំពេញ, កម្ពុជា
ខែធ្នូ ឆ្នាំ២០១៣

# ករណីអភិវឌ្ឍន៍នៅតំបន់ព្រៃឡង់៖

**តើប្រជាជនទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍនៅទីនោះដែរឬទេ?**

កាលបរិច្ឆេទបោះពុម្ពផ្សាយ៖ ខែធ្នូ ឆ្នាំ២០១៣
បោះពុម្ពផ្សាយដោយ៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
កម្មវិធីដីធ្លី និងជីវភាព
ស្រាវជ្រាវដោយ៖ លោក Allan Michaud
សម្របសម្រួលការស្រាវជ្រាវដោយ៖ លោកស្រី សៅ វិច្ឆិកា មន្ត្រីស្រាវជ្រាវ
រចនាអត្ថបទដោយ៖ លោក ភួន យូ មន្ត្រីព័ត៌មាន និងការបោះពុម្ពផ្សាយ

គ្រប់រូបភាពក្នុងរបាយការណ៍នេះត្រូវបានផ្តល់ដោយលោក Allan Michaud

## សេចក្តីបញ្ជាក់៖

ទស្សនៈបង្ហាញក្នុងរបាយកាណ៍នេះសុទ្ធតែជាទស្សនៈរបស់អ្នកនិពន្ធ ហើយមិនបង្ហាញពីទស្សនៈរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាទេ។ នៅពេលខ្លឹមសារនៃរបាយការណ៍នេះត្រូវគេដកស្រង់ ឬផលិតសារជាថ្មី ការទទួលស្គាល់ និងការសុំអនុញ្ញាតសិទ្ធិរបស់អ្នកនិពន្ធ និងអ្នកបោះពុម្ពផ្សាយនឹងត្រូវគេអោយតម្លៃ។

© **វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា, ខែធ្នូ ឆ្នាំ២០១៣**

# សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះប្រជាជនជាច្រើន មកពីសហគមន៍ផ្សេងៗដែលបានចូលរួមនៅក្នុងការអង្កេតនេះ និងសូមអរគុណចំពោះសមាជិកបណ្តាញសហគមន៍ព្រៃឡង់ (PLCN) ដែលបានផ្តល់ការគាំទ្រ និងជំនួយខាងភស្តុភា។ អ្នកនិពន្ធបានទទួលការជួយឧបត្ថម្ភជាច្រើនពីបុគ្គលិកនៃអង្គការជាច្រើន ដូចជាអង្គការការពារធនធានធម្មជាតិ (NRPG) វិទ្យាស្ថានគ្រប់គ្រងកើត-លិច (EWMI) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF)។ ជាពិសេស សូមថ្លែងអំណរគុណចំពោះអង្គការលីកាដូដែលបានផ្តល់ការគាំទ្រ ជាពិសេសតាមរយៈការផ្តល់ផែនទីដីសម្បទានសេដ្ឋកិច្ច និងអរគុណដល់គេហទំព័រអភិវឌ្ឍន៍បើកទូលាយ (www.opendevcam.net) ផងដែរ ដែលផ្តល់ឯកសារផ្លូវការជាប្រភពព័ត៌មានដ៏ល្អ។ ក្រៅពីនេះ អ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះ បណ្ឌិត អ៊ីដា ថេឡាដេ អ្នកស្រាវជ្រាវជាន់ខ្ពស់នៅសកលវិទ្យាល័យកូប៉េនហាក់ ដែលបានផ្តល់គំនិតដ៏មានតម្លៃដល់ការស្រាវជ្រាវ និងសូមអរគុណដល់ក្រុមអ្នកប្រមូលទិន្នន័យ ដែលបានពុះពារចំពោះកាលៈទេសៈដ៏លំបាកៗបំផុតមួយចំនួនគួរឲ្យកោតសរសើរ។

អ្នកនិពន្ធអាចទទួលបានរូបភាពសំខាន់ៗ ដោយសារមានការជួយគាំទ្រពីលោក ឡាស់ ស្មីត ដែលមកពីសកលវិទ្យាល័យកូប៉េនហាក់ អង្គការលីកាដូ និងអង្គការការពារធនធានធម្មជាតិ ដូច្នេះ អ្នកនិពន្ធសូមថ្លែងអណរគុណចំពោះអ្នកជួយគាំទ្រទាំងនេះដែលបានផ្តល់រូបភាពបន្ថែមសម្រាប់ប្រើប្រាស់ក្នុងរបាយការណ៍នេះ។

# មាតិកា


ពាក្យបំព្រួញ......iii
បញ្ជីតារាង បញ្ជីប្រអប់ បញ្ជីផែនទី......v
បញ្ជីរូបភាព......vi
សេចក្តីសង្ខេប......vii

**ជំពូកទី១: សេចក្តីផ្តើម**......១
១. ព្រៃឈើនៅកម្ពុជា......១
២. ការគ្រប់គ្រងដីព្រៃ......៣
២.១ កម្មវិធីព្រៃឈើជាតិ ឆ្នាំ ២០១០-២០២៩......៥
២.២ កម្មវិធីសហគមន៍ព្រៃឈើ......៦
៣. ដីសម្បទានសេដ្ឋកិច្ច......៧
៤. ពលរដ្ឋជនជាតិដើមភាគតិច - សិទ្ធិ និងការកាន់កាប់ដី......១១
៥. លក្ខណៈភូមិសាស្ត្រ និងប្រជាជននៅតំបន់ព្រៃឡង់......១៥
៦. ជីវៈចម្រុះ......១៦
៦.១ ព្រៃឈើ......១៦
៦.២ សត្វព្រៃ......១៩
៧. សេវាកម្មប្រព័ន្ធអេកូឡូស៊ី......២១
៨. សម្រួបកាបូន/រេដបូក......២៣
៩. សំណើកំណត់តំបន់ព្រៃការពាររបស់រដ្ឋបាលព្រៃឈើ......២៥
១០. ការគំរាមកំហែង......២៩
១០.១ ដីសម្បទានសេដ្ឋកិច្ច......២៩
១០.២ អាជ្ញាប័ណ្ណអាជីវកម្មរ៉ែ......៣២
១០.៣ ការកាប់ឈើល្មើសច្បាប់......៣៥
១០.៤ កំណើនជនចំណាកស្រុក/កំណើនចំនួនប្រជាជន......៣៨
១១. ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន/ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម......៣៩
១២. ការអប់រំសហគមន៍......៤១
១៣. បណ្តាញសហគមន៍ព្រៃឡង់......៤២

**ជំពូកទី២: វិធីសាស្ត្រស្រាវជ្រាវ**......៤៨
១. គោលបំណង......៤៨
២. ដែនកំណត់នៃការសិក្សា......៤៨
៣. ការជ្រើសរើសតំបន់គោលដៅ......៤៩
៤. ការជ្រើសរើសសំណាក និងចុះសិក្សានៅមូលដ្ឋាន......៥០

**ជំពូកទី៣:លទ្ធផលស្រាវជ្រាវ**......៥៣
១.ជីវភាព......៥៣
១.១. សាសនា / ក្រុមជនជាតិដើម......៥៣
១.២. អក្ខរភាព......៥៥
១.៣. ការប្រើប្រាស់អនុផលព្រៃឈើ / ជ័រទឹក......៥៦
១.៤. ប្រាក់ចំណូលពីអនុផលព្រៃឈើ / ជ័រទឹក......៥៨
១.៥.ចំនួនដើមច្បោះ......៦០
១.៦. ការផ្តល់សំណងចំពោះអនុផលព្រៃឈើ......៦១
១.៧. កម្មសិទ្ធិដី និងឯកសារផ្លូវការសម្រាប់គ្រួសារ......៦២
១.៨. ការកែប្រែរបរចិញ្ចឹមជីវិត......៦៤
២. ផលប្រយោជន៍ពីការអភិវឌ្ឍ......៦៦
៣. ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន / ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម......៧០
៤. ការបណ្តុះបណ្តាលអំពីច្បាប់នៅកម្ពុជា និងសិទ្ធិមនុស្ស......៧៣
៤.១. ការបណ្តុះបណ្តាលទៅកាន់សហគមន៍......៧៣
៤.២. ការបណ្តុះបណ្តាលទៅកាន់មន្ត្រីមូលដ្ឋាន......៧៤
៤.៣. ការគំរាមកំហែងចំពោះវគ្គបណ្តុះបណ្តាល......៧៦
៥. ផលប៉ះពាល់លើបរិស្ថាន......៧៦
៦. ចំណាត់ការដោយផ្ទាល់......៧៧
៧. ការជឿជាក់លើរដ្ឋាភិបាល......៨០
៨.អាជ្ញាធរមូលដ្ឋាន......៨១
៩. សកម្មភាពរបស់រដ្ឋបាលព្រៃឈើ......៨២
១០.ជនចំណាកស្រុក......៨៣

**អនុសាសន៍សម្រាប់ការអភិវឌ្ឍ និងគ្រប់គ្រងតំបន់ព្រៃឡង់**......៨៦
ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន......៨៦
ពង្រឹងការអនុវត្តច្បាប់......៨៨
ការអប់រំ និងសិទ្ធិនៅក្រោមច្បាប់កម្ពុជា......៨៩
ព្រៃការពារ......៩០
អាជីវកម្មរ៉ែ......៩១
សិទ្ធិចំពោះដីធ្លី......៩២
សម្បទានដីសេដ្ឋកិច្ចទៅអនាគត......៩៣
អនុសាសន៍ផ្សេងទៀត......៩៤

**ឯកសារយោង**......៩៥

# ពាក្យបំព្រួញ

| | |
|---|---|
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CF | សហគមន៍ព្រៃឈើ |
| CCHR | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| CMDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| CTSP | គម្រោងគ្រាប់ពូជឈើកម្ពុជា |
| EHE | ការអប់រំបរិស្ថាន និងសុខភាព |
| EIA | ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| ELC | ដីសម្បទានសេដ្ឋកិច្ច |
| ESIA | ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម |
| EWMI | វិទ្យាស្ថានគ្រប់គ្រងកើត-លិច |
| FA | រដ្ឋបាលព្រៃឈើ |
| FiA | រដ្ឋបាលជលផល |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MoRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| MoE | ក្រសួងបរិស្ថាន |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NFP | កម្មវិធីព្រៃឈើជាតិ |
| NGOF | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា |
| NRPG | អង្គការការពារធនធានធម្មជាតិ |
| NTFP | អនុផលព្រៃឈើ |
| PLCN | បណ្តាញសហគមន៍ព្រៃឡង់ |

| | |
|---|---|
| REDD/REDD+ | កាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ (រ៉េដ) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| VRG | ក្រុមហ៊ុនចំការកៅស៊ូវៀតណាម |
| UN | អង្គការសហប្រជាជាតិ (អ.ស.ប) |

# បញ្ជីតារាង


តារាងទី ១: ការចាត់ចែងរដ្ឋបាលលើសម្បត្តិព្រៃឈើអចិន្ត្រៃយ៍របស់កម្ពុជា...........៥

តារាងទី ២: គោលបំណងនៃកម្មវិធីព្រៃឈើជាតិដែលផលិតដោយរដ្ឋបាលព្រៃឈើ...........៦

តារាងទី ៣: ប្រភេទព្រៃនៅតំបន់ព្រៃឡង់...........១៧

តារាងទី ៤: តំបន់គោលដៅនៃការសិក្សា...........៥០


# បញ្ជីប្រអប់


ប្រអប់ ១: ដកស្រង់ពីអត្ថបទក្នុងខាមបូឌាដេលី ថ្ងៃទី១០-១១ ខែមីនា ឆ្នាំ២០១២.....៩

ប្រអប់ ២: និយមន័យដីសម្បទានសេដ្ឋកិច្ច...........១០

ប្រអប់ ៣: ការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០...........៣៣

ប្រអប់ ៤: សម្រង់អត្ថបទសារព័ត៌មានខាមបូឌាដេលី «ពុះច្រៀកប្រទេសកម្ពុជា» ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១២...........៧១


# បញ្ជីផែនទី


ផែនទី ១: ផែនទីគម្របព្រៃឈើជាតិ ឆ្នាំ ២០០៦ (រដ្ឋបាលព្រៃឈើ)...........២

ផែនទី ២: ផែនទីតំបន់ព្រៃឡង់...........១៥

ផែនទី ៣: ផែនទីបង្ហាញព្រៃស្រោងសំខាន់ៗនៅតំបន់ព្រៃឡង់ និងទីតាំងតំបន់ស្នូល...........១៨

ផែនទី ៤: ផែនទីសម្រង់ចំណុចចាប់ផ្តើមដែលរដ្ឋបាលព្រៃឈើបានលើកស្នើជាតំបន់ព្រៃការពារ នៅក្នុងតំបន់ព្រៃឡង់...........២៨

ផែនទី ៥: ផែនទីដីសម្បទានសេដ្ឋកិច្ច និងអាជ្ញាប័ណ្ណអាជីវកម្មរ៉ែ ដែលគេបានដឹងនៅជុំវិញតំបន់ព្រៃឡង់...........៣១

ផែនទី ៦: ផែនទីនៃទីតាំងសិក្សា...........៥០

ផែនទី ៧: ផែនទីរូបភាពពីផ្កាយរណបអំពីភូមិភាគកណ្តាលនៃប្រទេសកម្ពុជា ដែលបង្ហាញពីកន្លែងទើបរានឆ្ការថ្មីៗ...........៨៦

# បញ្ជីរូបភាព


រូបភាពទី ១: ទីតាំងខ្ទមដោយអាចិកំបាំងនៅភូមិស្រែវាលកាលពីខែសីហា ឆ្នាំ២០១០ មានអាជ្ញាប័ណ្ណសម្រាប់ការរុករករ៉ែក្នុងតំបន់នេះ............................៣៤

រូបភាពទី ២: ដង្គត់ដើមច្បោះនៅជិតផ្លូវក្រុមហ៊ុនសម្បទាននៅសណ្ដាន់............៣៧

រូបភាពទី ៣: ស្ត្រីជនជាតិកួយដឹកត្រីដែលទើបនេសាទបានអ្នកភូមិដឹកជញ្ជូន ដើមឫស្សី...........................................................................................៥៣

រូបភាពទី ៤: អ្នកភូមិកំពុងដឹកជញ្ជូនឫស្សី...........................................................៥៦

រូបភាពទី ៥: ការដងជ័រតាមប្រពៃណី.................................................................៦០

រូបភាពទី ៦: វាលស្រែអចិន្ត្រៃយ៍ដែលកម្រមានជាទូទៅនៅសហគមន៍ខ្លះ...........៦៤

រូបភាពទី ៧: ពលរដ្ឋជនជាតិដើមកំពុងរៀបចំអាហារថ្ងៃត្រង់ដោយប្រើប្រាស់ ធនធានធម្មជាតិដែលមាននៅក្នុងព្រៃ.............................................៦៥

រូបភាពទី ៨: ផ្លូវកសាងថ្មីៗដែលមកនូវការបំផ្លិចបំផ្លាញតំបន់ព្រៃឡង់................៦៧

រូបភាពទី ៩: ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន CRCK នៅស្រុកសណ្ដាន់.......៦៩

រូបភាពទី ១០: ព្រៃឈើដែលជនចំណាកស្រុកបានរានឆ្ការនៅស្រុកថាឡាបរិវ៉ាត់ ខែមេសា ឆ្នាំ២០១១...................................................................៨៤

# សេចក្ដីសង្ខេប

ព្រៃឡង់ត្រូវបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ ដោយសកម្មភាពក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងសកម្មភាពរុករករ៉ែ។ ការកាប់ឈើ និងការទន្ទ្រានព្រៃដោយល្មើសច្បាប់មានពាក់ព័ន្ធជាមួយអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរខេត្តដែលជារឿយៗមានទាហ៊ានការពារពីក្រោយខ្នង និង/ឬមានពាក់ព័ន្ធជាមួយក្រុមហ៊ុនដីសម្បទាន។ ដីសម្បទានសេដ្ឋកិច្ចខ្លះត្រូវបានផ្ដល់ដោយមិនស្របច្បាប់ ដោយមិនគោរពតាមច្បាប់របស់រដ្ឋាភិបាលដែលនៅជាធរមាន និងមិនមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋានឡើយ។ ដូច្នេះ សហគមន៍ទាំងនោះកំពុងបាត់បង់ដីប្រពៃណី និងធនធានដែលពួកគេពឹងអាស្រ័យដើម្បីរស់។

ដូចករណីនៅតំបន់ជនជាតិដើមភាគតិចជាច្រើននៅកម្ពុជា សហគមន៍ព្រៃឡង់ជំទាស់នឹងវត្តមានសម្បទានដីសេដ្ឋកិច្ចនៅលើទឹកដីរបស់ពួកគេ និងមានកង្វល់ជាខ្លាំងអំពីសន្តិសុខរបស់ពួកគេទៅអនាគត។ ប្រជាជនដែលបានចូលរួមក្នុងការសិក្សានេះភាគច្រើនយល់ថា ការបាត់បង់ព្រៃឈើមិនបាននាំមកនូវអ្វីក្រៅពីមហន្តរាយឡើយ។ ពួកគេមិនចង់ផ្លាស់ប្ដូររបរចិញ្ចឹមជីវិតដោយការទៅធ្វើការឲ្យក្រុមហ៊ុនទាំងនោះឡើយ ដោយសារតែទទួលបានប្រាក់កម្រៃទាប ជាការងាររយៈពេលខ្លី ជាការងារបណ្ដោះអាសន្ន និងមានលក្ខខណ្ឌការងារមិនល្អ។ ដូចជាអ្វីដែលបានកើតឡើងនៅតំបន់ផ្សេងទៀតដែរ ក្រៅពីមិនបានផ្ដល់ផលប្រយោជន៍ដល់សហគមន៍ជនបទ ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចត្រូវបានគេមើលឃើញថាបានបង្កអោយសហគមន៍បាត់បង់ដីធ្លី និងធ្លាក់ក្នុងភាពក្រីក្រ [១]។

បើទោះជានៅក្នុងច្បាប់កម្ពុជាផ្ដល់អោយមានការការពារព្រៃឈើនិងផែនការប្រើប្រាស់ដីក៏ដោយ តែចំណុចខ្វះចន្លោះនៅតែមានដែលតែងតែបង្ករអោយមានសកម្មភាពល្មើសច្បាប់ផ្សេងៗ និងកើតមានបញ្ហាជាច្រើនដែលបណ្ដាលមកពី

---

[១] អភិបាលកិច្ចនៅមូលដ្ឋានសម្រាប់ការទទួលបានដីអភិវឌ្ឍន៍ដោយសមធម៌ និងនិរន្តរភាពពីសំណាក់ភ្នាក់ងារមកពីក្រៅមូលដ្ឋាន និងផលវិបាកនៃគណៈកម្មការជនជាតិដើមនៅបណ្ដាខេត្តភាគឦសាននៃប្រទេសកម្ពុជា ម៉ែន ប្រាជ្ញរុទ្ធី ខែមីនា ឆ្នាំ ២០១១។

ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនានា។ ដំណោះស្រាយជាក់ស្តែងមួយត្រូវធ្វើឡើង ដើម្បីបំពេញចន្លោះប្រហោងនៃប្រកាស ស្តីពីការអនុវត្តគោលការណ៍ណែនាំទូទៅ សម្រាប់ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មាត្រា២ ដែលតម្រូវឲ្យក្រុមហ៊ុន សម្ប ទានធ្វើការ «វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬវាយតម្លៃហេតុប៉ះពាល់ បរិស្ថានពេញលេញសម្រាប់សំណើគម្រោង និងដាក់ជូនរបាយការណ៍វាយតម្លៃទាំង នោះមកក្រសួងបរិស្ថានដើម្បីពិនិត្យ លើកលែងតែក្នុងករណីចាំបាច់បន្ទាន់ខ្លះដែល តម្រូវឲ្យមានការសម្រេចដោយរាជរដ្ឋាភិបាល»។[២] ចំនុចខ្វះចន្លោះនេះអាចអោយ ក្រុមហ៊ុនសម្បទាន មានលទ្ធភាពពន្យាពេលក្នុងការធ្វើការវាយតម្លៃហេតុប៉ះពាល់ បរិស្ថាន និងសង្គមអោយបានចប់សព្វគ្រប់ ក្រោយពីព្រៃឈើត្រូវបានគេសម្អាត ហើយដីត្រូវបានគេបំលែងទៅតាមគោលបំណងផ្សេងៗរួចទៅហើយនោះ។

ជាក់ស្តែង នៅស្រុកសណ្តាន់ មានការចោទប្រកាន់ជាទូទៅថាមន្ត្រីមូលដ្ឋាន និងមន្ត្រីស្រុក បានពាក់ព័ន្ធនៅក្នុងការទន្ទ្រានយកដី និងការកាប់ឈើល្មើសច្បាប់។ មន្ត្រីរដ្ឋបាលព្រៃឈើនៅប៉ុស្តិត្រួតពិនិត្យស្រុកសណ្តាន់ ត្រូវបានគេចោទប្រកាន់ថា ពាក់ព័ន្ធធ្ងន់ធ្ងរក្នុងការកាប់ឈើល្មើសច្បាប់ និងមានការរិះគន់ជាច្រើនពីសំណាក់ ប្រជាជនមូលដ្ឋាន។ នៅកន្លែងផ្សេងៗទៀតនៃព្រៃឡង់ ក៏មានសហគមន៍រិះគន់អំពី បញ្ហាស្រដៀងគ្នានេះដែរ ចំពោះមន្ត្រីរដ្ឋបាលព្រៃឈើ។[៣]

នៅក្នុងរយៈពេលដ៏វែងខាងមុខ ការប៉ុនប៉ងរបស់រដ្ឋបាលព្រៃឈើក្នុងការ កំណត់ព្រៃឡង់សម្រាប់ជាតំបន់ការពារ និងជាតំបន់ដែលគួរអោយទាក់ទាញអាច មានប្រសិទ្ធភាព។ ប៉ុន្តែ ការកាប់ឈើល្មើសច្បាប់ដែលកើតឡើងជាទ្រង់ទ្រាយធំ មានន័យថា នៅក្នុងរយៈពេលខ្លីខាងមុខនេះគេចាំបាច់ត្រូវចាត់វិធានការផ្សេងទៀត ទើបអាចរក្សាព្រៃឈើដែលនៅសល់ឲ្យគង់វង្សបាន។

ការពង្រឹងកិច្ចការអនុវត្តច្បាប់ត្រូវតែអនុវត្តឲ្យបានម៉ឺងម៉ាត់ និងមានការស៊ើប អង្កេតជាបន្ទាន់លើការចោទប្រកាន់ចំពោះមន្ត្រីមូលដ្ឋាន អំពីការពាក់ព័ន្ធនៅក្នុងការ

---

[២] ប្រកាសស្តីពីការអនុវត្តគោលការណ៍ណែនាំទូទៅសម្រាប់ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៩ ។ (ក្រសួងបរិស្ថាន ប្រកាសលេខ ៣៧៦)

[៣] សេចក្តីលំអិតមាននៅក្នុងជំពូកស្តីពីលទ្ធផលនៃរបាយការណ៍នៅក្រោម "សកម្មភាពរបស់រដ្ឋបាលព្រៃឈើ"។

កាប់ឈើល្មើសច្បាប់។ ដើម្បីបញ្ឈប់ការកាប់ឈើល្មើសច្បាប់នៅទូទាំងតំបន់ព្រៃឡង់ រាជរដ្ឋាភិបាលត្រូវអនុញ្ញាតឲ្យសហគមន៍មូលដ្ឋានអនុវត្តសហគ្រប់គ្រងតំបន់ព្រៃឡង់ ជាពិសេសសហគ្រប់គ្រងប៉ុស្តិ៍ត្រួតពិនិត្យរបស់រដ្ឋបាលព្រៃឈើ។

# ជំពូកទី១: សេចក្តីផ្តើម

## ១. ព្រៃឈើនៅកម្ពុជា

ប្រវត្តិសាស្ត្រថ្មីៗនៃព្រៃឈើនៅកម្ពុជា គឺការបាត់បង់ជាប់ជាប្រចាំ។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ព្រៃឈើក្នុងប្រទេសនេះបានរងការកាប់ពីសំណាក់ខ្មែរក្រហម និងវៀតណាមសម្រាប់ជាមធ្យោបាយផ្គត់ផ្គង់ការវាយប្រយុទ្ធគ្នា។ នៅពេលដែលវៀតណាមបានចាកចេញពីកម្ពុជានៅក្នុងឆ្នាំ១៩៨៩ ហើយក៏ដោយ ភាគីនានាដែលពាក់ព័ន្ធនៅក្នុងសង្គ្រាមស៊ីវិលនាពេលក្រោយមក ក៏បានបន្តកាប់ឈើផងដែរ។ ក្រោយការបោះឆ្នោតនៅឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតអោយមានព្រៃសម្បទានចំនួន៣៦កន្លែង ដែលមានវិសាលភាពសរុប៧លានហិកតា ដែលត្រូវជាជិត៧០% នៃគម្របព្រៃឈើរបស់កម្ពុជា (កម្មវិធីព្រៃឈើជាតិឆ្នាំ២០១០-២០២៩។ ក្នុងអំឡុងពេលនោះ ភាពទន់ខ្សោយនៃការអនុវត្តច្បាប់ និងការពិនិត្យតាមដានបានអនុញ្ញាតឲ្យមានការកាប់ឈើល្មើសច្បាប់ និងការទន្ទ្រានយកដីធ្លីដោយគ្មានការត្រួតពិនិត្យ ហើយការបាត់បង់ព្រៃឈើបានកើនឡើងយ៉ាងខ្លាំង។ ជាការឆ្លើយតប នាយករដ្ឋមន្ត្រីបានចេញសេចក្តីសម្រេចព្យួរទុកសម្បទានព្រៃឈើ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០២ ខណៈពេលដែលរដ្ឋបាលព្រៃឈើបានកសាងយុទ្ធសាស្ត្រថ្មីមួយរបស់ខ្លួនសម្រាប់គ្រប់គ្រងព្រៃឈើទាំងមូលនៅក្នុងប្រទេសផងដែរ។[៤]

ទោះបីការព្យួរទុកនេះនៅជាធរមានក៏ដោយ ចាប់តាំងពីឆ្នាំ២០០៦ មក ព្រៃសម្បទានជាច្រើន ត្រូវបានកំណត់ឡើងវិញជាសម្បទានតាមទម្រង់ផ្សេងៗទៀត។ សម្បទានដីសេដ្ឋកិច្ច បានក្លាយជាកត្តាជម្រុញចំបងមួយនៃការបាត់បង់ព្រៃឈើនៅកម្ពុជា បើទោះជាការកាប់ឈើល្មើសច្បាប់បានបន្តក្លាយជាបញ្ហាធ្ងន់ធ្ងរហើយក៏ដោយ។ ដំណាំចំបងដែលជាមូលហេតុនៃការរានឆ្ការព្រៃគឺ កៅស៊ូ អំពៅ និងនៅពេលថ្មីៗនេះ គឺដំណាំសម្រាប់ជីវៈឥន្ធនៈដូចជា ដំឡូងមី។ ការរៀបរាប់ទាំងនេះគឺបណ្តាលមកពីការផ្តល់ដីសម្បទានសេដ្ឋកិច្ចដែលបង្ករអោយមានការទន្ទ្រានយកដី។

---

[៤] កម្មវិធីព្រៃឈើជាតិ ឆ្នាំ២០១០-២០២៩ និង "ឯកសារសាវតា" ដែលពាក់ព័ន្ធចេញផ្សាយដោយរដ្ឋបាលព្រៃឈើ



ផែនទី១: ផែនទីគម្របព្រៃឈើជាតិ ឆ្នាំ ២០០៦ (រដ្ឋបាលព្រៃឈើ)

ការរានឆ្ការដីភាគច្រើនសម្រាប់ធ្វើកសិកម្ម ហើយអ្នកចំណាកស្រុកដែលគ្មានដីធ្លីដែលមានជាបន្តបន្ទាប់ ក៏ជាកត្តាជម្រុញសំខាន់ៗនៃការបាត់បង់ព្រៃឈើនៅក្នុងប្រទេសផងដែរ។ ការបន្តប្រើប្រាស់អុសពីសំណាក់ប្រជាពលរដ្ឋភាគច្រើនដែលរួមទាំងឡផលិតឥដ្ឋនៃប្រទេសនេះ ដែលកំពុងលូតលាស់យ៉ាងឆាប់រហ័សក៏គួរតែចាត់ទុកថាជាការគំរាមកំហែងធ្ងន់ធ្ងរ មកលើព្រៃឈើដែលនៅសេសសល់ក្នុងប្រទេសកម្ពុជាផងដែរ។[៥]

បើទោះជាមានការបាត់បង់ព្រៃឈើយ៉ាងច្រើន នៅក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងទៅថ្មីៗនេះក៏ដោយ កម្ពុជានៅតែស្ថិតក្នុងចំណោមប្រទេសនៅអាស៊ីអាគ្នេយ៍ដែលមានគម្របព្រៃឈើក្នុងអត្រាខ្ពស់ជាងគេនៅឡើយ។ យោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលព្រៃឈើឆ្នាំ២០១០ ប្រទេសកម្ពុជាមានគម្របព្រៃឈើ ៥៦,៩៤% ដែលមានការថយចុះ ២,១៥% ចាប់តាំងពីឆ្នាំ២០០៦។ យោងតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ប្រទេសនេះត្រូវបង្កើនគម្របព្រៃឈើជាតិរបស់ខ្លួន

[៥] REDD + in the Prey long Area - A feasibility study: March 2011, Stavros Papageorgiou, Jenny Hewson, David Emmett, Marc Steininger. Conservation International.

ឲ្យដល់ ៦០% មកដល់ឆ្នាំ២០១៥។ អ្នកនាំពាក្យមួយរូបនៃរដ្ឋបាលព្រៃឈើបានព្រមានកាលពីខែមករា ឆ្នាំ២០១០ ថា «...គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាក្នុងការបង្កើនគម្របព្រៃឈើអោយបាន៦០% អាចមិនសម្រេចបានឡើយដោយសារតែនិន្នាការបាត់បង់បណ្តាលមកពីដីសម្បទានសេដ្ឋកិច្ច» និងមានការកត់សម្គាល់ផងដែរថា តំបន់សម្បទានមួយចំនួនទៀតកំពុងស្ថិតក្រោមការពិចារណាផ្តល់ជាដីសម្បទានបន្ថែមទៀត[៦]។

## ២. ការគ្រប់គ្រងដីព្រៃ

ភាគច្រើននៃព្រៃឈើនៅកម្ពុជាគឺជាសម្បត្តិរដ្ឋ និងស្ថិតនៅក្រោមការគ្រប់គ្រងនៃទីភ្នាក់ងារខុសៗគ្នានៃរដ្ឋាភិបាល អាស្រ័យតាមចំណាត់ថ្នាក់នៃប្រភេទព្រៃ។ ច្បាប់ចំបងៗដែលចែងទាក់ទងនឹងកិច្ចការព្រៃឈើរួមមានច្បាប់ភូមិបាល (ឆ្នាំ២០០១) និងច្បាប់ស្តីពីព្រៃឈើ (ឆ្នាំ២០០២)។ ច្បាប់ភូមិបាល (ឆ្នាំ២០០១) ចែកចំណាត់ថ្នាក់ដីធ្លីជាបួនក្រុម៖ i) *ដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋ:* ដីធ្លីសម្រាប់បម្រើផលប្រយោជន៍សាធារណៈ និងស្ថិតក្រោមការកាន់កាប់ជាកម្មសិទ្ធិសាធារណៈដែលមិនអាចលក់ ឬផ្ទេរទៅឲ្យបុគ្គលណាឡើយ។ ព្រៃឡង់ស្ថិតក្នុងចំណាត់ថ្នាក់នេះ។ ii) *ដីកម្មសិទ្ធិឯកជនរបស់រដ្ឋ:* ដីធ្លីរបស់រដ្ឋដែលមិនបម្រើផលប្រយោជន៍សាធារណៈ និងអាចលក់ ឬផ្ទេរទៅឲ្យបុគ្គលផ្សេង។ ដីជំពូកនេះរាប់បញ្ចូលព្រៃរេចរឹលដែលកំណត់ជាដីសម្បទានសេដ្ឋកិច្ច។ iii) *ដីធ្លីជនជាតិដើមភាគតិច:* ដីធ្លីដែលសហគមន៍ជនជាតិដើមបានតាំងទីលំនៅ និងធ្វើកសិកម្មតាមប្រពៃណី។ iv) *ដីកម្មសិទ្ធិឯកជន:* ដីធ្លីជាកម្មសិទ្ធិរបស់ឯកជន។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សំគាល់ថាតាមរយៈអនុក្រឹត្យនៃបទប្បញ្ញត្តិ និងនីតិវិធីស្តីពីការធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋ និងអង្គភាពសាធារណៈ[៧] រដ្ឋាភិបាលអាចបម្លែង *ដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋ* ទៅជា *ដីកម្មសិទ្ធិឯកជនរបស់រដ្ឋ* ដែលជាញឹកញាប់ នេះជាករណី

[៦] Cambodia: Forests under threat - The Phnom Penh Post, 17th January 2011, by Vong Sockheng and James O'Toole in reference to the FA annual report 2010.

[៧] អនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០៦

សម្រាប់ដីសម្បទានសេដ្ឋកិច្ច។

នៅក្នុងច្បាប់ស្តីពីព្រៃឈើ (ឆ្នាំ២០០២) ព្រៃឈើត្រូវបានចាត់ទុកជាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ដែលត្រូវបានបែងចែកជាព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងតំបន់ព្រៃឯកជន។ ព្រៃបម្រុងទុកអចិន្ត្រៃយ៍ប្រមាណ៧០% នៃព្រៃឈើក្នុងប្រទេសទាំងមូលត្រូវបានចាត់ទុកថាជាសម្បត្តិសាធារណៈរបស់រដ្ឋ ដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងនៃរដ្ឋបាលព្រៃឈើ និងបែងចែកជាបន្តដូចក្នុងតារាងទី១ខាងក្រោម។ បន្ថែមលើរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន រដ្ឋបាលជលផល និងទីភ្នាក់ងាររដ្ឋាភិបាលមួយចំនួនផ្សេងទៀតក៏ពាក់ព័ន្ធក្នុងការគ្រប់គ្រងព្រៃឈើនៅក្នុងប្រទេសផងដែរ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានការពាក់ព័ន្ធដោយផ្ទាល់ក្នុងការផ្តល់ដីសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុននានា ហើយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលជាអ្នកចេញអាជ្ញាប័ណ្ណសម្រាប់ការរុករក និងធ្វើអាជីវកម្មរ៉ែ ខណៈដែលការរុករក ការអភិវឌ្ឍ និងការប្រើប្រាស់ដីសម្បទាន រួមទាំងដីសម្បទានរុករករ៉ែ គឺជាបន្ទុករបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងបរិស្ថាន ក្រសួងសាធារណៈការ និងដឹកជញ្ជូន និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក៏អាចផ្តល់ជាយោបល់សំខាន់ៗទៅលើការអភិវឌ្ឍផ្សេងៗផងដែរ។ អ្នកពាក់ព័ន្ធដទៃទៀតនៃព្រៃឈើនៅកម្ពុជារួមមាន យោធា ក្រុមហ៊ុនឯកជន សហគមន៍ជនជាតិដើមភាគតិច អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ម្ចាស់ជំនួយ ធ្វើឲ្យកិច្ចការគ្រប់គ្រងព្រៃឈើកាន់តែមានភាពស្មុគស្មាញជាបន្ថែមទៀត។

តារាងទី១: ការចាត់ចែងរដ្ឋបាលលើសម្បត្តិព្រៃឈើអចិន្ត្រៃយ៍របស់កម្ពុជា

| ប្រភេទព្រៃ | សមត្ថកិច្ច | និយមន័យជំពូកព្រៃឈើ |
|---|---|---|
| ព្រៃបម្រុងអចិន្ត្រៃយ៍ - *សម្បត្តិសាធារណៈរបស់រដ្ឋ* | | |
| ព្រៃផលិតកម្ម | រដ្ឋបាលព្រៃឈើ | សម្រាប់ជាព្រៃសម្បទាន និងតំបន់ព្រៃសហគមន៍ ជាពិសេសសម្រាប់ផលិតកម្មឈើ និងអនុផលព្រៃឈើដោយនិរន្តរភាព |
| ព្រៃការពារ | រដ្ឋបាលព្រៃឈើ | សម្រាប់អភិរក្សជីវៈចម្រុះ ការពារប្រព័ន្ធអេកូឡូស៊ីសំខាន់ៗដូចជាទីជម្រាល |
| ព្រៃចាត់ថ្នាក់ឡើងវិញ | រដ្ឋបាលព្រៃឈើ | ដីព្រៃរិចរឹលធ្ងន់ធ្ងរឬដីទំនេរ។ អាចចាត់ថ្នាក់ឡើងវិញតាមរយៈអនុក្រឹត្យសម្រាប់ការអភិវឌ្ឍ ឬសម្រាប់ជាដីសម្បទានសេដ្ឋកិច្ច/សង្គមកិច្ច។ |
| ព្រៃឯកជន - *សម្បត្តិឯកជនដែលមានព្រៃឈើ និងមិនមែនជារបស់រដ្ឋ* | | |
| | រដ្ឋបាលព្រៃឈើ | រួមបញ្ចូល ដីព្រៃដែលត្រូវបានផ្ទេរទៅឲ្យជនជាតិដើមភាគតិច តាមរយៈការ ផ្តល់ប័ណ្ណកម្មសិទ្ធដីសមូហភាព |
| តំបន់ការពារធម្មជាតិ | ក្រសួងបរិស្ថាន | ជំពូកផ្សេងទៀតនៃសម្បត្តិរបស់រដ្ឋ |
| | រដ្ឋបាលជលផល | ព្រៃលិចទឹក ព្រៃកោងកាង |

## ២.១ កម្មវិធីព្រៃឈើជាតិ ឆ្នាំ ២០១០-២០២៩

នៅឆ្នាំ២០១០ រដ្ឋបាលព្រៃឈើបានរៀបរៀងកម្មវិធីព្រៃឈើជាតិដែលជាផែនការជាតិសម្រាប់ធនធានព្រៃឈើរបស់កម្ពុជាសម្រាប់ឆ្នាំ២០១០-២០២៩។ កម្មវិធីនេះមានគោលបំណងចំនួន៩ និងបានតាក់តែងឡើងសម្រាប់ «ជម្រុញការគ្រប់គ្រងព្រៃឈើឲ្យមាននិរន្តរភាព ដើម្បីរួមវិភាគទានក្នុងការកាត់បន្ថយភាពក្រីក្រ ពង្រឹងរបរចិញ្ចឹមជីវិត កំណើនសេដ្ឋកិច្ច និងកិច្ចការពារបរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះ និងបេតិកភណ្ឌវប្បធម៌របស់យើង»។

គោលបំណងទីមួយនៃកម្មវិធីព្រៃឈើជាតិ ផ្តល់នូវអំណះអំណាងដ៏រឹងមាំមួយអំពីកិច្ចការពារព្រៃឡង់ ដោយសារគុណតម្លៃជាក់ស្តែងនៃព្រៃឈើនេះសម្រាប់ប្រជាពលរដ្ឋជាច្រើនពាន់នាក់។ រួមជាមួយសារៈសំខាន់នៃព្រៃឈើដែលទាក់ទងនឹងសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ ក្របខ័ណ្ឌនៃកម្មវិធីព្រៃឈើជាតិផ្តល់ហេតុផលគ្រប់គ្រាន់សម្រាប់ផ្តល់ឲ្យព្រៃឡង់នូវកិច្ចការពារ តាមទម្រង់ដែលមានបច្ចុប្បន្ន ពោលគឺ *ព្រៃការពារ*។

តារាងទី២: គោលបំណងនៃកម្មវិធីព្រៃឈើជាតិ

| គោលបំណងកម្មវិធីព្រៃឈើជាតិ | |
|---|---|
| ១ | បង្កើនវិភាគទានពីព្រៃឈើដោយនិរន្តរភាពដើម្បីកាត់បន្ថយភាពក្រីក្រ ពង្រឹងរបរចិញ្ចឹមជីវិត និងកំណើនសេដ្ឋកិច្ចដោយសមធម៌ |
| ២ | បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយឥទ្ធិពលរបស់វាមកលើរបរចិញ្ចឹមជីវិតដែលពឹងផ្អែកលើព្រៃឈើ |
| ៣ | ការកសាងផែនការប្រើប្រាស់ដីនៅកម្រិតម៉ាក្រូ ដែលអាចឲ្យមានការកសាងផែនការគ្រប់ជ្រុងជ្រោយនៅទូទាំងវិស័យទាំងអស់ ដែនសមត្ថកិច្ច និងព្រំប្រទល់រដ្ឋាភិបាលមូលដ្ឋាន |
| ៤ | អភិបាលកិច្ចព្រៃឈើ ច្បាប់ និងការពង្រឹងការអនុវត្តនៅគ្រប់លំដាប់ថ្នាក់ |
| ៥ | បង្កើតប្រព័ន្ធគ្រប់គ្រងទំនាស់ |
| ៦ | បង្កើនការយល់ដឹង សមត្ថភាពរបស់ស្ថាប័ន និងគុណភាពនៃការអប់រំ ដែលអាចឲ្យមានការអនុវត្តដោយនិរន្តរភាពនូវកម្មវិធីព្រៃឈើជាតិ |
| ៧ | ធានាកិច្ចការពារបរិស្ថាន និងអភិរក្សធនធានព្រៃឈើ |
| ៨ | អនុវត្តគំរូគ្រប់គ្រងព្រៃឈើបែបទំនើបដែលមាននិរន្តរភាព និងដែលបន្សាំទៅនឹងបរិបទដែលប្រែប្រួល |
| ៩ | បង្កើតប្រព័ន្ធហិរញ្ញប្បទានដែលមាននិរន្តរភាព |

## ២.២. កម្មវិធីសហគមន៍ព្រៃឈើ

សហគមន៍ព្រៃឈើនៅកម្ពុជា បានចាប់ផ្តើមនៅក្នុងអំឡុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ និងត្រូវបានអភិវឌ្ឍន៍បន្តទៅជាកម្មវិធីសហគមន៍ព្រៃឈើជាតិនៅក្នុងឆ្នាំ២០០៦។ ការចុះបញ្ជីសហគមន៍ព្រៃឈើបានបន្តពង្រីកនៅក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ ហើយកម្មវិធីព្រៃឈើជាតិប្តេជ្ញារយៈពេលម្ភៃឆ្នាំដើម្បីអភិវឌ្ឍន៍សហគមន៍ព្រៃឈើជាបន្តនៅទូទាំងប្រទេស។[៨] ផ្នែកមួយនៃការប្តេជ្ញានេះមានបំណងសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ប្រទេសដើម្បីកាត់បន្ថយភាពក្រីក្រ និងបង្កើនសន្តិសុខនៅតាមជនបទ។ នៅក្រោមកម្មវិធីសហគមន៍ព្រៃឈើ សហគមន៍នានាត្រូវបានកំណត់ទៅតាមតំបន់ព្រៃឈើដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។ កិច្ចព្រមព្រៀងសហគមន៍ព្រៃឈើដែលបានចុះហត្ថលេខា មានសុពលភាពសម្រាប់រយៈ

[៨] កម្មវិធីព្រៃឈើជាតិឆ្នាំ២០១០-២០២៩ ផលិតដោយរដ្ឋបាលព្រៃឈើ ទំព័រទី៨៩

ពេលដំបូង១៥ឆ្នាំ និងបន្ទាប់ពីនោះត្រូវពិនិត្យឡើងវិញ ហើយចំណុចលម្អិតអំពីការពិនិត្យបែបនេះនៅពុំទាន់មានការសម្រេចនៅឡើយទេ។[៩] ការពង្រីកកម្មវិធីសហគមន៍ព្រៃឈើ មានន័យថាបានធ្វើអោយមានការអនុវត្តសមស្របទទួលបានការគាំទ្រ និងពង្រឹងការអនុវត្តដែលអាចជួយអោយសហគមន៍ព្រៃឈើមាននិរន្តរភាព និងការពារបាននូវធនធានរបស់ពួកគេ។ នៅឆ្នាំ២០០៩ រដ្ឋាភិបាលបានចុះបញ្ជីសម្រាប់ទីតាំងសហគមន៍ព្រៃឈើចំនួន៤០០ កន្លែង[១០] នៅទូទាំងប្រទេស។ ប៉ុន្តែ ជាញឹកញាប់បំផុត កន្លែងដែលផ្តល់ជាសហគមន៍ព្រៃឈើគឺជាកន្លែងដែលមានព្រៃរេចរឹលឬជាព្រៃដែលមានគុណភាពទាបដែលមានអនុផលព្រៃឈើតិចតួចតែប៉ុណ្ណោះ។ ឧទាហរណ៍ សហគមន៍ព្រៃឈើនៅភូមិស្រែវាល ស្រុកសណ្តាន់ ទំនងជាត្រូវបានប្រើប្រាស់ជាមធ្យោបាយដើម្បីធ្វើឲ្យអ្នកភូមិស្ងប់ចិត្ត មុននឹងផ្តល់ដីសម្បទានសេដ្ឋកិច្ចនៅក្នុងតំបន់នោះ។ នៅក្នុងករណីស្រែវាល អ្នកភូមិបានត្អូញត្អែរថា សហគមន៍ព្រៃឈើគ្រាន់តែជាព្រៃ «មានគុណភាពទាប» ចំណែកដីសម្បទានសេដ្ឋកិច្ចគឺជាព្រៃដែលមិនទាន់រេចរឹល ពោលគឺជាកន្លែងដែលអ្នកភូមិធ្លាប់ប្រមូលយកអនុផលព្រៃឈើបានជាច្រើន។

## ៣. ដីសម្បទានសេដ្ឋកិច្ច

យោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលព្រៃឈើ សម្រាប់ឆ្នាំ២០១០ ដីសម្បទានសេដ្ឋកិច្ចសរុបនៅទូទាំងប្រទេសមានទំហំ១,៣លានហិកតា គិតត្រឹមថ្ងៃបោះពុម្ពរបាយការណ៍ ហើយដីសម្បទានទាំងនោះគិតរួមទាំងដីសម្បទានជាច្រើនដែលស្ថិតនៅក្នុងតំបន់ការពារផងដែរ។ ប៉ុន្មានខែថ្មីៗនេះ សម្បទានថ្មីៗត្រូវបានផ្តល់អោយនៅក្នុងដែនជម្រកសត្វព្រៃស្នួល និងបឹងពែរដែលស្ថិតនៅត្រឹមប៉ុន្មានគីឡូម៉ែត្រពីខាងលិចព្រៃឡង់ និងជាកន្លែងដែលត្រូវបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដោយសារការកាប់ទន្ទ្រានព្រៃឈើនៅក្នុងព្រៃជ្រៅ។ ដូចជាព្រៃឡង់ផងដែរ សហគមន៍មូលដ្ឋានដែលរស់នៅតាមតំបន់ព្រៃឈើបច្ចុប្បន្ននេះ កំពុងតវ៉ាប្រឆាំងនឹងក្រុមហ៊ុន

---

[៩] កម្មវិធីព្រៃឈើជាតិឆ្នាំ២០១០-២០២៩ ផលិតដោយរដ្ឋបាលព្រៃឈើ ទំព័រទី៩១

[១០] កម្មវិធីព្រៃឈើជាតិឆ្នាំ២០១០-២០២៩ ផលិតដោយរដ្ឋបាលព្រៃឈើ ទំព័រទី៩០

សម្បទានទាំងនេះ និងការកាប់ឈើអនាធិបតេយ្យដែលទំនងជាកើតឡើងនៅជុំវិញកន្លែងដែលពួកគេរស់នៅ។ តំបន់ការពារផ្សេងៗទៀតដែលបច្ចុប្បន្ននេះក្លាយជាដីសម្បទាន រួមមានដែនជម្រកសត្វព្រៃឱរ៉ាល់ ដែនជម្រកសត្វព្រៃភ្នំសំកុះ ឧទ្យានជាតិវិរៈជ័យ និងឧទ្យានជាតិបូកគោ។

ជាក់ស្តែងនៅក្នុងឆ្នាំ២០១១ គេមានការលំបាកក្នុងការទទួលបានព័ត៌មានថ្មីៗអំពីដីសម្បទានសេដ្ឋកិច្ចដែលបានផ្តល់ដោយសារតែព័ត៌មានដែលមន្ត្រីផ្តល់ឲ្យ ពុំស៊ីសង្វាក់គ្នា។ នៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១១ លោក វន ធឿន នាយកតំបន់បឹងពែរ ត្រូវបានគេស្រង់សំដីដែលពោលថា ១០០,០០០ហិកតា ក្នុងទំហំដីសរុប២៨២,៥០០ហិកតា នៃតំបន់ការពារធម្មជាតិនេះត្រូវបានអភិវឌ្ឍន៍តាមរយៈសម្បទានសេដ្ឋកិច្ចដែលបានផ្តល់នៅក្រោមអនុក្រឹត្យខុសៗគ្នា។[១១] ត្រឹមប៉ុន្មានសប្តាហ៍ក្រោយមកមានសេចក្តីរាយការណ៍ថានៅក្នុង «សៀវភៅរាជកិច្ច» ចុងក្រោយបង្អស់ដែលកត់ត្រារាល់អនុក្រឹត្យដែលរាជរដ្ឋាភិបាលបានអនុម័ត នាយករដ្ឋមន្ត្រី ហ៊ុន សែន បានចុះហត្ថលេខាផ្តល់ដីទំហំ២៥,៧២៩ហិកតា នៅក្នុងដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព្យ និង៧៦០ហិកតា ថែមទៀត នៅដែនជម្រកសត្វព្រៃបឹងពែរនៅក្នុង ខែធ្នូ ឆ្នាំ២០១១។ លោក វន ធឿន ត្រូវបានគេស្រង់សំដី ដែលពោលថា ក្រុមហ៊ុនចំនួនចំនួន១៨ កំពុងអភិវឌ្ឍន៍លើផ្ទៃដីទំហំ ១៥០,០០០ ហិកតា នៅក្នុងតំបន់នោះ។[១២]

[១១] http://www.phnompenhpost.com/index.php/2011102852407/National-news/wildlife-sanctuary-shrinks-again.html

[១២] http://www.phnompenhpost.com/index.php/2012010353748/National-news/companies-granted-wildlife-land.html

ប្រអប់ ១: ដកស្រង់ពីអត្ថបទក្នុងខេមបូឌាដេលី «Carving Up Cambodia» ថ្ងៃទី ១០-១១ ខែមីនា ឆ្នាំ ២០១២

«និន្នាការមួយក្នុងចំណោមដីសម្បទានថ្មីៗគឺថា មានកំណើននៃការផ្តល់ដីសម្បទាននៅក្នុងតំបន់ការពារព្រៃធម្មជាតិដែលបង្កឲ្យមានកំណើនអត្រាបាត់បង់ព្រៃឈើ។ ទិន្នន័យពីលីកាដូបង្ហាញថា ថ្មីៗនេះក្រសួងបរិស្ថានបានបើកចំហឧទ្យានជាតិ និងដែនជម្រកសត្វព្រៃទាំង ២៣កន្លែង ដល់ក្រុមហ៊ុនវិនិយោគ ដោយផ្តល់ដីទំហំប្រមាណ ៣៤៦,០០០ហិកតា នៅក្នុងតំបន់អភិរក្សចំនួន១៣កន្លែង ឬត្រូវជា១០.៥% នៃផ្ទៃដីចំការកៅស៊ូសរុប។ មួយផ្នែកធំនៃដីទាំងនោះស្ថិតនៅក្នុងព្រៃដែលពុំទាន់រេចរឹលនៅឡើយ។ យោងតាមអនុក្រឹត្យដែលសារព័ត៌មានខេមបូឌាដេលីទទួលបាន ដីទំហំប្រមាណ២៥១,០០០ហិកតា នៃសម្បទានទាំងនេះ ត្រូវបានផ្តល់តែនៅក្នុងឆ្នាំ២០១១ តែប៉ុណ្ណោះ ចំណែក ៤០,០០០ហិកតាផ្សេងទៀតត្រូវបានត្រៀមទុកជាបន្តរហូតដល់ឆ្នាំនេះ។»

តាមពិតទៅ យើងអាចមិនដឹងច្បាស់ថាតើដីទំហំប៉ុន្មានដែលបានផ្តល់ទៅឲ្យក្រុមហ៊ុនឯកជនឡើយ។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានបង្ហាញតួលេខចំនួន ១,៧៨លានហិកតា[១៣] ចំណែកអង្គការលីកាដូ ប៉ាន់ស្មានថាមាន ២,០៣៦,១៧០ហិកតា។[១៤] ភាពខុសគ្នាទាំងនេះ អាចកើតឡើងដោយសារតែការលំបាកក្នុងការទទួលបានទិន្នន័យអំពីដីសម្បទានសេដ្ឋកិច្ច ដែលបានផ្តល់ទៅអោយក្រុមហ៊ុនឯកជន។

ការអះអាងអំពីការបង្កើតការងារយ៉ាងច្រើនពីដីសម្បទានទាំងនេះ ច្រើនតែជាការបំភ្លើស ហើយជាញឹកញាប់គឺពុំមែនជាការងារដែលប្រជាពលរដ្ឋក្នុងមូលដ្ឋានមានជំនាញនោះឡើយ ដូច្នេះ បានត្រឹមតែផ្តល់ការងារទៅអ្នកមកពីខាងក្រៅតែ

[១៣] វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា «ទិន្នន័យដីសម្បទានសេដ្ឋកិច្ច ឆ្នាំ២០១១»។ សំគាល់: គ្មានទិន្នន័យពិតប្រាកដសម្រាប់ឆ្នាំ ២០១២ឡើយ

[១៤] "Carving Up Cambodia: One concession at a time"; A Join LICADHO/Cambodia Daily Analysis, The Cambodia Daily, Issue number 730, March 10-11, 2012, Pg 4ff. http://www.camnet.com.kh/cambodia.daily/selected_features/Carving%20Up%20Cambodia.pdf

ប៉ុណ្ណោះ។[១៥]

**ប្រអប់ ២: និយមន័យដីសម្បទានសេដ្ឋកិច្ច**

### និយមន័យដីសម្បទានសេដ្ឋកិច្ច

យោងតាមមាត្រា ២ នៃអនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច ដែលចេញដោយរដ្ឋាភិបាលក្នុងឆ្នាំ២០០៥ ដីសម្បទានសេដ្ឋកិច្ច «សំដៅលើយន្តការក្នុងការផ្តល់ដីឯកជនរបស់រដ្ឋ តាមរយៈកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ចជាក់លាក់មួយទៅឲ្យសម្បទានិក ដើម្បីប្រើប្រាស់សម្រាប់អាជីវកម្មកសិកម្ម និងអាជីវកម្មកសិ-ឧស្សាហកម្ម»។[1] ដូច្នេះ ជាសិទ្ធិក្នុងការកាន់កាប់ដីកម្មសិទ្ធិឯកជនរបស់រដ្ឋសម្រាប់ធ្វើអាជីវកម្មកសិកម្ម និងកសិ-ឧស្សាហកម្ម ដែលបម្រើគោលដៅសេដ្ឋកិច្ច។ មាត្រា ២ ចែងបន្ថែមថា៖ «អាជីវកម្មកសិ-ឧស្សាហកម្ម សំដៅលើ៖

. ការដាំដំណាំស្បៀង ឬដំណាំឧស្សាហកម្មដែលរួមទាំងដើមឈើសម្រាប់ជាចំការឈើ។

. ការចិញ្ចឹមសត្វ និងវារីវប្បកម្ម។

. ការសាងសង់ដូចជាស្ថានីយ៍ ឬ រោងចក្រ និងកន្លែងសម្រាប់កែច្នៃផលិតផលកសិកម្មក្នុងស្រុក។

. វត្ថុធាតុដើម ឬ បង្គុំនៃសកម្មភាពខាងលើខ្លះៗ ឬ ទាំងអស់»។

. រយៈពេលអតិបរមានៃដីសម្បទានសេដ្ឋកិច្ចគឺ ៩៩ឆ្នាំ។[2]

1 មាត្រា ៣ នៃអនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច

2 មាត្រា ៥៩ នៃច្បាប់ភូមិបាល។

កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១០ មានការពិភាក្សាមួយនៅរដ្ឋសភាដែលទាក់ទងនឹងការផ្តល់ដីសម្បទានសេដ្ឋកិច្ច។ លោក អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានប្រាប់សមាជិកសភាថា រដ្ឋាភិបាលបានផ្តល់ដីសម្បទានសេដ្ឋកិច្ចត្រឹមតែ ៩៥០,០០០ហិកតា ហើយក្នុងនោះ ៣០០,០០០ហិកតា បានដកហូតមកវិញដោយសារតែក្រុមហ៊ុនគ្មានសកម្មភាព។[១៦]

[១៥] Land Grabbing & Poverty in Cambodia: The Myth of Development, by Licadho May 2009: Economic Land Concessions and Local Communities by NGOF, August 2011.

[១៦] http://www.cambodiamirror.org/2010/04/03/the-government-provides-950000-hectares-of-concession-land-to-companies-friday-2-4-2010/

តួលេខរបស់រដ្ឋមន្ត្រីរូបនេះបង្ហាញពីការព្រួយបារម្ភថា ដីសម្បទានសេដ្ឋកិច្ច ១/៣ នៅពុំទាន់មានការសម្រេចនៅឡើយ។

## ៤. ពលរដ្ឋជនជាតិដើមភាគតិច - សិទ្ធិ និងការកាន់កាប់ដី

ជាប្រពៃណី សហគមន៍ព្រៃឈើមានការពឹងផ្អែកជាខ្លាំងទៅលើដីធ្លី និងព្រៃឈើ។ ជាក់ស្តែង ដើមច្បោះមិនត្រឹមតែជាប្រភពចំណូលចំបងរបស់ពួកគេទេ ប៉ុន្តែដើមច្បោះទាំងនោះ ថែមទាំងជាតំណាងអោយសារៈសំខាន់នៃសមធម៌ទៀតផង។ ដើមច្បោះជាកេរ្តិ៍មរតក សម្រាប់ផ្ទេរអោយទៅកូនចៅពីជំនាន់មួយទៅជំនាន់មួយ ហើយនៅក្នុងករណីមានការចាំបាច់បន្ទាន់ក្នុងគ្រួសារ ពួកគេអាចលក់ដើមច្បោះនោះបាន។ ទោះបីជាដើមច្បោះ និងអនុផលព្រៃឈើដទៃទៀតមិនអាចផ្តល់នូវប្រាក់ចំណូលដ៏ច្រើន ប៉ុន្តែវាពិតជាបានផ្តល់សន្តិសុខសម្រាប់សហគមន៍ជនជាតិដើមភាគតិចទាំងនេះ និងបានផ្តល់នូវធនធានយ៉ាងសំខាន់មិនត្រឹមតែសម្រាប់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែសំរាប់ប្រជាជនគ្រប់គ្នាផងដែរ។

ពលរដ្ឋជាជនជាតិដើមភាគតិចកម្ពុជាកំពុងរស់នៅទូទាំងផ្ទៃប្រទេស។ យោងតាមជំរឿនប្រជាសាស្ត្រ ឆ្នាំ២០០៨ ប្រជាជនចំនួន ១.៣៤% នៃចំនួនសរុប ឬត្រូវជា ១៧៩,០០០នាក់ បានរាយការណ៍ថាមានភាសាជនជាតិដើមរបស់ខ្លួនជាភាសាកំណើត។[១៧] ទោះជាយ៉ាងណា ដោយសារតែជនជាតិដើមភាគតិចមានចំនួនកាន់តែច្រើនឡើងដែលនិយាយតែភាសាខ្មែរ ដូច្នេះ គេជឿថាចំនួននេះមានខ្ពស់ជាងនេះខ្លាំងណាស់។

ចំពោះនិយមន័យដែលកំណត់ថានរណាជា «ជនជាតិដើមភាគតិច» គឺមិនមានភាពច្បាស់លាស់ឡើយ។ ប្រទេសកម្ពុជាមានច្បាប់ជាច្រើនដែលធានាអំពីសិទ្ធិរបស់ជនជាតិដើមភាគតិច ប៉ុន្តែនៅមានសហគមន៍ជាច្រើនដែលយើងហៅថាខ្មែរដែលមានលក្ខណៈនៃការចែករំលែក និងការអនុវត្តប្រហាក់ប្រហែលគ្នា មានការពឹង

[១៧] Current Population Census Of Cambodia 2008, Hor Darith, Deputy Director General, National Institute of Statistics (NIS)

ផ្អែកលើរបរចិញ្ចឹមជីវិតដូចគ្នា មានជំនឿដូចគ្នាទៅលើព្រៃអារក្ស និងមាន «ព្រៃអារក្ស» សម្ភហភាព និងឆ្លុះបញ្ចាំងពីវប្បធម៌នៃក្រុមជនជាតិដើមភាគតិចនៅមូលដ្ឋាន។ ទោះយ៉ាងណា នៅពេលដែលគេកំណត់ថាសហគមន៍មួយជា «ខ្មែរ» សហគមន៍នោះគឺត្រូវបានគេចាត់ទុកថា មិនមានសិទ្ធិចំពោះដីសហគមន៍ដូចជនជាតិដើមភាគតិចឡើយ។ ដើម្បីទទួលបានសិទ្ធិជាជនជាតិដើមភាគតិច ពួកគេត្រូវតែមានភស្តុតាងបញ្ជាក់ថាពួកគេជាជនជាតិដើមភាគតិច មិនមែនជាខ្មែរទេ។ មានសេចក្តីរាយការណ៍ថាក្រុមហ៊ុនឯកជន និងអាជ្ញាធរមូលដ្ឋានខ្លះបានព្យាយាមមិនផ្តល់កិច្ចការពារម៉ត់ចត់ដល់សហគមន៍ជនជាតិដើមភាគតិចឡើយ ដោយអះអាងខុសៗគ្នាថាពួកគេមិនមែនជាជនជាតិដើមភាគតិចឡើយដោយសារពួកគេមិនស្លៀកពាក់តាមប្រពៃណី ប្រើប្រាស់ទោចក្រយានយន្ត មានទូរស័ព្ទចល័តប្រើប្រាស់ ឬពួកគេអាចនិយាយភាសាខ្មែរ។[១៨] ប្រការទាំងអស់នេះ មានការពាក់ព័ន្ធតិចតួចប៉ុណ្ណោះសម្រាប់ការកំណត់អត្តសញ្ញាណថាអ្នកណាម្នាក់មកពីក្រុមជនជាតិដើមភាគតិច។

ជាជនជាតិដើមភាគតិចនៅកម្ពុជាភាគច្រើនជាអ្នករស់នៅក្នុងព្រៃ និងរស់នៅក្នុងហាគមន៍ដែលមានអាយុចំណាស់មកហើយ។ ពួកគេពឹងផ្អែកស្ទើរតែទាំងស្រុងលើធនធានធម្មជាតិនៅជុំវិញពួកគេ សម្រាប់ការរស់នៅប្រចាំថ្ងៃ ដោយប្រើប្រាស់សម្ភារៈសាងសង់ អាហារ និងឱសថពីព្រៃឈើ។ សម្រាប់អ្នកទាំងនោះ ភាគច្រើនព្រៃឈើក៏ជាប្រភពប្រាក់ចំណូលផងដែរ ដែលក្នុងនោះប្រាក់ចំណូលភាគច្រើនបានមកពីការលក់ជ័រទឹកដែលពួកគេប្រមូលបានមកពីដើមច្បោះមួយចំនួន។ ក្នុងមួយឆ្នាំៗ មានការប៉ាន់ប្រមាណថាជ័រទឹកប្រមាណ២០,០០០តោន ត្រូវគេប្រមូលយកពីព្រៃក្នុងប្រទេសកម្ពុជា។[១៩] ជាញឹកញាប់ ជ័រទាំងនេះគឺជាប្រភពតែមួយគត់នៃប្រាក់ចំណូលសម្រាប់អ្នកភូមិ ដោយគ្រួសារភាគច្រើនអះអាងថាបានកាន់កាប់ដើមច្បោះជាច្រើនរាប់រយដើម។ ប្រាក់ចំណូលដែលបានពីជ័រទឹកមានកម្រិតខុសគ្នាអាស្រ័យទៅលើបរិមាណ និងគុណភាពនៃផលិតផលនេះ។ ប្រាក់ចំណូលបន្ថែមក៏បានមក

---

[១៨] Losing Ground – Forced Evictions and Intimidation in Cambodia September 2009.

[១៩] Capacity Building for Law Compliance in the Forest Sector - Case study: Cambodia by Liviu Amariei for FAO/ITTO, December 2004

ពីអនុផលព្រៃឈើក្នុងទម្រង់ខុសៗគ្នាផងដែរ ដូចជា ផ្តៅដែលធ្លាប់ត្រូវបានអ្នកទាំងនេះប្រើប្រាស់ជាប្រពៃណីសម្រាប់ការសាងសង់ ច្រើនជាងសម្រាប់ជាប្រភពប្រាក់ចំណូល។ ដីដែលមានគុណភាពទាបនៅតាមកន្លែងភាគច្រើនក្នុងតំបន់ព្រៃឡង់ មិនសមស្របសម្រាប់ដំណាំស្រូវឡើយ ដូច្នេះ ប្រជាជនច្រើនតែដាំដំណាំផ្សេងទៀតដូចជា សណ្តែកសៀង សណ្តែកបាយ ពោត និងស្វាយចន្ទីដែលជាទូទៅប្រើប្រាស់ជាប្រភពប្រាក់ចំណូលដើម្បីទិញអង្ករសម្រាប់គ្រួសារ។[២០]

ការអប់រំនៅមានកម្រិតទាបនៅឡើយ ដោយសារសហគមន៍ខ្លះនៅឆ្ងាយជាកត្តាមួយ ប៉ុន្តែភាគច្រើនបណ្តាមកពីបញ្ហាភាសារ។ នេះជាភាពស្មុគស្មាញបន្ថែមទៀត ដោយសារក្រុមជនជាតិដើមភាគច្រើនមិនមានភាសារសរសេរ។ បច្ចុប្បន្នភាសារខ្មែរជាភាសារតែមួយគត់ដែលគេបង្រៀននៅតាមសាលាកម្ពុជា លើកលែងតែសាលាចំណុះមួយដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលនៅឆ្នាំ២០០៩ នៅខេត្តមណ្ឌលគិរីដែលមានបង្រៀនពីរភាសា[២១]។ ស្ថានភាពអប់រំរបស់ជនជាតិដើមភាគតិចជាច្រើននៅតែមានកម្រិតទាប ហើយមានឥទ្ធិពលជាខ្លាំងទៅលើលទ្ធភាពរបស់ពួកគេក្នុងការយល់ច្បាស់ពីសិទ្ធិរបស់ខ្លួននៅក្នុងច្បាប់កម្ពុជា។

ទោះបីច្បាប់កម្ពុជាមានមាត្រាមួយចំនួន ចែងអំពីការការពារដីធ្លីជនជាតិដើមភាគតិចក៏ដោយ ភាពផ្ទុយគ្នាជាច្រើនរវាងច្បាប់ និងអនុក្រឹត្យ ក៏ធ្វើឲ្យជនជាតិដើមភាគតិចជាច្រើននៅទូទាំងប្រទេស បាត់បង់សិទ្ធិទាំងនេះផងដែរ។ ជាក់ស្តែង ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ[២២] ចែងថាពលរដ្ឋជាជនជាតិដើមភាគតិចមិនអាចទទួល

---

[២០] មួយផ្នែកនៃជំពូកនេះគឺជាព័ត៌មានដែលរកបាននៅក្នុងការសិក្សានេះ និងបានមកពីរបាយការណ៍ Dipterocarp oleoresin in Vietnam and Cambodia: harvesting techniques, resource management and livelihood issues - Hong-Truong Luu Center for Biodiversity and Development (CBD), Femy Pinto NTFP-Exchange Programme for South and Southeast Asia May 2007

[២១] Rights of Indigenous Peoples in Cambodia: February 2010, NGO Forum, Indigenous People NGO Network, Asian Indigenous Peoples Pact, Cambodian Human Rights Action Committee, Human Rights Task Force.

[២២] Protected Area Law, 2008, Article 26

កម្មសិទ្ធិលើដីដាំដំណាំនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិបានឡើយ។[២៣] ប្រការនេះ ផ្ទុយគ្នាជាមួយច្បាប់ភូមិបាលដែលបានចែងថា ចំណែកដីខ្លះដែលជាកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ក៏រួមបញ្ចូលដីកម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិចផងដែរ។

អនុក្រឹត្យមួយស្តីពីការចុះបញ្ជីដីធ្លីក៏កំរិតលើទំហំដីព្រៃអ្នកតា និងព្រៃកប់សពផងដែរ ដែលអាចបញ្ចូលជាកម្មសិទ្ធិសមូហភាពដែរ[២៤]។ ចំណែកច្បាប់ភូមិបាលចែងថា ព្រំប្រទល់អចលនទ្រព្យរបស់សហគមន៍ជនជាតិដើមនឹងត្រូវកំណត់ទៅតាមស្ថានភាពជាក់ស្តែង។[២៥]

ច្បាប់ភូមិបាលឆ្នាំ២០០១ ចែងអំពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់ជនជាតិដើមភាគតិច ប៉ុន្តែរហូតដល់ឆ្នាំ២០០៩ ពុំមានការអនុម័តអនុក្រឹត្យដែលចាំបាច់សម្រាប់អនុវត្តច្បាប់នេះឡើយ ហើយមានមាត្រាជាច្រើនដែលច្របូកច្របល់ និងមានខ្លឹមសារផ្ទុយគ្នា។ អនុក្រឹត្យស្តីពីបែបបទសម្រាប់ការចុះបញ្ជីដីធ្លីជនជាតិដើមភាគតិច ត្រូវបានអនុម័តនៅក្នុងខែឧសភា ឆ្នាំ២០០៩ ប៉ុន្តែមុននឹងអាចចុះបញ្ជីដីធ្លីនោះបាន សហគមន៍ត្រូវតែចុះបញ្ជីជានីតិបុគ្គលពីសំណាក់ក្រសួងមហាផ្ទៃជាមុនមុននឹងអាចដាក់ពាក្យស្នើសុំ។[២៦] បញ្ហានេះកាន់តែច្របូកច្របល់ដោយសារក្រសួងមហាផ្ទៃនៅពុំទាន់បានអនុម័តក្របខ័ណ្ឌច្បាប់សម្រាប់ទទួលស្គាល់ និងចុះបញ្ជីសហគមន៍ជនជាតិដើមនៅឡើយទេ ហើយជាញឹកញាប់ តុលាការមិនដោះស្រាយករណីដែលទាក់ទងនឹងសិទ្ធិរបស់សហគមន៍ជនជាតិដើមឡើយ រហូតដល់ពួកគេបានចុះបញ្ជី។ ប្រការនេះធ្វើឲ្យដំណើរការនេះទាំងមូលជួបការលំបាក ហើយមកដល់ខែធ្នូ ឆ្នាំ២០១១ មានសហគមន៍ចំនួនបីដំបូងគេនៅខេត្តរតនគិរី និងមណ្ឌលគិរី

[២៣] សេចក្តីដកស្រង់ចេញពីឯកសារ The Rights of Indigenous Peoples in Cambodia, Feb 2010

[២៤] នៅក្រោមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ក្រសួងបរិស្ថានជាអ្នកកំណត់សហគមន៍តំបន់ការពារធម្មជាតិ។

[២៥] សេចក្តីដកស្រង់ចេញពីឯកសារ The Rights of Indigenous Peoples in Cambodia, Feb 2010

[២៦] មាត្រា ៣ នៃអនុក្រឹត្យស្តីពី នីតិវិធីសម្រាប់ការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិច។

ដែលបានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ពួកគេពីរដ្ឋាភិបាលខណៈ ដែលសហគមន៍ខ្លះរង់ចាំដល់រយៈពេលជិត៦ឆ្នាំ ឯណោះ។[២៧]

## ៥. លក្ខណៈភូមិសាស្ត្រ និងប្រជាជននៅតំបន់ព្រៃឡង់



ផែនទី ២: ទីតាំងតំបន់ព្រៃឡង់

មហាតំបន់ព្រៃឡង់ លាតសន្ធឹងនៅក្នុងខេត្តចំនួនបួន គឺ ក្រចេះ កំពង់ធំ ព្រះវិហារ និង ស្ទឹងត្រែង ហើយមានគេអធិប្បាយខុសៗគ្នាថា វាមានទំហំពី ៣៥០,០០០ហិកតា ដោយ EWMI ដល់ ៥២០,០០០ហិកតា នៅក្នុងរបាយការណ៍ថ្មីៗនេះ ស្តីពីរ៉េដនៃអង្គការអភិរក្សអន្តរជាតិ[២៨]។ នៅក្នុងតំបន់នេះ ភាគច្រើនជាកសិករតូចតាច និងសហគមន៍ដែលរស់នៅក្នុងព្រៃនិងពឹងផ្អែកលើព្រៃឈើសម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគេ។ សហគមន៍ទាំងនេះ រកអុស សម្ភារៈសាងសង់ រុក្ខជាតិឱសថ និងអាហារប្រចាំថ្ងៃភាគច្រើននៅក្នុងព្រៃ។ យោងតាមការសិក្សាផ្សេងៗ គ្រួសារនៅក្នុងព្រៃឡង់រហូតដល់៨០% ក៏ជាអ្នករក និងលក់ជ័រតាមទំរង់ផ្សេងៗគ្នា សម្រាប់ជាប្រភពចំណូលចំបងរបស់ពួកគេផងដែរ។[២៩] សហគមន៍នានា រួមមានអ្នកដែលរស់នៅដាច់ស្រយាលបំផុតនៅក្នុងប្រទេសអធិប្បាយថា មានបញ្ហា «លំបាក» ក្នុងការធ្វើដំណើរចូលទៅតំបន់ព្រៃឡង់ សូម្បីតែនៅពាក់កណ្តាលរដូវប្រាំងក៏ដោយ។

ប្រជាជនដែលរស់នៅក្នុងតំបន់ព្រៃឡង់ រួមមានជនជាតិដើមភាគតិចជាច្រើន

---

[២៧] ដកស្រង់ពីអង្គការអេដហុក http://www.phnompenhpost.com/index.php/2011121653455/National-news/indigenous-families-6-year-title-wait-ends.html

[២៨] REDD + in the Prey long Area - A feasibility study: March 2011, Conservation International.

[២៩] An Ecological Survey of Prey Long, McDonald, J.A. 2004 for Global Witness,

ដែលភាគច្រើនមកពីក្រុមជនជាតិដើមកួយ។ សម្រាប់ជនជាតិកួយ និងសហគមន៍ដទៃទៀតដែលរស់នៅក្នុងតំបន់ព្រៃឡង់ ព្រៃឡង់មិនត្រឹមតែផ្តល់ជាផលិតផលនានាសម្រាប់បំពេញតម្រូវការជាច្រើនប្រចាំថ្ងៃប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាផ្នែកសំខាន់នៃវប្បធម៌ និងជំនឿរបស់ពួកគេផងដែរ ដោយសហគមន៍ភាគច្រើនកំណត់ទុកដោយឡែកនូវ*តំបន់ព្រៃអ្នកតា*របស់ខ្លួន។ កសិកម្មចំការវិលជុំតាមប្រពៃណី ឬ«ចំការវិលជុំ» ត្រូវបានគ្រួសារនានាអនុវត្តជាទូទៅដោយរានឆ្ការតំបន់តូចៗនៅក្នុងព្រៃ ដើម្បីដាំស្រូវ និងបន្លែដទៃទៀត ដូចជាសណ្តែកសៀង ពោត។ ដោយសារតែដីមានគុណភាពទាបនៅទូទាំងតំបន់ព្រៃឡង់ គេអាចដាំដំណាំសម្រាប់រយៈពេលតែ២ ទៅ ៣ ឆ្នាំ នៅតាមទីតាំងណាមួយ ដោយពុំប្រើប្រាស់ជីគីមីដែលមានតម្លៃខ្ពស់។ បន្ទាប់មកគ្រួសារនានាបន្តទៅរកទីតាំងថ្មី និងទុកឲ្យព្រៃលូតលាស់ឡើងវិញ ជាពិសេសក្នុងរយៈពេល២០ឆ្នាំ មុននឹងពួកគេអាចវិលត្រឡប់មកដាំនៅលើចំណែកដីដដែលឡើងវិញ។ ការដាំដំណាំតាមប្រពៃណីបែបនេះត្រូវបានអនុវត្តជាច្រើនរយឆ្នាំមកហើយ បើទោះមិនដល់រាប់ពាន់ឆ្នាំក៏ដោយ ហើយត្រូវគេមើលឃើញថាមាននិរន្តរភាពរហូតដល់ពេលបច្ចុប្បន្ន ដែលមានកំណើននៃអ្នកមកពីខាងក្រៅដែលទន្ទ្រានចូលមកក្នុងព្រៃនេះ។

## ៦. ជីវៈចម្រុះ

### ៦ ១.ព្រៃឈើ

បច្ចុប្បន្ននេះ ព្រៃឡង់ជាតំបន់ធំជាងគេចុងក្រោយបង្អស់នៃទំនាបព្រៃស្រោងនៅក្នុងឧបទ្វីបភូមា និងឥណ្ឌូចិន។ ព្រៃឈើប្រភេទនេះ ត្រូវបានទទួលស្គាល់ថារងការគំរាមកំហែងនៅកម្រិតពិភពលោកនាពេលបច្ចុប្បន្ន។ ការអង្កេតភូតគ្រាមសាស្ត្រនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បានឲ្យដឹងអំពីសមាសភាពរុក្ខជាតិដ៏សំបូរបែប និងលក្ខណៈដោយឡែកនៅក្នុងតំបន់ព្រៃឡង់ ដែលយ៉ាងហោចណាស់មានព្រៃប្រាំពីរបែបខុសគ្នា។[៣០] ព្រៃទាំងនេះអាចចាត់ថ្នាក់ជាក្រុមធំៗគឺ ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះ។

---

[៣០] An Ecological Survey of Prey Long, Kampong Thom, McDonald, J.A. 2004 for Global Witness; REDD+ and Conservation of Prey Long Forest Cambodia – Summary of Scientific Findings, 2007-2010: Ida Theilade, Lars Schmidt.

**តារាងទី ៣: ប្រភេទព្រៃនៅតំបន់ព្រៃឡង់**

| ប្រភេទព្រៃ | សំណុំលក្ខណៈ |
|---|---|
| ព្រៃល្បោះ | ព្រៃប្រភេទនេះប្រហែលគ្នានឹងព្រៃស្ងួតប្រចាំរដូវដែលមាននៅតំបន់ស្ងួតក្នុងឥណ្ឌូចិន។ ដើមឈើមានកំពស់ទាប (៣-១២ម) ដែលភាគច្រើនជាប្រភេទដែលធន់ទ្រាំនឹងភាពរាំងស្ងួត ដោយមានស្លឹកតូចៗ និងសំបកក្រាស់។ ព្រៃល្បោះស្ងួតបង្កើតជាទ្រនាប់ជាប់ជាមួយវាលស្មៅធម្មជាតិ ដែលគេឃើញមាននៅតំបន់ស្ងួតសំបូរខ្សាច់។ |
| ព្រៃពាក់កណ្ដាលស្រោងតឿ | ព្រៃប្រភេទនេះជាទ្រនាប់នៃព្រៃស្រោងខ្ពស់និងច្រើនតែផ្សំដោយរុក្ខជាតិប្រភេទប្រហាក់ប្រហែលគ្នា ប៉ុន្តែដើមឈើមានទំហំតូចជាងច្រើន។ |
| ព្រៃ«ស្រឡៅ» (Lagerstroemia) | ព្រៃ*Lagerstroemia* មានលក្ខណៈខុសប្លែកពីគេដោយសារដើមឈើមានសំបកពណ៌ ស និងខ្ពស់ ដើមដុះត្រង់ទៅលើ មែករលូន។ ព្រៃប្រភេទនេះច្រើនតែមាននៅដុះជាឯកសណ្ឋានដោយកន្លែង។ |
| ព្រៃតឿតាមដងទន្លេ និងព្រៃស្នាច់ | ព្រៃឈើប្រភេទនេះមានដុះនៅជិតស្ទឹង និងទន្លេ និងលិចទឹកតាមរដូវ ហើយនៅតែសើមនៅក្នុងរដូវប្រាំង។ |
| ព្រៃល្បោះទីទំនាប | ប្រភេទព្រៃប្លែកពីគេមួយបែបដែលមាននៅម្ដុំបឹងប៉េសភាគខាងជើងនៃតំបន់ព្រៃឡង់។ ភាពប្លែកពីគេនៃប្រភេទឈើ និងទម្រង់នៃការដុះប្លែកពីគេមួយចំនួនត្រូវបានសង្កេតឃើញមាននៅក្នុងតំបន់ទំនាបដែលតាមធម្មតាពាក់ព័ន្ធជាមួយជំពូកព្រៃកោងកាង។ |
| ព្រៃស្រោង dipterocarp | ព្រៃប្រភេទនេះមាននៅតំបន់សើមប៉ុន្តែមិនជាំទឹក។ ព្រៃបែបនេះមានប្រភេទឈើប្លែកៗគ្នាជាច្រើន ដែលមានវិសាលភាពនៃគម្របព្រៃពី ៣០ ទៅ ៥០ម។ |
| ព្រៃស្រោងទីទំនាប | ព្រៃប្រភេទនេះមាននៅតាមតំបន់សើមខ្លាំង ដែលមានការជន់លិចជាប់ជាប្រចាំ ឬ រយៈពេលវែង។ ព្រៃប្រភេទនេះមានដោយកម្រ និងជាព្រៃដែលមានតែនៅកម្ពុជា។ |

សម្គាល់: ដកស្រង់ចេញពី MacDonald (2004): Olsson and Emmett (2007)

អ្វីដែលជាចំណាប់អារម្មណ៍បំផុតសម្រាប់អ្នកជំនាញការរុក្ខជាតិ គឺចំនួនតំបន់ព្រៃស្រោងក្នុងទីទំនាប ដែលមានលក្ខណៈដោយឡែកពុំមាននៅកន្លែងផ្សេងទៀត ដែលក្នុងនោះសំបូរដោយប្រភេទរុក្ខជាតិកម្រ ឬដែលពុំមាននៅកន្លែងដទៃ និងធ្វើឲ្យតំបន់ព្រៃឡង់មានសារៈសំខាន់នៅកម្រិតពិភពលោក។ បណ្ដុំព្រៃស្រោងតាមទីទំនាបទាំងនេះផ្ដល់ជាទីជម្រកសំបូរបែប ដែលអាចទ្រទ្រង់សត្វព្រៃជាច្រើនប្រភេទ។ បច្ចុប្បន្ននេះ ប្រភេទព្រៃកម្របែបនេះត្រូវបានរានឆ្ការនៅទូទាំងតំបន់នេះ សម្រាប់ការអភិវឌ្ឍកសិកម្ម និងការពង្រីកសកម្មភាពសង្គម។ ក្នុងន័យនេះ កិច្ចការពារព្រៃ

ឡង់នឹងផ្តល់ឱកាស សម្រាប់សហគមន៍អ្នកវិទ្យាសាស្ត្រ ដើម្បីធ្វើការសិក្សាស្រាវជ្រាវអំពីរុក្ខជាតិ និងសត្វក្នុងព្រៃស្ដុកបែបនេះ ហើយវាអាចមានសក្ដានុពលផ្ដល់នូវរបកគំហើញសំខាន់ៗ ដែលអាចនឹងត្រូវបាត់បង់។[៣១]




ផែនទី៣: ផែនទីបង្ហាញព្រៃស្រោងសំខាន់ៗនៅតំបន់ព្រៃឡង់ និងទីតាំងតំបន់ស្នូល (ប្រភព: EWMI)

ផ្អែកតាមទស្សនៈវិស័យរបស់ជាតិ ព្រៃឡង់គឺជាកន្លែងដែលមានប្រភេទឈើ៨០% ជាប្រភេទឈើមានតម្លៃបំផុត និងប្រភេទឈើក្នុងស្រុកដែលជិតផុតពូជ នៅក្នុងប្រទេសកម្ពុជា (CTSP, 2003)។ ក្នុងចំណោមឈើ២០ប្រភេទ ដែលមានការទទួលស្គាល់ថាជា «ឈើដែលមានអាទិភាពខ្ពស់» នៅក្នុងគម្រោងពូជឈើនៅកម្ពុជា មានឈើចំនួន១៥ប្រភេទ ត្រូវបានរកឃើញថាមាននៅក្នុងតំបន់ព្រៃឡង់។ ប្រភេទទាំងនោះ រាប់បញ្ចូលទាំងប្រភេទឈើដែលមានតម្លៃខ្ពស់បំផុតនៅអាស៊ីដែលចាត់ជាអាទិភាពខ្ពស់បំផុត ដោយសារវាមានដើមត្រង់ ដូចជា បេង និងឈើក្រញូង។ ដោយសារតែការបាត់បង់ឈើទាំងនេះនៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ និងតំបន់ដទៃទៀត ថ្មីៗនេះថ្លៃឈើក្រញូងបានកើនឡើង។ នៅចុងឆ្នាំ២០១១ ថ្លៃឈើក្រញូងក្នុងមួយម៉ែត្រគូបនៅប្រទេសវៀតណាម មានតម្លៃពី ៧,០០០ ដល់ ១០,០០០ដុល្លារអាមេរិក។[៣២] ដើមឈើគ្រញូងដែលគេសង្កេតឃើញនៅក្នុងការអង្កេតភូតគ្រាម

---

[៣១] REDD+ and Conservation of Prey Long Forest Cambodia – Summary of Scientific Findings, 2007-2010: Ida Theilade, Lars Schmidt.

[៣២] តួលេខនេះបានមកពីលោក ឈុត វុទ្ធី នៃអង្គការការពារធនធានធម្មជាតិ **(NRPG)** និងត្រូវបានលើកយកមកពិភាក្សាក្នុង ចំណោមអ្នកធ្វើការខាងអភិរក្សនៅកម្ពុជា។

សាស្រ្តរយៈពេល១០ថ្ងៃ នៅតំបន់ស្នូលនៃព្រៃឡង់កាលពី ខែមេសា ឆ្នាំ ២០១១ មានទំហំតូចៗតែប៉ុណ្ណោះ ដោយសារតែអ្នកកាប់ឈើល្មើសច្បាប់បានជ្រើសយកឈើដែលមានតម្លៃអស់ទៅហើយ។ ចំពោះប្រភេទឈើដទៃទៀតដែលមានតម្លៃប្រហាក់ប្រហែលបង្ហាញយ៉ាងច្បាស់ថា ចំនួនដើមឈើជាច្រើនប្រភេទនោះស្ថិតក្រោមសម្ពាធធ្ងន់ធ្ងររួចទៅហើយ។ ការបញ្ឈប់នូវរាល់ការបំផ្លិចបំផ្លាញក្នុងតំបន់ព្រៃឡង់គឺត្រូវការវិធានការជាបន្ទាន់។

សៀវភៅបញ្ជីរុក្ខជាតិឱសថកម្ពុជា បង្ហាញពីប្រភេទរុក្ខជាតិឱសថច្រើនជាង ១,០០០ប្រភេទ ដែលភាគច្រើនមាននៅក្នុងតំបន់ព្រៃឡង់។ ក្នុងចំណោមរុក្ខជាតិទាំងនេះមានតែមួយចំនួនតូចប៉ុណ្ណោះ ដែលអ្នកវិទ្យាសាស្រ្តបានកំណត់អត្តសញ្ញាណ ដូច្នេះ គេនៅពុំទាន់បានដឹងពិស្តារអំពីលក្ខណៈសម្បត្តិខាងវេជ្ជសាស្រ្តនៃប្រភេទរុក្ខជាតិទាំងនោះនៅឡើយទេ ហើយនៅក្នុងបេសកកម្មថ្មីៗនេះ អ្នកជំនាញរុក្ខវិទ្យារំពឹងថា ប្រសិនបើមានការអង្កេតបានទូលំទូលាយនៅក្នុងតំបន់ព្រៃឡង់គេអាចនឹងរកឃើញប្រភេទរុក្ខជាតិថ្មីៗជាបន្ថែមទៀត ដែលពុំធ្លាប់បានកំណត់អត្តសញ្ញាណពីមុនមក។

## ៦.២ សត្វព្រៃ

ព្រៃឡង់គឺជាជម្រកនៃសត្វជាច្រើនប្រភេទ រួមទាំងសត្វជាច្រើនដែលរងការគំរាមកំហែងជាសកលផងដែរ។ ក្នុងចំណោមថនិកសត្វ សត្វដំរី ខ្លាឃ្មុំតូច ទន្សោងពង្រូល និងទោចម្កុដ គឺជាចំណាប់អារម្មណ៍នៃអ្នកអភិរក្ស ដោយសារមានប្រភេទសត្វមួយចំនួនដូចជា អណ្តើកបិទមុខស្នូកខ្មៅ អណ្តើកសោមឈ្មោល និងអណ្តើកព្រិចផងដែរ ជាប្រភេទសត្វជិតផុតពូជបំផុត។ មកទល់ពេលនេះ ការអង្កេតសត្វព្រៃបានធ្វើឡើងក្នុងកម្រិតកំណត់តែប៉ុណ្ណោះ ដោយអង្គការអភិរក្សអន្តរជាតិបានធ្វើការអង្កេតដោយការដាក់ម៉ាស៊ីនថតរូប និងការអង្កេតនៅតាមព្រៃក្នុងទីទំនាប។ យោងតាមរបាយការណ៍នានាពីប្រជាពលរដ្ឋនៅមូលដ្ឋាន មានសត្វក្រពើត្រីមួយចំនួនតូចដែលជិតផុតពូជបំផុតត្រូវបានរកឃើញនៅក្នុងទីកន្លែងដាច់ស្រយាលខ្លះៗ នៅក្នុង

ព្រៃតាមទីទំនាប។ សត្វប្រភេទផ្សេងទៀតដែលមានសារៈសំខាន់ផងដែរនោះរួមមាន ឆ្កែព្រៃ ពពួកសត្វប្រើសជាច្រើនប្រភេទ និងពពួកសត្វខ្លា ដូចជា ខ្លាពពក ខ្លាភ្លើថ្មកែវ ខ្លារខិន និងខ្លាត្រី។[៣៣]

មកទល់ពេលថ្មីៗនេះ គេឃើញមានពពួកសត្វស្វាក្តាមជាច្រើននៅក្នុងតំបន់ព្រៃឡង់។ ប៉ុន្តែយោងតាមប្រជាពលរដ្ឋមូលដ្ឋាន ការលួចចាប់សត្វជាទ្រង់ទ្រាយធំ បាននាំឲ្យសត្វប្រភេទនេះជាច្រើនពាន់ក្បាលបាត់បង់ពីភាគកណ្តាល និងភាគខាងកើតនៃតំបន់ព្រៃឡង់នៅក្នុងឆ្នាំ២០០៦។ គេជឿថា សត្វទាំងនោះបន្ទាប់មកត្រូវគេលក់ទៅក្នុងទីផ្សារអន្តរជាតិសម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រ និងការសាកល្បងនានា ហើយភាគច្រើនត្រូវគេលក់ទៅឲ្យមន្ទីរពិសោធន៍នៅចិន និងអាមេរិក។[៣៤] បច្ចុប្បន្ននេះ គេកម្រឃើញសត្វប្រភេទនេះណាស់នៅក្នុងតំបន់ព្រៃឡង់ ហើយតាមពិតទៅសត្វទាំងនេះអាចផុតពូជពីក្នុងតំបន់នេះទៅហើយ។ គេអាចនៅឮសម្រែកសត្វទោចម្កុដដែលជាពពួកសត្វចូលចិត្តរស់នៅដាច់ឆ្ងាយពីគេ ក្នុងតំបន់ព្រៃឡង់ ប៉ុន្តែសត្វប្រភេទផ្សេងទៀតទាំងអស់ក្នុងអំបូរនេះ ត្រូវបានកត់សម្គាល់ថាបាត់ពីតំបន់នេះទៅហើយ។ ទាក់ទងនឹងប្រភេទសត្វស្លាប ព្រៃឡង់គឺជាជម្រកសម្រាប់សត្វត្រយ៉ងយក្សដែលជាសត្វលាក់មុខ និងជាសត្វនិម្មិតរូបរបស់កម្ពុជា។ សត្វត្រយ៉ងយក្សគឺជាសត្វកម្រជាងគេបំផុតមួយលើពិភពលោក ដោយលើពិភពលោកទាំងមូលនៅមានសល់ត្រឹមតែចំនួន២០០ក្បាល ប៉ុណ្ណោះ[៣៥] សត្វទាំងអស់នេះមានរស់នៅភាគឧត្តរ និងបូព៌ានៃប្រទេសកម្ពុជា។ ដោយសារវាជាសត្វដែលត្រូវការទីជម្រកជាក់លាក់បំផុតទើបអាចរស់នៅបាន សត្វស្លាបដ៏អស្ចារ្យនេះកំពុងស្ថិតក្រោមសម្ពាធកាន់តែធ្ងន់ធ្ងរពីការអភិវឌ្ឍនៅប្រទេសកម្ពុជា ជាពិសេសនៅតំបន់ខ្ពង់រាបខាងជើងនៃខេត្ត

---

[៣៣] A Floral and Faunal Biodiversity Assessment of Prey Long: November 2007, Annette Olsson & David Emmett, Conservation International, Forest & Landscape, University of Copenhagen, Forestry Administration.

[៣៤] http://www.reuters.com/article/2008/11/23/us-cambodia-monkeys-idUSTRE4AM0TC20081123 Article regarding a report from the British Union for the Abolition of Vivisection (BUAV)

[៣៥] http://birdlifeindochina.org/content/western-siem-pang-land-giants

ព្រះវិហារ។ មានទិន្នន័យតិចតួចប៉ុណ្ណោះ អំពីសត្វស្លាបនៅតំបន់ព្រៃឡង់ដែលរួមទាំងសត្វស្លាបទឹកធំៗប្រភេទផ្សេងទៀតដែលមានសារៈសំខាន់ផងដែរ ដូចជាសត្វកសត្រដក់ធំ និងត្រដក់តូច និងសត្វក្ងោកដ៏ឆើតឆាយ។

គេមិនបានយល់ដឹងពេញលេញ អំពីឥទ្ធិពលនៃការបរបាញ់ជាលក្ខណៈប្រពៃណីពីសំណាក់សហគមន៍នានាដែលរស់នៅតាមដងព្រៃ ក្នុងប្រទេសកម្ពុជាឡើយ។ ជាការច្បាស់ណាស់ថា ការបរបាញ់បែបនេះបានធ្វើឡើងជាច្រើនជំនាន់រួចមកហើយ ប៉ុន្តែពពួកសត្វស្លាបព្រៃភាគច្រើននៅតែមានស្ថិរភាពជាបង្គួររហូតមកទល់ពេលថ្មីៗនេះ។ បច្ចុប្បន្ននេះ ការកែលម្អផ្លូវចេញចូល ការមកដល់នៃជនចំណាកស្រុក និងការកាប់ឈើល្មើសច្បាប់ ពិតជាមានឥទ្ធិពលដ៏មហន្តរាយមកលើពពួកសត្វព្រៃ។ ជាញឹកញាប់ អ្នកកាប់ឈើចំណាយពេលជាច្រើនសប្តាហ៍ក្នុងមួយលើកៗស្នាក់នៅក្នុងព្រៃ ហើយតាមធម្មតាពួកគេអាចរស់នៅបានអាស្រ័យដោយការដាក់អន្ទាក់ដើម្បីចាប់សត្វជាអាហារ។ គ្រួសារចំណាកស្រុកតែងតែបរបាញ់ ឬដាក់អន្ទាក់ចាប់សត្វ ដើម្បីបំពេញបន្ថែមលើចំណីអាហាររបស់ពួកគេនៅក្នុងរយៈពេលប៉ុន្មានខែដំបូង ឬរហូតដល់ឆ្នាំផងដែរ ក្នុងពេលដែលពួកគេមកតាំងទីលំនៅក្នុងតំបន់ណាមួយ។ ការបន្តទន្ទ្រាននៅជុំវិញតំបន់ព្រៃឡង់ អាចបង្កឲ្យមានបញ្ហាដែលផលដំណាំរបស់ពួកគេត្រូវបំផ្លាញពីសំណាក់សត្វដំរី ឬសត្វព្រៃដទៃទៀត ដូចដែលធ្លាប់បានកើតឡើងនៅក្នុងតំបន់បាត់បង់ព្រៃឈើតាមកន្លែងផ្សេងទៀត ក្នុងប្រទេសកម្ពុជាផងដែរ។[៣៦]

## ៧. សេវាកម្មប្រព័ន្ធអេកូឡូស៊ី

ដោយស្ថិតនៅចំកណ្តាលនៃផ្ទៃប្រទេសកម្ពុជា តំបន់ព្រៃឡង់ផ្តល់សេវាកម្មប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ សម្រាប់តំបន់នានាជាច្រើនក្នុងប្រទេសកម្ពុជា។ បណ្តាញព្រៃឈើបែបនេះ គឺជាទីជម្រាលដ៏មានសារៈសំខាន់បំផុតមួយរបស់កម្ពុជាដែលជួយធ្វើនិយ័តកម្មការផ្គត់ផ្គង់ទឹកដល់ទីក្រុងធំជាងគេចំនួនពីរនៃប្រទេសនេះ ពោលគឺ

---

[៣៦] WCS report on Human-Wildlife Conflict in and Around Seima Biodiversity Area, Mondulkiri and Kratie Provinces, Cambodia. Kara Scally, Tom D. Evans and Nut Meng Hor. 2007

ខេត្តកំពង់ធំ និងកំពង់ចាម។ លើសពីនេះ ព្រៃឈើនេះជួយកាត់បន្ថយទឹកជំនន់ និងគ្រោះរាំងស្ងួត ដោយធ្វើឲ្យមានទឹកហូរគ្រប់រដូវទៅទន្លេមេគង្គ និងបឹងទន្លេសាប។ តំបន់ព្រៃឡង់ក៏មានតួនាទីជាតម្រងធម្មជាតិ ដែលធ្វើនិយ័តកម្មកំណកល្បាប់នៅតំបន់ខ្សែទឹកខាងក្រោម និងជាតំបន់ដ៏សំខាន់សម្រាប់ត្រីពងកូនផងដែរ។[៣៧]

របាយការណ៍ថ្មីមួយរបស់ USAID បានពិភាក្សាអំពីការបន្តបាត់បង់ព្រៃឈើនៅតំបន់ព្រៃឡង់ដែលទំនងជានឹងមានឥទ្ធិពលមកលើរបបជលសាស្ត្រ។[៣៨] អនុសាសន៍នៅក្នុងរបាយការណ៍នេះគឺជាអភិក្រមដែលមានតុល្យភាពមួយ សម្រាប់ការអភិវឌ្ឍណាមួយទៅអនាគតនៅតំបន់ព្រៃឡង់ និងការពិចារណាដោយប្រុងប្រយ័ត្ន ដើម្បីឲ្យមានការអភិរក្ស ដើម្បីធានាថា របបជលសាស្ត្រធម្មជាតិ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីមិនរងឥទ្ធិពលអវិជ្ជមានឡើយ។ របាយការណ៍នោះបានរកឃើញថា ប្រសិនបើលំនាំនៃកំណើនការអភិវឌ្ឍកើតមានជាបន្តដូចបច្ចុប្បន្ននេះ គេអាចទទួលបាននូវផលចំណេញខាងសេដ្ឋកិច្ច និងសង្គម សម្រាប់រយៈពេលខ្លី ប៉ុន្តែវានឹងនាំឲ្យមានការខូចខាតធ្ងន់ធ្ងរសម្រាប់ប្រទេសនៅក្នុងរយៈពេលវែង ដោយសារតែឥទ្ធិពលមកលើរបបជលសាស្ត្រនៅក្នុងតំបន់នេះ។ ផ្ទុយពីផលប្រយោជន៍សម្រាប់រយៈពេលខ្លី ប្រទេសកម្ពុជានឹងជួបប្រទះកំណើននៃកំទេចកំណក និងការបាត់បង់សារធាតុចិញ្ចឹម ការថយចុះនៃសមត្ថភាពទប់ស្កាត់ទឹកជំនន់ និងគ្រោះរាំងស្ងួត ក៏ដូចជាការថយចុះយ៉ាងខ្លាំងនៃជីវៈចម្រុះ ធនធានជលផល និងសមត្ថភាពស្រូបយកកាបូនផងដែរ។ ដូចជាព្រៃឈើផងដែរ ទីជម្រាលមិនងាយនឹងស្តារឡើងវិញបានឡើយ ដូច្នេះ រាល់ការអភិវឌ្ឍណាមួយជាបន្ត ត្រូវមានការប៉ាន់ប្រមាណដោយប្រុងប្រយ័ត្នអំពីឥទ្ធិពលដែលអាចកើតមានឡើងមកលើទីជម្រាលនៃតំបន់ព្រៃឡង់។

---

[៣៧] REDD+ and Conservation of Prey Long Forest Cambodia – Summary of Scientific Findings, 2007-2010: Ida Theilade, Lars Schmidt.

[៣៨] USAID report 'Rapid Socio Economic Hydrology Assessment of Prey Long Forest' published in 2011

បន្ថែមពីនេះ វាត្រូវបានគេកត់សម្គាល់នៅក្នុង «ហេដ្ឋារចនាសម្ព័ន្ធ និងការនេសាទត្រីបឹងទន្លេសាប» ថ្មីៗនេះ ដោយមជ្ឈមណ្ឌលត្រីពិភពលោក[៣៩] ថាទំនប់ជាច្រើន ដូចជាទំនប់មួយដែលគ្រោងនឹងធ្វើនៅស្ទឹងសែននឹងមានផលប៉ះពាល់ដល់ទន្លេសាបតាមរយៈការកាត់បន្ថយលំហូរទឹកនៅរដូវប្រាំងរហូតដល់២៥% មានបម្រែបម្រួលទឹកជំនន់ធម្មជាតិជាប្រចាំនៃបឹង បង្កអោយទឹកជំនន់កើតឡើងយឺតពេលមួយខែ និងកាត់បន្ថយទឹកជំនន់នៅកន្លែងដទៃទៀត។ របាយការណ៍ក៏បានកត់សម្គាល់ផងដែរថា ទំនប់នានាសុទ្ធតែមានប្រវត្តិបង្កផលប៉ះពាល់ដល់គុណភាពទឹក ជាពិសេស បាត់បង់អុកស៊ីសែន និងលំហូរទឹកដែលបង្កអោយមានឥទ្ធិពលអវិជ្ជមានដល់ពងត្រី។ កាន់តែសំខាន់ កាកសំណល់ដ៏ច្រើនលើសលប់នឹងត្រូវជាប់នៅទំនប់ទាំងនេះដែលត្រូវបានគេរំពឹងថាកាត់បន្ថយគុណភាពទឹកជាទូទៅ និងបណ្តាលអោយមានការធ្លាក់ចុះនូវទិន្នផលត្រី។

## ៨. សម្រួបកាបូន/រ៉េដបូក

រដ្ឋាភិបាលកម្ពុជា គ្រោងប្រើប្រាស់ព្រៃឈើខ្លះៗរបស់ខ្លួនដើម្បីទទួលបានហិរញ្ញវត្ថុអន្តរជាតិ ដែលគេរំពឹងថានឹងអាចទទួលបាន តាមរយៈឥណទានកាបូនក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។ សម្រួបកាបូន ដើរតួយ៉ាងសំខាន់នៅក្នុងកម្មវិធីព្រៃឈើជាតិឆ្នាំ ២០១០ របស់រដ្ឋបាលព្រៃឈើ ជាមួយផែនការដើម្បីប្រើប្រាស់យន្តការរ៉េដបូក (កាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ) សម្រាប់ជាការជំនួសឲ្យការអភិវឌ្ឍហួសកម្រិតនៃសម្បត្តិព្រៃឈើជាតិ។[៤០]

ទោះបីនៅមានចំណោទជាច្រើននៅឡើយ អំពីថាតើរ៉េដបូកមានប្រសិទ្ធភាពបែបណាក្នុងការកាត់បន្ថយការបំភាយឧស្ម័នជាសកលក៏ដោយ តែវាពិតជាមានសក្តានុពល សម្រាប់ការពារតំបន់សំខាន់ៗនៃព្រៃឈើនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍

---

[៣៩] http://www.worldfishcenter.org/resource_centre/Infrastructure%20and%20Tonle%20Sap%20Fisheries%20-%20English.pdf

[៤០] National Forest Programme 2010-2029 and associated “Background Document”: Forestry Administration, Ministry of Agriculture Forests and Fisheries, Royal Government of Cambodia.

ដូចកម្ពុជា។ តាមរយៈជំនួយពី RECOFTC, សាកលវិទ្យាល័យកូប៉េនហាក់ និង អង្គការអភិរក្សអន្តរជាតិ រដ្ឋបាលព្រៃឈើបានធ្វើការប៉ាន់ប្រមាណដំបូងមួយរួចមក ហើយសម្រាប់ការអនុវត្តគម្រោងរ៉េដ នៅក្នុងតំបន់ព្រៃឡង់។ សេចក្ដីសន្និដ្ឋានគឺព្រៃ ឡង់គឺជាកន្លែងដ៏ប្រសើរសម្រាប់អនុវត្តគម្រោងរ៉េដ។[៤១] កិច្ចការនេះ មួយផ្នែកបាន ធ្វើឡើងដោយសារតែបរិមាណកាបូនក្នុងអត្រាខ្ពស់ ដែលមាននៅក្នុងអំពុករុក្ខជាតិ នៅក្នុងព្រៃតាមទីទំនាបដែលមានកាបូនរហូតដល់ប្រមាណ ៣០% ច្រើនជាងព្រៃ ស្រោងធម្មតា និងច្រើនជាងបីដងធៀបនឹងសមត្ថភាពដែលចំការកៅស៊ូអាចស្រូប យកកាបូន។ បញ្ហាដទៃផ្សេងទៀតដែលបានលើកយកមកពិចារណាផងដែរគឺគុណ តម្លៃខ្ពស់នៃព្រៃឈើដែលទាក់ទងនឹងផលប៉ះពាល់សង្គម ដោយសារតែសហគមន៍ ជាច្រើនពឹងផ្អែកលើព្រៃឈើសម្រាប់ការរស់នៅរបស់ពួកគេ។ ពិតណាស់ ប្រសិនបើ គម្រោងរ៉េដមួយត្រូវបានគេអនុវត្តនៅក្នុងតំបន់ព្រៃឡង់ វានឹងអាចផ្ដល់ប្រយោជន៍ សម្រាប់កិច្ចប្រឹងប្រែងនានាដើម្បីការពារព្រៃឈើនេះ ហើយថែមទាំងអាចជួយសហ គមន៍ដែលពឹងផ្អែកលើព្រៃឈើនេះផងដែរ។

បញ្ហាជាមួយរ៉េដនៅកម្ពុជាគឺ «ការលេចធ្លាយ» ទាំងនៅក្នុងមូលដ្ឋាន និងនៅ ថ្នាក់ជាតិ។[៤២] ខណៈដែលរដ្ឋបាលព្រៃឈើប្រឹងប្រែងបង្កើតគម្រោងរ៉េដ ក្រសួងដទៃ ទៀត អាចមានសក្ដានុពលសម្រេចចិត្តដើម្បីអភិវឌ្ឍន៍ដីធ្លីជំនួសវិញ។ គម្រោងសាក ល្បងដែលកំពុងអនុវត្តនៅក្នុងខេត្តមណ្ឌលគិរី បានប្រឈមនឹងបញ្ហានេះរួចទៅ ហើយជាមួយវត្តមានអាជ្ញាប័ណ្ណរុករករ៉ែមួយចំនួនដែលបានផ្ដល់ សម្រាប់ប្រតិបត្តិ

---

[៤១] REDD+ and Conservation of Prey Long Forest Cambodia – Summary of Scientific Findings 2007-2010 by Ida Theilade & Lars Schmidt.

[៤២] ការលេចធ្លាយ គឺជាពាក្យដែលប្រើប្រាស់សំដៅលើការបាត់បង់ព្រៃឈើ ដែលអាចកើតឡើងនៅតំបន់ដទៃទៀត ប្រសិនបើការកាប់ព្រៃឈើនៅតំបន់នោះត្រូវបានលុបបំបាត់ ដែលជះឥទ្ធិពលដល់ការអនុវត្តកម្មវិធីរ៉េដក្នុងការកាត់ បន្ថយការបំភាយកាបូនលើពិភពលោក មិនមានប្រសិទ្ធភាព។ *ឧទាហរណ៍៖ ការផ្លាស់ទីកន្លែងនៃការកាប់ឈើពី "តំបន់ ក" ទៅ "តំបន់ ខ" ដោយសារ"តំបន់ ក" មានការអភិរក្សព្រៃឈើ*។

ការនៅក្នុងតំបន់សីម៉ា។[៤៣] ដូចដែលបានកត់សម្គាល់នៅក្នុងជំពូក ស្តីពីដីសម្បទានសេដ្ឋកិច្ច (ប្រអប់១) រដ្ឋាភិបាលបានប្រកាសរួចមកហើយនូវផ្ទៃដីជាច្រើនរយពាន់ហិកតា ជាដីសម្បទាននៅក្នុងអតីតតំបន់ការពារធម្មជាតិ។ នៅក្នុងពេលនេះគេមិនដឹងច្បាស់ទេថាមានផលប្រយោជន៍ត្រូតគ្នាប៉ុន្មានដែលរដ្ឋាភិបាលត្រូវដោះស្រាយ។ ប៉ុន្តែ ដោយហេតុថាមានព្រៃឈើជាច្រើនត្រូវបានលក់ទៅហើយ ដែលទំនងជាមានការពិគ្រោះយោបល់តិចតួច ឬគ្មានការពិគ្រោះយោបល់រវាងក្រសួងពាក់ព័ន្ធនានា គេអាចជជែកវែកញែកបានថាតើទីផ្សារកាបូនអាចមើលឃើញកម្ពុជា ថាជាកន្លែងវិនិយោគដ៏ល្អ ឬមានសុវត្ថិភាពដែរឬទេ។

## ៩. សំណើកំណត់តំបន់ព្រៃការពាររបស់រដ្ឋបាលព្រៃឈើ

បញ្ហាសំខាន់ជាងគេបំផុតមួយដែលត្រូវដោះស្រាយ ទាក់ទងនឹងតំបន់ព្រៃឡង់គឺការកំណត់លើផែនទី និងការឯកភាពគ្នាអំពីព្រំប្រទល់ជាក់លាក់នៃព្រៃឡង់។ មានផែនទីខុសៗគ្នាជាច្រើនអំពីព្រៃឡង់ដែលផលិតដោយអ្នកស្រាវជ្រាវ អ្នកអភិរក្ស និងអង្គការមិនមែនរដ្ឋាភិបាលនានា។ ប៉ុន្តែ មកទល់ពេលនេះស្ថាប័នរដ្ឋាភិបាលពុំដែលបានផ្តល់ផែនទីណាមួយឡើយ ដែលធ្វើឲ្យទំនាស់ទាក់ទងនឹងព្រៃឡង់ពិបាកដោះស្រាយបំផុត។ ការឆ្លើយតបរបស់រដ្ឋាភិបាលទៅនឹងសំណួរនានាមកពីអ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ២០០៩ ច្រើនតែជាការអះអាងថា សហគមន៍កំពុងរងផលប៉ះពាល់អវិជ្ជមានដោយសារដីសម្បទានសេដ្ឋកិច្ច ឬការអភិវឌ្ឍផ្សេងទៀត មិនស្ថិតនៅក្នុងតំបន់ព្រៃឡង់ឡើយ។ អំណះអំណាងនេះក៏តែងតែត្រូវបានប្រើប្រាស់ផងដែរ នៅក្នុងការឆ្លើយតបទៅនឹងការតវ៉ារបស់អង្គការមិនមែនរដ្ឋាភិបាល និងក្រុមសហគមន៍។ ការស្នើសុំទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលនូវច្បាប់ចម្លងនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងកិច្ចព្រមព្រៀងសម្បទានសម្រាប់អាជីវកម្មរ៉ែ នៅក្នុងតំបន់ព្រៃឡង់ ក៏បានទទួលការឆ្លើយតបដូចគ្នានេះដែរ តាមរយៈទូរស័ព្ទថា «ក្រសួងឧស្សាហកម្ម រ៉ែ និង

---

[៤៣] ផែនទីរបស់លីកាដូ ថ្ងៃទី ០២ ខែធ្នូ ឆ្នាំ ២០១១ ដែលមានប្រើប្រាស់នៅក្នុងអត្ថបទក្នុងសារព័ត៌មានកាំបូឌាដេលី ក្រោមចំណងជើងថា "ការអង្គន់ប្រទេសកម្ពុជា" ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១២។

ថាមពលមិនបានផ្តល់សម្បទានណាមួយនៅក្នុងតំបន់ព្រៃឡង់ឡើយ»។ ការសុំសម្ភាសជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក៏ត្រូវបានបដិសេធដោយសារតែហេតុផលដូចគ្នានេះផងដែរ។

នៅខែធ្នូ ឆ្នាំ២០១១ រដ្ឋបាលព្រៃឈើបានចេញសេចក្តីព្រាងអនុក្រឹត្យមួយស្តីពីកិច្ចការពារព្រៃឡង់ និងតំបន់អភិរក្សជីវៈចម្រុះ ដែលរួមទាំងកូអរដោនេសម្រាប់ទីតាំងនោះផងដែរ ដែលមានលក្ខណៈប្រហាក់ប្រហែលជាមួយផែនទីដែលបានឃើញពីលើកមុន។ យោងតាមប្រភពមួយនៅក្នុងរដ្ឋបាលព្រៃឈើដែលសុំមិនឲ្យបញ្ចេញឈ្មោះកាលពីចុងឆ្នាំ២០១១ បច្ចុប្បន្ននេះ រដ្ឋបាលព្រៃឈើកំពុងធ្វើការអង្កេតពិស្តារមួយអំពីតំបន់ព្រៃឡង់ក្នុងគោលបំណងលើកស្នើជាតំបន់ព្រៃការពារ។ ការអង្កេតនេះត្រូវបានរំពឹងថានឹងអនុវត្តរួចរាល់នៅខែមីនា ឆ្នាំ២០១២ ហើយផែនទីដែលរួចរាល់ជាស្ថាពរបានរំពឹងថាអាចដាក់ជូនទៅរដ្ឋមន្ត្រីនៅខែ កក្កដា ឆ្នាំ២០១២។ ប្រភពនេះគូសបញ្ជាក់ថា ផែនទីនេះគ្រាន់តែជា «ចំណុចចាប់ផ្តើម» តែប៉ុណ្ណោះ និងមិនអាចចាត់ទុកថាជាការកំណត់ព្រំប្រទល់ជាផ្លូវការដោយរដ្ឋាភិបាល សម្រាប់តំបន់ព្រៃឡង់ឡើយ។

ផែនទីនេះ រួមមានតំបន់ធំមួយនៅភាគខាងជើងដែលជាទូទៅមិនត្រូវបានចាត់ទុកថាជាផ្នែកមួយនៃតំបន់ព្រៃឡង់ឡើយ។ ប្រភពដដែលបានពន្យល់ថា នេះក៏ដោយសារ នៅពេលដែលមានការលើកស្នើតំបន់នេះជាលើកដំបូង តាមធម្មតា នៅចុងដំណើរការនេះនឹងត្រូវបានកាត់បន្ថយពី៣០% ទៅ៥០% ហើយផ្នែកនេះទំនងជានឹងត្រូវកាត់ចេញ។ ផែនទីនេះមិនរាប់បញ្ចូលនូវទីតាំងដីសម្បទានសេដ្ឋកិច្ច *ទាំងអស់* ដែលគេបានស្គាល់ឡើយ រួមទាំងសម្បទានដែលមានភាពចម្រូងចម្រាស់បំផុតក្នុងស្រុកសណ្តាន់ និងរវៀង និងតំបន់នៅជុំវិញទំរីងរហូតដល់ភាគនិរតីនៃព្រៃនេះ ដែលជាប្រការគួរឲ្យព្រួយបារម្ភបំផុត ដោយសារវាមិនទំនងជារាប់បញ្ចូលផ្នែកយ៉ាងធំមួយនៃទីជម្រាលធម្មជាតិនេះឡើយ។ ការកំណត់របស់រដ្ឋបាលព្រៃឈើពិតជាបានរួមបញ្ចូលតំបន់ភាគច្រើនបំផុតដែលសំបូរជីវចម្រុះ និងតំបន់អេកូឡូស៊ីសំខាន់ៗនៃតំបន់ព្រៃឡង់ដូចដែលបានផ្តល់យោបល់ពីការអង្កេតភូតគ្រាម និងជីវៈចម្រុះដែលបានធ្វើឡើងដោយរដ្ឋបាលព្រៃឈើ និងក្រុមហ៊ុនហ្វ័ររេស&ឡែនស្កេបនៃប្រទេសដា

ណីម៉ាក់ រួមជាមួយរដ្ឋបាលព្រៃឈើ និងអង្គការអភិរក្សអន្តរជាតិ។[៤៤] ដូចដែលបានបង្ហាញនៅក្នុងផែនទី៤ វាគឺជាទីតាំងប្រហាក់ប្រហែលមួយនៃតំបន់ស្នូលជីវៈចម្រុះ ចំណែកព្រៃស្រោងដែលបានគូសបញ្ជាក់ តំណាងឲ្យតំបន់មួយដែលបានវិភាគសម្រាប់របាយការណ៍របស់អង្គការអភិរក្សអន្តរជាតិនៅឆ្នាំ២០១១ ស្តីពីរ៉េដបូកនៅក្នុងតំបន់ព្រៃឡង់។[៤៥] តំបន់ដែលបានលើកស្នើនេះ ក៏ផ្តល់កិច្ចការពារសំខាន់សម្រាប់ទីជម្រាលស្ទឹងជីនិតដែលហូរទៅភាគខាងត្បូងនៃតំបន់ព្រៃឡង់ដែរ។[៤៦]

---

[៤៤] REDD+ & Conservation of Prey Long Forest Cambodia - 2007-2010, by Ida Theilade & Lars Schmidt.

[៤៥] REDD+ in the Prey Long Area – A feasibility study (preliminary results. March 2011.

[៤៦] សូមអានរបាយការណ៍ USAid 'Rapid Socio Economic Hydrology Assessment of Prey Long Forest' published in 2011 for maps the watersheds and drainage of Prey Lang.




ផែនទី៤: សម្រង់ចំណុចចាប់ផ្តើមដែលរដ្ឋបាលព្រៃឈើបានលើកស្នើសម្រាប់ជាតំបន់ព្រៃការពារ នៅក្នុងតំបន់ព្រៃឡង់

# ១០. ការគំរាមកំហែង

## ១០.១ ដីសម្បទានសេដ្ឋកិច្ច

រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណដីសម្បទានសេដ្ឋកិច្ច និងសម្បទានអាជីវកម្មរ៉ែជាច្រើននៅជុំវិញតំបន់ព្រៃឡង់នៅក្នុងបណ្តាឆ្នាំថ្មីៗនេះ។ ដីសម្បទានជាច្រើន បានមកជំនួសព្រៃសម្បទានចាស់ៗដែលបានបញ្ឈប់នៅឆ្នាំ២០០២។ ភាគច្រើននៃដីសម្បទានទាំងនេះ គឺសម្រាប់កសិ-ឧស្សាហកម្មដែលមានចំការកៅស៊ូច្រើនជាងគេ។ អាជ្ញាប័ណ្ណរុករក និងអាជីវកម្មរ៉ែជាច្រើនត្រូវបានចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សម្រាប់ទីតាំងនានានៅក្នុង និងជុំវិញតំបន់ព្រៃនេះ។[៤៧] សូមមើលផែនទី៥ សម្រាប់ព័ត៌មានលំអិត។

ក្នុងចំណោមដីសម្បទានសេដ្ឋកិច្ចថ្មីៗទាំងអស់នៅជុំវិញតំបន់ព្រៃឡង់ គ្មានដីសម្បទានណាមួយដែលមានទំនាស់ច្រើនជាងចំការកៅស៊ូទំហំ ៦,០០០ហិកតា របស់ក្រុមហ៊ុន CRCK នៅស្រុកសណ្តាន់ ក្នុងខេត្តកំពង់ធំឡើយ។ ក្រុមហ៊ុនដីសម្បទាននេះ ស្ថិតក្នុងចំណោមក្រុមហ៊ុនចំនួនបីដែលមានទំនាក់ទំនងជាមួយក្រុមហ៊ុនចំការកៅស៊ូវៀតណាម (VRG) រួមជាមួយក្រុមហ៊ុនដីសម្បទាន Thy Gna[៤៨] និង PNT ដែលស្ថិតនៅជាប់ពីខាងជើងទីតាំងក្រុមហ៊ុន CRCK។ ជាការឆ្លើយតបទៅនឹងការដាក់កំហិតរបស់រដ្ឋាភិបាលនៃប្រទេសវៀតណាម លើការប្រើប្រាស់ដីក្រុមហ៊ុន VRG បានពង្រីកផលិតកម្មទៅក្នុងប្រទេសជិតខាង ហើយមកទល់ចុងឆ្នាំ២០១១ ក្រុមហ៊ុននេះមានគម្រោងអន្តរជាតិចំនួន២៤ ដែលរួមទាំងគម្រោងចំនួន១៥ នៅក្នុងប្រទេសកម្ពុជាផងដែរ។[៤៩] កង្វល់អំពីការពង្រីកសម្បទានដីសម្រាប់ដំណាំកៅស៊ូក្នុងពេលថ្មីៗនេះនៅក្នុងប្រទេសឡាវបាននាំឲ្យរដ្ឋាភិបាលឡាវដាក់កំហិតផងដែរ លើការប្រើប្រាស់ដីនៅក្នុង ខែកញ្ញា ឆ្នាំ២០១១។ ការកំហិតនេះ មួយផ្នែក

---

[៤៧] Land Grabbing & Poverty in Cambodia: The Myth of Development: May 2009, Licadho.

[៤៨] ជួនកាលភាសាអង់គ្លេសសរសេរថា Thy Nga

[៤៩] http://www.vneconomynews.com/2012/01/vietnam-rubber-group-has-24-projects-in.html

ដោយសារកំណើនការទន្ទ្រានចូលក្នុងដីព្រៃ ប៉ុន្តែវាជាការបង្កើនមុខដំណាំពាណិជ្ជកម្ម និងដើម្បីធានាសន្តិសុខស្បៀងទៅអនាគត។[៥០]

ផ្ទុយពីគោលការណ៍ណែនាំរបស់កម្មវិធីព្រៃឈើជាតិ ក្រុមហ៊ុនសម្បទាន CRCK ពិតជាមិនស្ថិតនៅក្នុងតំបន់ព្រៃរេចរឹលឡើយ បើតាមការអះអាងរបស់អ្នកស្រាវជ្រាវ។ យោងតាមប្រជាពលរដ្ឋមូលដ្ឋាន ព្រៃឈើនៅក្នុងតំបន់នេះស្ថិតនៅក្នុងស្ថានភាពល្អជាបង្គួរនៅមុនការមកដល់នៃក្រុមហ៊ុនសម្បទាននេះ និងស្ថិតក្រោមការប្រើប្រាស់ជាទូទៅពីសំណាក់សហគមន៍មូលដ្ឋាន សម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគេ។ លើសពីនេះ ពុំមានដំណើរការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋានឡើយ បើទោះវាជាផ្នែកមួយនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មុននឹងការចុះកិច្ចព្រមព្រៀង ដែលនេះជាការរំលោភលើច្បាប់ដែលនៅជាធរមាន។[៥១]

យោងតាមអ្នកភូមិ ក្រុមហ៊ុនសម្បទាននេះមិនត្រឹមតែបំផ្លាញធនធានរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែ គ្រួសាររបស់ពួកគេក៏បាត់បង់ដីចំការប្រពៃណី និងវាលស្មៅសម្រាប់ការចិញ្ចឹមសត្វរបស់ពួកគេ ដែលនាំឲ្យបាត់បង់សិទ្ធិប្រើប្រាស់ដី និងគំរាមកំហែងចំពោះសន្តិសុខស្បៀងរបស់សហគមន៍មូលដ្ឋានផងដែរ។ លើសពីនេះ អ្នកភូមិជាច្រើនអះអាងថា ក្រុមហ៊ុននេះមិនអនុញ្ញាតឲ្យអ្នកភូមិឆ្លងកាត់តំបន់ដីសម្បទានដើម្បីទៅដល់ដើមច្បោះ ឬអនុផលព្រៃឈើនៅខាងកើតតំបន់ដីសម្បទាននេះឡើយ ដោយទុកឲ្យដើរវាងជាច្រើនគីឡូម៉ែត្រ ដែលត្រូវចំណាយពេលយ៉ាងច្រើន។

---

[៥០] យោងតាមសេចក្តីរាយការណ៍ក្នុងសារព័ត៌មាន វៀងច័ន្ទ ថាយម៍ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១។ http://www.laolandissues.org/2011/09/16/limits-set-on-future-rubber-plantations-in-laos/

[៥១] អនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច មាត្រា ៤។ ប្រកាសស្តីពីគោលការណ៍ណែនាំសម្រាប់របាយការណ៍ EIA, មាត្រា ១១។




ផែនទី៥: ផែនទីស្តីពីទីតាំងដីសម្បទានសេដ្ឋកិច្ចនិងអាជ្ញាប័ណ្ណសម្រាប់អាជីវកម្មរ៉ែដែលយើងបានដឹងនៅជុំវិញតំបន់ព្រៃឡង់

## ១០.២ អាជ្ញាប័ណ្ណអាជីវកម្មរ៉ែ

អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្រូវបានផ្តល់ទៅអោយក្រុមហ៊ុនជាច្រើន ដើម្បីរុករក ឬធ្វើនិស្សារណកម្មទៅលើធនធានរ៉ែជាច្រើនប្រភេទ រួមមានរ៉ែដែកនៅភាគខាងជើងព្រៃឡង់ និងរ៉ែមាសនៅចំណុចកណ្តាល និងភាគខាងជើងនៃព្រៃឡង់[៥២]។ រ៉ែមាសនៅតំបន់ព្រៃឡង់ ត្រូវបានគេកម្រិតព្រំដែនយ៉ាងធំនៅតំបន់ជុំវិញភ្នំជី ជាច្រើនឆ្នាំមកនេះ[៥៣]។ ទោះជាយ៉ាងណា ដោយសារតែតម្លៃមាសមានការកើនឡើង ការរុករករ៉ែល្មើសច្បាប់ខ្នាតតូចរាប់រយបានកើតឡើង តាមបណ្តោយដងស្ទឹងនានានៅភាគកណ្តាល និងភាគខាងត្បូងនៃតំបន់ព្រៃឡង់ជាងមួយឆ្នាំ ឬលើសពីនេះ។ តាមរយៈរបាយការណ៍សមាជិកបណ្តាញព្រៃឡង់ ជនជាតិកួយដែលអនុវត្តការរុករករ៉ែជាលក្ខណៈប្រពៃណីត្រូវបានគេប្រាប់ថា សកម្មភាពរុករករបស់ពួកគេជាការល្មើសច្បាប់ និងត្រូវតែបញ្ឈប់។ ទោះយ៉ាងណា ធនធានរ៉ែរាប់រយប្រភេទកំពុងតែត្រូវគេប្រើវិធីសាស្ត្ររុករកដែលធ្វើអោយមានភាពវិនាស ដែលជារឿយៗគេប្រើសារធាតុគីមីពុលដូចជា ថ្នាំជ្រលក់ពណ៌ខៀវ និងបារ៉ត ដោយគ្មានវិធានការត្រួតពិនិត្យ និងពង្រឹងច្បាប់ឡើយ។ បញ្ហានេះបានបង្កអោយមានការព្រួយបារម្ភជាខ្លាំងចំពោះកង្វក់ទឹកដែលបានគំរាមកំហែងដល់សហគមន៍នៅខ្សែទឹកខាងក្រោម និងប្រជាជនជាច្រើននៅភាគកណ្តាលដូចជាខេត្តកំពង់ធំ និងខេត្តកំពង់ចាម។

ការប៉ាន់ប្រមាណរបបជលសាស្ត្រដោយ USAID នៅឆ្នាំ២០១១[៥៤] បានកត់សម្គាល់ថា ទីតាំងទាំងពីរដែលមានសម្បទានអាជីវកម្មរ៉ែ ស្ថិតនៅជិតទីតាំងនានានៃល្អាងទឹកក្រោមដី គឺជាប្រភពផ្តល់ទឹកដល់ទីជម្រាលស្ទឹងសែន និងស្ទឹងជីនិត នៅភាគខាងលិច និងភាគខាងត្បូងព្រៃឡង់។ ទោះបីរបាយការណ៍នោះមិនអាចប៉ាន់ស្មានអំពីកម្រិតនៃផលប៉ះពាល់ក៏ដោយ អណ្តូងរ៉ែទាំងនេះអាចបង្កផលប៉ះពាល់មកលើព្រៃឈើ និងល្អាងទឹកក្រោមដីទាំងនេះ។

[៥២] Country for Sale – Welcome to Cambodia, Global Witness, February 2009

[៥៣] http://www.indochinemining.com/projects/kratie

[៥៤] USAid Rapid Socio-Economic And Hydrological Assessment of Prey Lang Forest, April 29th 2011 by Advanced Engineering Consultants Ltd.

លិខិតមួយចុះនៅខែកញ្ញា ឆ្នាំ២០០៩ មកពីអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិជូនរដ្ឋាភិបាល បានចោទសួរអំពីការចោទប្រកាន់ករណីអាជីវកម្មរ៉ែមាសអនាធិបតេយ្យ និងសកម្មភាពនានារបស់ក្រុមហ៊ុនវ៉ានីម៉ិច នៅជុំវិញភ្នំជី។ ក្រុមហ៊ុនវ៉ានីម៉ិច ត្រូវបានចោទប្រកាន់អំពីការប្រើប្រាស់វិធីប្រកបដោយគ្រោះថ្នាក់ និងបានសុំឲ្យសហគមន៍មូលដ្ឋានចាកចេញ ឬធ្វើការឲ្យក្រុមហ៊ុនដោយទទួលបានកម្រៃទាប។[៥៥]

**ប្រអប់ទី៣: ការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០**

«ក្រុមហ៊ុនវ៉ានីម៉ិកបានទទួលសិទ្ធិពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីសិក្សារុករករ៉ែមាស នៅភ្នំជី ក្នុងស្រុកសណ្ដាន់ ខេត្តកំពង់ធំ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុនវ៉ានីម៉ិក នៅពុំទាន់បានចាប់ផ្ដើមសកម្មភាព ធ្វើអាជីវកម្មរ៉ែពិតប្រាកដនៅឡើយទេ។ មានការចោទប្រកាន់ថា គឺប្រជាពលរដ្ឋមូលដ្ឋាននៅក្នុងតំបន់នោះ ដែលធ្វើសកម្មភាពជីកយករ៉ែដោយល្មើសច្បាប់ ដោយមានការប្រើប្រាស់សារជាតុគីមីពុល ដើម្បីទាញយកមាស។ ការចោទប្រកាន់របស់អ្នករាយការណ៍ពិសេស ដែលថាក្រុមហ៊ុនបានសុំឲ្យប្រជាពលរដ្ឋមូលដ្ឋានចាកចេញ ឬ ធ្វើការដោយទទួលប្រាក់កម្រៃទាប មានលក្ខណៈមិនសមហេតុផល ដោយសារតែក្រុមហ៊ុននៅពុំទាន់បានទទួលអាជ្ញាប័ណ្ណដើម្បីធ្វើអាជីវកម្មរ៉ែ ហើយប្រសិនបើក្រុមហ៊ុននេះបានចាប់ផ្ដើមធ្វើអាជីវកម្មរ៉ែ ក្រុមហ៊ុននេះគួរតែបានបញ្ឈប់ប្រជាជនពីសកម្មភាពអាជីវកម្មអនាធិបតេយ្យនៅលើដីសម្បទានរបស់ខ្លួនទៅហើយ។»

ការឆ្លើយតបរបស់រដ្ឋាភិបាល គឺថាក្រុមហ៊ុនវ៉ានីម៉ិកពុំទាន់មានអាជ្ញាប័ណ្ណដើម្បីធ្វើអាជីវកម្មរ៉ែមាសនៅឡើយទេ ប៉ុន្តែមានត្រឹមតែអាជ្ញាប័ណ្ណរុករករ៉ែតែប៉ុណ្ណោះ។ មានព័ត៌មានតិចតួចប៉ុណ្ណោះ អំពីសកម្មភាពធ្វើអាជីវកម្មរ៉ែ នៅជុំវិញភ្នំជី ហើយអ្នកស្រាវជ្រាវមិនអាចទៅដល់តំបន់នោះ កំឡុងពេលចុះប្រមូលទិន្នន័យឡើយ ដោយសារជារដូវវស្សា ដូច្នេះវានៅតែមានភាពមិនច្បាស់លាស់ថាតើការពិតអំពីការរុករករ៉ែវាយ៉ាងណា។ សម្រាប់គោលបំណងនៃរបាយការណ៍នេះត្រូវបានរំពឹងទុកថា

[៥៥] http://unsr.jamesanaya.org/cases-2010/08-cambodia-cambodia-land-laws-and-policies-and-the-situation-concerning-development-in-and-around-the-prey-lang-forest

អាចមានទស្សនកិច្ចនៅតំបន់នោះ ដើម្បីពិនិត្យមើលអ្វីដែលកើតឡើងជាក់ស្តែងនៅក្នុងមូលដ្ឋាន។ យើងបានសុំការសម្ភាសក្រសួងឧស្សាហកកម្ម រ៉ែ និងថាមពលដោយសង្ឃឹមថាក្រសួងនេះ នឹងអាចធ្វើការបញ្ជាក់អោយកាន់តែច្បាស់នូវបញ្ហាមួយចំនួន ប៉ុន្តែ ជាអកុសល ក្រសួងនេះបានបដិសេធចំពោះសំណើសុំសម្ភាសន៍ ដោយបានបញ្ជាក់ថាក្រសួងមិនបានចេញអាជ្ញាប័ណ្ណអាជីវកម្មរ៉ែនៅតំបន់ព្រៃឡង់ឡើយ។ ជាការច្បាស់ណាស់ថា ប្រការនេះមិនសុក្រឹត្យទាំងស្រុងឡើយ ប៉ុន្តែកង្វះការកំណត់ព្រំប្រទល់ជាផ្លូវការអំពីតំបន់ព្រៃឡង់ផ្តល់ឱកាសដល់ក្រសួងនេះ ក្នុងការបដិសេធនូវការសាកសួរណាមួយ។

នៅក្នុងពេលអង្កេតនៅស្រុកសណ្តាន់ អ្នកស្រាវជ្រាវបានទទួលដំណឹងថាមានការខួងរណ្តៅនៅក្នុងភូមិស្រែវាល រវាងថ្ងៃទី ១៦ ខែ មិថុនា និង ១៦ ខែសីហា ឆ្នាំ២០១០។ យោងតាមប្រជាពលរដ្ឋមូលដ្ឋាន មានការខួងរណ្តៅមួយចំនួននៅក្នុងភូមិនេះ ហើយភាគច្រើននៅជិតស្ទឹង។ ប៉ូលីសត្រូវបានទទួលការណែនាំដើម្បីរារាំងប្រជាជនមិនឲ្យសាកសួរ ហើយគេបានណែនាំកម្មករមិនឲ្យនិយាយអ្វីទាំងអស់។ រណ្តៅមួយនៅជិតស្ទឹងត្រូវគេបញ្ចូលបំពង់ផ្លាស្ទិកទៅក្នុងនោះ ដោយមានការបញ្ជាមិនឲ្យអ្នកភូមិប៉ះពាល់ឡើយ។




**រូបភាពទី១: ទីតាំងខួងដ៏អាថ៌កំបាំងនៅភូមិស្រែវាលកាលពីខែសីហា ឆ្នាំ២០១០**
**(មិនមានអ្នកណាដឹងអំពីអាជ្ញាប័ណ្ណសម្រាប់ការរុករករ៉ែក្នុងតំបន់នេះឡើយ)**

ពួកគេបានប្រាប់អ្នកភូមិថា ពួកគេខួងរណ្តៅជម្រៅប្រមាណ៤០ម៉ែត្រ ប៉ុន្តែមិនដឹងថាតើពួកគេកំពុងស្វែងរកអ្វីឡើយ។ ក្រោយខួងរណ្តៅចុងក្រោយ ប្រធានក្រុមដែលជាជនជាតិវៀតណាម និងជនជាតិឥណ្ឌា ត្រូវគេមើលឃើញថា «បានចាប់ដៃគ្នា» ទៅវិញទៅមកដោយសប្បាយរីករាយ និងធ្វើការអបអរសាទរ។ ក្រោយពីនោះក្រុមនេះបានប្រមូលរបស់របរពួកគេ និងចាកចេញពីទីតាំងនោះវិញទៅ។ ស្ត្រីម្នាក់

ដែលរស់នៅជិត «បំពង់ផ្លាស្ទិក» ដែលគេបានជីករណ្ដៅនោះត្រូវគេប្រាប់ថាផ្ទះរបស់គាត់នឹងត្រូវរុះរើនៅក្នុងរយៈពេលមិនយូរប៉ុន្មានឡើយ ប៉ុន្តែគាត់មិនដឹងទេថាតើនៅពេលណា ឬហេតុអ្វីរឿងនោះកើតឡើងឡើយ។ នៅក្នុងពេលនេះ ពុំមានការចេញអាជ្ញាប័ណ្ណឲ្យធ្វើអាជីវកម្មរ៉ែនៅក្នុងតំបន់នេះឡើយ។

មានសេចក្តីរាយការណ៍ថា នៅក្នុងសារព័ត៌មានចិន[៥៦] ក្នុងខែវិច្ឆិកា ឆ្នាំ ២០១១ ក្រុមហ៊ុន China's Guangxi Nonferrous Metal Group គ្រោងធ្វើការវិនិយោគទឹកប្រាក់ចំនួន ៥០០លានដុល្លារអាមេរិក លើរោងចក្រផលិតលោហៈ និងតំបន់ឧស្សាហកម្មមួយនៅក្នុងប្រទេសកម្ពុជានៅក្នុងរយៈពេលបីឆ្នាំខាងមុខ។ មានការកត់សម្គាល់ផងដែរថា ក្រុមហ៊ុននេះបានធ្វើការវិនិយោគរួចមកហើយនូវទឹកប្រាក់ប្រមាណ៣០លានដុល្លាអារមេរិក ក្នុងការរុករករ៉ែដែកនៅស្រុករវៀងនៃខេត្តព្រះវិហារ។ លោក យ៉ាង ដាវស៊ី អនុប្រធានតំបន់ស្វយ័តក្វាងស៊ីហ្ស៊ង បានធ្វើការប្រកាសនៅក្នុងអំឡុងពេលនៃការប្រជុំជាមួយរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលកម្ពុជា លោក ស៊ុយ សែម។ រដ្ឋមន្ត្រីរូបនេះត្រូវបានគេស្រង់សំដីដែលបានពោលថា «ក្រសួងនេះគាំទ្រពេញទំហឹងឲ្យមានគម្រោងនេះ ហើយលោកនឹងណែនាំអំពីទីតាំងសមស្របសម្រាប់ក្រុមហ៊ុននេះសាងសង់រោងចក្រ»។ គេពុំឃើញមានការផ្តល់យោបល់អំពីទីតាំងសម្រាប់សាងសង់រោងចក្រនេះនៅឡើយទេ ប៉ុន្តែមានរ៉ែដែកកំពុងនាំចេញពីតំបន់រវៀង ហើយមានកង្វល់ជាក់ស្តែងជាច្រើនអំពីទីតាំងដែលរោងចក្រនឹងត្រូវសាងសង់។

## ១០.៣ ការកាប់ឈើល្មើសច្បាប់

ការចូលទៅក្នុងតំបន់ព្រៃឡង់មានសភាពងាយស្រួលជាបង្គួរ សម្រាប់អ្នកកាប់ឈើល្មើសច្បាប់ ដោយសារមានបណ្តាញនៃច្រកផ្លូវនានា ដានរទេះគោ និងផ្លូវកាប់ឈើដែលបន្សល់ទុកតាំងពីសម័យកាលព្រៃសម្បទានមកម្លេះ។ ចាប់តាំងពីឆ្នាំ ២០០៧ មក គេឃើញមានកំណើននៃការកាប់ឈើល្មើសច្បាប់ក្នុងទូទាំងតំបន់ព្រៃឡង់ជាបណ្តើរៗ ហើយមកទល់ឆ្នាំ២០១១ សកម្មភាពល្មើសច្បាប់នេះបានឈាន

[៥៦] http://www.chinadaily.com.cn/bizchina/2011-11/19/content_14124492.htm

ដល់កម្រិតមួយ ដែលរាល់ដើមឈើដែលមានតម្លៃត្រូវបានគេកាប់ដោយគ្មានរើសមុខ។[៥៧] សកម្មភាពនេះអាចកើតមាននៅក្នុងផ្នែកខ្លះ ដោយសារតែកំណើនថ្លៃឈើប្រណិតក្នុងពេលថ្មីៗនេះ ដូចជាបេង និងក្រញូង ដែលមានតម្លៃរវាង ៥,០០០ និង ៨,០០០ដុល្លាអារមេរិកក្នុងមួយម៉ែត្រគូប នៅក្នុងប្រទេសវៀតណាម។[៥៨] សូម្បីតែដើមច្បោះដែលមានតម្លៃត្រឹមប្រមាណរយដុល្លារអាមេរិកប៉ុណ្ណោះ ក្នុងមួយម៉ែត្រគូប ក៏ត្រូវបានគេកាប់ជាទ្រង់ទ្រាយធំផងដែរ។ ប្រការនេះបាននាំឲ្យមានឥទ្ធិពលដ៏មហន្តរាយមកលើទាំងសហគមន៍ជនជាតិខ្មែរ និងសហគមន៍ជនជាតិដើមដែលអ្នកទាំងនោះភាគច្រើនពឹងផ្អែកទាំងស្រុងលើការប្រមូលយកជ័រ សម្រាប់ជាប្រភពចំណូល។ តាមរយៈការរានឆ្ការជាលក្ខណៈប្រព័ន្ធ នៅក្នុងតំបន់ព្រៃឡង់ គេអាចនិយាយបានថា ដើមឈើមានតម្លៃភាគច្រើនបានបាត់បង់អស់ទៅហើយ។

ការកាប់ឈើល្មើសច្បាប់ក៏ត្រូវបានសង្កេតឃើញថា កាន់តែកើនឡើងផងដែរ នៅក្នុងតំបន់ជុំវិញនៃទីតាំងអភិវឌ្ឍន៍នានាក្នុងប្រទេស ដូចជាផ្លូវថ្នល់ ដីសម្បទានសេដ្ឋកិច្ច និងទំនប់។ ផ្លូវថ្មីៗនៅក្នុងតំបន់ជួរភ្នំក្រវាញ បានបើកចំហសម្រាប់ទីតាំងដែលកាលពីមុនមកលំបាកចេញចូល ចំណែកទំនប់ ដូចជា គម្រោងស្ទឹងអាតៃបានព័ទ្ធជុំវិញទៅដោយការចោទប្រកាន់អំពីសកម្មភាពកាប់ឈើល្មើសច្បាប់។[៥៩] កាលពីមុន តំបន់ព្រៃឡង់ក៏បានជួបប្រទះបញ្ហានានារបស់ខ្លួនផងដែរ ដូចជានៅទំរីង ដែលដើមច្បោះជាច្រើនពាន់ដើមត្រូវបានកាប់ដោយល្មើសច្បាប់ ចំណែកឈើដែលមានតម្លៃត្រូវបានដកហូតចេញពីតំបន់ជុំវិញនោះ និងបានលក់ចេញ។[៦០] ក្នុងពេលដែលការអភិវឌ្ឍដែលទទួលសិទ្ធិពីរដ្ឋាភិបាល ត្រូវបានអនុញ្ញាតឲ្យប្រមូលយកផលឈើ

[៥៧] ផ្អែកតាមបទពិសោធន៍ផ្ទាល់ខ្លួន និងការពិភាក្សានានាជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋាន នៅពេលធ្វើទស្សនកិច្ចតាមតំបន់ស្នូល នៃព្រៃឡង់។ បានមកពីការពិភាក្សាជាមួយអ្នកជំនាញការរុក្ខជាតិមួយចំនួនផងដែរ ដែលបានធ្វើដំណើរមកព្រៃឡង់ជាទៀងទាត់ យ៉ាងហោចណាស់ តាំងពីឆ្នាំ ២០០៤មក។

[៥៨] ថ្លៃដែលបានពីប្រភពនានានៅក្នុងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការខាងអភិរក្ស ដូចជា អង្គការអភិរក្សអន្តរជាតិ និងសម្ព័ន្ធភាពសត្វព្រៃ ក៏ដូចជា បានមកពីអង្គការការពារធនធានធម្មជាតិ និងប្រភពមកពីរដ្ឋបាលព្រៃឈើផងដែរ។

[៥៩] http://www.phnompenhpost.com/index.php/2011122153536/National-news/logging-in-the-wild-west.html

[៦០] Global Witness report “Family Trees” 2007

ដោយស្របច្បាប់នៅក្នុងតំបន់នានាដែលបានកំណត់ ការធ្វើបែបនេះក៏បានផ្តល់ភាពងាយស្រួលសម្រាប់ការកាប់ឈើល្មើសច្បាប់ពីតំបន់ជុំវិញផងដែរ។

## ដូច្នេះ តើអ្នកណាជាអ្នកកាប់ឈើ?



រូបភាពទី ២: ដង្កត់ដើមច្បោះនៅជិតផ្លូវក្រុមហ៊ុនសម្បទាននៅសណ្តាន់

នៅស្រុកសណ្តាន់ ប្រជាជននីមូលដ្ឋាន បានរាយការណ៍អំពីការកាប់ឈើជាទូទៅ នៅជុំវិញចំការរបស់ក្រុមហ៊ុន CRCK។ យោងតាម សមាជិកបណ្តាញសហគមន៍ព្រៃឡង់ អ្នកកាប់ឈើល្មើសច្បាប់ជាច្រើន ដែលត្រូវបានឃាត់ខ្លួន ពីសំណាក់បណ្តាញនេះ បានអះអាងថា ពួកគេធ្វើការឲ្យក្រុមហ៊ុននេះ។ ប្រជាជននៅមូលដ្ឋានមានជំនឿជាទូទៅថាហេតុផលពីក្រោយអំពើនេះគឺធ្វើយ៉ាណាឲ្យព្រៃរេចរឹលដល់កម្រិតមួយដែលគ្រប់គ្រាន់ សម្រាប់ក្រុមហ៊ុនស្នើសុំដើម្បីពង្រីកចូលក្នុងតំបន់ដែលមានតែព្រៃរិចរឹលរួចទៅហើយនោះ។ គេមិនអាចនិយាយបានទេថា ក្រុមហ៊ុនមានការពាក់ព័ន្ធកម្រិតណា ប៉ុន្តែឈើហ៊ុបរាប់រយដើមដែលមានសញ្ញាសំគាល់ (ដែលក្នុងនោះឈើជាច្រើនជាដើមច្បោះ) នៅតាមដងផ្លូវចូលទៅទីតាំងដីសម្បទាន ពិតជាចង្អុលបង្ហាញអំពីសកម្មភាពល្មើសច្បាប់របស់ក្រុមហ៊ុន។

ជាការពិត មិនមែនអ្នកកាប់ឈើទាំងអស់សុទ្ធតែធ្វើការអោយក្រុមហ៊ុន CRCK ទេ ព្រោះ អ្នកខ្លះ មកពីទីរួមខេត្តកំពង់ធំ ហើយជារឿយៗពួកគេប្រាប់ថាពួកគេត្រូវបានមន្ត្រីដែលមានឋានៈខ្ពស់ ឬអ្នកដែលមានខ្នងក្រាស់ជួលអោយធ្វើការងារនេះ។[៦១] តួអង្គសំខាន់ផ្សេងទៀតដែលត្រូវបានគេកត់សំគាល់នោះ រួមមានមន្ត្រីរដ្ឋបាលព្រៃឈើនៅក្នុងមូលដ្ឋាន និងមន្ត្រីអាវុធហត្ថនៅត្រង់ប៉ុស្តិ៍ត្រួតពិនិត្យរបស់ក្រុម

[៦១] NRPG and PLNC members and researcher questioned illegal loggers apprehended in Sep 2011.

ហ៊ុនសម្បទាននេះ។[៦២] ដោយសារតែប៉ុស្តិ៍ត្រួតពិនិត្យមានអំណាចបញ្ឈប់ស្ទើរតែគ្រប់ការកាប់ឈើល្មើសច្បាប់ដែលកើតមានឡើងនៅក្នុងទីតាំងនោះ វាមានការពិបាកក្នុងការបដិសេធអំពីការពាក់ព័ន្ធរបស់ពួកគេនៅក្នុងសកម្មភាពទាំងនេះ។ ដោយសារមានការមិនពេញចិត្តចំពោះការទារយក «ប្រាក់កម្រៃ» មិនផ្លូវការពីប្រជាជនមូលដ្ឋាន ប៉ុស្តិ៍ត្រួតពិនិត្យ ត្រូវបានចោទប្រកាន់អំពីការទារយកប្រាក់ពីក្រុមអ្នកកាប់ឈើ ២០ ដុល្លារអាមេរិក ក្នុងមួយថ្ងៃ ដើម្បីអាចចូលតាមផ្លូវរបស់ក្រុមហ៊ុនសម្បទាននេះ។[៦៣] នៅតាមខ្សែចង្វាក់នេះ ប្រជាជនរដ្ឋមូលដ្ឋានបានឲ្យដឹងថា មន្ត្រីឃុំ និងមន្ត្រីស្រុក និងមន្ត្រីជាន់ខ្ពស់ក្នុងជួរប៉ូលីសមូលដ្ឋាន គឺជាអ្នកចាត់ចែង និងណែនាំឲ្យមានសកម្មភាពជាច្រើននៃការកាប់ឈើល្មើសច្បាប់ និងការទន្ទ្រានយកដីនៅទូទាំងស្រុកសណ្តាន់។ ពួកគេក៏ជាអ្នកឃុបឃិតជាមួយក្រុមហ៊ុននេះផងដែរ។[៦៤]

នៅខេត្តស្ទឹងត្រែង ការកាប់ឆ្ការតំបន់ធំៗពីសំណាក់ជនចំណាកស្រុកមិនសូវបង្ហាញឲ្យឃើញច្បាស់លាស់ឡើយ។ នៅក្នុងករណីមួយចំនួន អ្នកស្រាវជ្រាវបានឃើញឈើប្រណិតប្រមាណ១០ម៉ែត្រគូប គរនៅក្នុងភូមិនានានៅក្នុងស្រុកថាឡាបរិវ៉ាត់រង់ចាំការដឹកចេញ។ វិសាលភាពធំធេងនៃការកាប់ឈើ បង្ហាញពីការពាក់ព័ន្ធនៃអាជ្ញាធរមូលដ្ឋាននៅក្នុងកម្រិតខុសៗគ្នា។

## ១០. ៤ កំណើនជនចំណាកស្រុក/កំណើនចំនួនប្រជាជន

យោងតាមជំរឿនប្រជាជននៅកម្ពុជា ឆ្នាំ១៩៩៨ និង២០០៨ ប្រជាជនតាមជនបទនៅក្នុងខេត្តទាំងបួនដែលជាប់នឹងព្រៃឡង់បានកើនឡើងចំនួន៣៥% ដែលត្រូវជាជិតពីរដងនៃកំណើនជាមធ្យមទូទាំងប្រទេសនៅក្នុងរយៈពេលដូចគ្នានេះ។[៦៥] កង្វះសុវត្ថិភាពកម្មសិទ្ធិដីចំពោះប្រជាជនចំណាកស្រុក បាននាំឲ្យមានបញ្ហាធ្ងន់ធ្ងរមួយ ដោយសារគ្រួសារដែលគ្មានដីធ្លីនៅទូទាំងប្រទេស បន្តស្វែងរកទីកន្លែងដើម្បី

[៦២] ការអះអាងនៅក្នុងការសម្ភាសនានានៅសណ្តាន់ (សូមអានជំពូកស្តីពីលទ្ធផលស្រាវជ្រាវ)

[៦៣] ការអះអាងដោយសមាជិកបណ្តាញសហគមន៍ព្រៃឡង់ និងអង្គការការពារធនធានធម្មជាតិ។

[៦៤] ការអះអាងដោយសមាជិកបណ្តាញសហគមន៍ព្រៃឡង់ និងអង្គការការពារធនធានធម្មជាតិ។

[៦៥] http://celade.cepal.org/khmnis/census/khm1998/ http://celade.cepal.org/khmnis/census/khm2008/

តាំងទីលំនៅ។ កង្វះសន្តិសុខស្បៀង ក៏រួមចំណែកធ្វើឲ្យបាត់បង់ព្រៃឈើផងដែរ នៅពេលដែលអ្នកចំណាកស្រុករានឆ្ការព្រៃដើម្បីដាំដំណាំសំខាន់ៗដូចជាស្រូវ ឬដំណាំសម្រាប់លក់នានាដូចជា ស្វាយចន្ទី ដំឡូងមី ឬសណ្តែកសៀង។[៦៦]

នៅក្នុងអំឡុងពេលនៃដំណើរកាលពីខែមេសា ឆ្នាំ២០១១ អ្នកស្រាវជ្រាវបានសម្ភាសន៍គ្រួសារចំនួន២ ដោយត្រួសៗ នៅក្នុងស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។ តំបន់នេះជាតំបន់ព្រៃស្រឡៅដ៏ធំ ដែលមានតាលព្រឹក្សធំៗដែលត្រូវបានរានឆ្ការចាប់តាំងពីអ្នកស្រាវជ្រាវបានចូលមកក្នុងតំបន់នេះនៅក្នុងខែមិថុនា ឆ្នាំ២០០៩មកម្លេះ។ ទីនេះមិនមែនជាផ្នែកមួយនៃសហគមន៍ ដែលបានកំណត់អត្តសញ្ញាណរួចមកហើយនោះទេ។ សហគមន៍រំដៀងស្ថិតនៅជិតជាងគេដែលត្រូវបានបង្កើតឡើងនៅចម្ងាយប្រមាណ ៤ ទៅ ៥គីឡូម៉ែត្រភាគឦសាន។ គ្រួសារទាំងពីរបានអះអាងថាពួកគេមកពីខេត្តកំពត និងគ្មានដីធ្លីនៅទីនោះទេ ហើយពួកគេទើបមកដល់ទីនេះបានប្រាំមួយខែ និងកំពុងត្រៀមចាប់ផ្តើមដាំដំឡូងមី។

គ្រួសារទាំងពីរបានអះអាងថាបានទិញដីនោះ ហើយនៅពេលសួរថាតើពួកគេដឹងអំពីដីនៅព្រៃឡង់ដោយរបៀបណា ពួកគេឆ្លើយថាអាជ្ញាធរមូលដ្ឋាននៅខេត្តកំពតបានប្រាប់ពួកគេពីដីនៅទីនេះ។ គ្រួសារមួយបានបញ្ជាក់ថា ប៉ូលីសបានប្រាប់ពួកគេ ចំណែកគ្រួសារមួយទៀតបានបញ្ជាក់ថា មានមន្ត្រីម្នាក់ផ្សេងទៀតជាអ្នកប្រាប់ពួកគេអំពីដីនៅទីនេះ។ គ្រួសារទាំងពីរបានពោលថា ពួកគេត្រូវបានណែនាំឲ្យទៅធនាគារមួយដែលពួកគេធានាថានឹងអាចផ្តល់ប្រាក់កម្ចីដល់ពួកគេដើម្បីទិញដី។ ពួកគេក៏បាននិយាយទៀតថា គ្រួសារជាច្រើនទៀតនៅខេត្តកំពតនឹងមកទីនេះនៅក្នុងពេលឆាប់ៗខាងមុខនេះ។

## ១១. ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន/ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

នៅក្នុងច្បាប់ដូចបានបញ្ជាក់នៅក្នុងប្រកាសស្តីពី «គោលការណ៍ណែនាំសម្រាប់ធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន» និងអនុក្រឹត្យដែលពាក់

[៦៦] ការសម្ភាសជាមួយជនចំណាកស្រុក នៅក្នុងស្រុកថាឡាបរិវ័ត្តិ។

ព័ន្ធ[៦៧] ក៏ដូចជាអនុក្រឹតស្តីពីដីសម្បទានសេដ្ឋកិច្ច (មាត្រា៩) បង្ហាញថា ក្រុមហ៊ុនវិនិយោគត្រូវតែប្រគល់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅអោយ «ស្ថាប័នដែលអនុម័តគម្រោង» ឧទាហរណ៍ ដីសម្បទានសេដ្ឋកិច្ចអនុម័តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បន្ទាប់មកស្ថាប័នដែលអនុម័តលើគម្រោង ត្រូវផ្តល់ឯកសារនេះជាបន្តទៅអោយក្រសួងបរិស្ថានដើម្បីពិនិត្យ[៦៨] ក្នុងរយៈពេល៣ ថ្ងៃនៃថ្ងៃធ្វើការ។[៦៩] ប្រសិនជា របាយការណ៍មានចំណុចដែលខ្វះខាត របាយការណ៍នេះអាចបញ្ជូនត្រឡប់ទៅត្រឡប់មករវាងក្រសួងដែលពាក់ព័ន្ធ និងក្រុមហ៊ុន ដើម្បីធ្វើការស៊ើបអង្កេត និងត្រួតពិនិត្យឡើងវិញ។

នៅក្នុងករណីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងចុងក្រោយជាមួយក្រុមហ៊ុន ដោយក្រសួងបរិស្ថានជាអ្នកអនុម័តលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយផ្អែកលើការពិនិត្យគុណភាពនៃរបាយការណ៍។ ដំណើរការនេះអាចនិយាយបានថា តាមលក្ខន្តិកៈច្បាប់ក្រសួងទាំងពីរមានសិទ្ធិបដិសេធ ឬទាមទារអោយមានការកែប្រែចំពោះរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង/ឬសំណើរបស់ក្រុមហ៊ុនគួរតែត្រូវបានពួកគេសន្មត់ថាគ្រប់គ្រាន់ហើយ។ ទោះយ៉ាងណាក៏ដោយ ប្រកាសស្តីពី «គោលការណ៍ណែនាំសម្រាប់ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន» និងអនុក្រឹត្យដែលពាក់ព័ន្ធ[៧០] នៅមានភាពមិនច្បាស់លាស់ និងមានចន្លោះប្រហោងជាច្រើនដែលធ្វើអោយរបាយការណ៍នោះមានភាពមិនគ្រប់គ្រាន់ និងមិនទាន់ពេល។ ឧទាហរណ៍ អនុក្រឹត្យបានចែងថា ប្រសិនបើក្រសួងបរិស្ថានមិនបានឆ្លើយតបចំពោះរបាយការណ៍នៅក្នុងរយៈពេលដែលបានកំណត់ ក្រសួងដែលពាក់ព័ន្ធនឹងអាចសន្មត់ថារបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះ មានលក្ខណៈពេញលេញគ្រប់

[៦៧] Sourcebook – Laws & Regulations. MoE Paraks/49MOE/09Mar00 and RGC Anukret/72ANK_BK/11Aug99

[៦៨] Anukret on EIA Process - Art. 7 and 14.

[៦៩] Anukret on EIA Process - Art. 15 and 17; Prakas – Guideline for Conducting EIA Report. Art 6 and 7.

[៧០] Sourcebook – Laws & Regulations. MoE Paraks/49MOE/09Mar00 and RGC Anukret/72ANK_BK/11Aug99

គ្រាន់។[៧១] ទោះបីជាចន្លោះប្រហោងដ៏ធំកើតមាននៅក្នុងមាត្រា ២ នៃប្រកាសដែលលើកឡើងថា មានករណីលើកលែងចំពោះរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់ «គម្រោងជាក់លាក់ និងត្រូវការបន្ទាន់ដែលបានសម្រេចចិត្តដោយរាជរដ្ឋាភិបាល»[៧២]។ គ្មានគោលការណ៍បទបញ្ញាណាបញ្ជាក់ថាតើគម្រោងប្រភេទណា ឬអ្នកណាដែលត្រូវសន្មត់ថាវាស្ថិតក្នុង «តម្រូវការបន្ទាន់»។[៧៣]

## ១២. ការអប់រំសហគមន៍

អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានាបានផ្តល់វគ្គបណ្តុះបណ្តាលដល់សមាជិកបណ្តាញអំពី សិទ្ធិ ភាពជាអ្នកដឹកនាំ អភិបាលកិច្ចល្អ ការគ្រប់គ្រងធនធានធម្មជាតិ ការស្រាវជ្រាវជីវចម្រុះ សកម្មភាពគ្មានអំពើហិង្សា ការផ្តល់ព័ត៌មានពីសហគមន៍ និងការចងក្រងឯកសារក៏ដូចជាជួយសមាជិកបណ្តាញព្រៃឡង់ដើម្បីរៀបចំក្រុមអោយកាន់តែប្រសើរ។ ដោយសារសមាជិកបណ្តាញព្រៃឡង់កាន់តែមានសំលេងខ្លាំងឡើង អាជ្ញាធរបានបង្កើនការប្រឹងប្រែងដើម្បីបញ្ឈប់វគ្គបណ្តុះបណ្តាលនានាដល់សហគមន៍។

កាលពី ខែកញ្ញា ឆ្នាំ២០១១ មានមន្ត្រីស្រុក និងមន្ត្រីឃុំដែលមានកិច្ចការពារពីប៉ូលីសប្រដាប់ដោយអាវុធផងនោះ បានមកបញ្ឈប់វគ្គបណ្តុះបណ្តាលមួយ ក្រោយពីមានការជជែកគ្នាយ៉ាងយូររវាងតំណាងរបស់អង្គការមិនមែនរដ្ឋាភិបាល និងអភិបាលរងស្រុក។ ប៉ូលីសប្រដាប់ដោយអាវុធអាកា៤៧ បានចូលមកកន្លែងបណ្តុះបណ្តាល បើទោះជាអ្នកភូមិភាគច្រើនគឺជាស្ត្រី ហើយស្ត្រីទាំងនោះភាគច្រើនគឺជាមនុស្សចាស់ក៏ដោយ។ ការប៉ុនប៉ងផ្សេងទៀត បានធ្វើឡើងដោយការបំភិតបំភ័យផ្សេងៗដល់អ្នកភូមិដែលគ្រាន់តែពួកគេបានចូលរួមរៀនសូត្រ អំពីសិទ្ធិរបស់ពួកគេនៅក្រោមច្បាប់កម្ពុជា និងច្បាប់ដទៃទៀត។

---

[៧១] អនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន -មាត្រា ១៨។

[៧២] Prakas on the implementation on general guideline for conducting environmental impact assessment, 02 Sept 2009. (Ministry of Environment, Prakas No 376)

[៧៣] Prakas on the implementation on general guideline for conducting environmental impact assessment, 02 Sept 2009. (Ministry of Environment, Prakas No 376)

អាជ្ញាធរស្រុកបានបញ្ជាដល់អ្នកក្រោមបង្គាប់របស់ខ្លួន ឲ្យកត់ឈ្មោះរបស់អ្នកភូមិ និងថតរូបពួកគេ និងបន្ទាប់មកបានថតរូបរថយន្តដែលជាកម្មសិទ្ធិរបស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ (UN) ដែលបានបញ្ជូនក្រុមមួយមកសង្កេតការណ៍។ កាលពីដំបូង អភិបាលរងស្រុករូបនេះ បានគំរាមកំហែងចាប់ខ្លួនបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ប្រសិនបើពួកគេចាប់ផ្តើមការប្រជុំនេះ ដោយពោលថា អង្គការទាំងនេះញុះញុងអ្នកភូមិ។ ក្រោយពីជជែកគ្នាយ៉ាងយូរអំពីរឿងនេះ គាត់ក៏ចាប់ផ្តើមវិនិច្ឆ័យថាក្រុមនេះកំពុងចាត់ចែងការប្រជុំនយោបាយ ដែលជាអំពើល្មើសច្បាប់ ដោយសារតែគាត់បានឃើញពាក្យថា «សិទ្ធិមនុស្ស» នៅលើផ្ទាំងក្រណាត់មួយ ដូច្នេះក្រុមនេះត្រូវបានគេអះអាងថាពាក់ព័ន្ធនឹងគណៈបក្សសិទ្ធិមនុស្ស។

បើទោះជាផ្ទាំងក្រណាត់នោះ ត្រូវបានចាត់ទុកថាមានការដកស្រង់ពាក្យទាំងស្រុងចេញពីរដ្ឋធម្មនុញ្ញរបស់កម្ពុជាក៏ដោយ ប៉ុន្តែបន្ទាប់ពីការជជែកគ្នាយ៉ាងតឹងតែងរយៈពេលប្រមាណពីរម៉ោងមក អង្គការមិនមែនរដ្ឋាភិបាលបានសម្រេចចិត្តដកថយដោយព្យាយាមលើកការបណ្តុះបណ្តាលទៅក្នុងពេលផ្សេងវិញ។ បញ្ហានេះបានចុះផ្សាយនៅពាសពេញសារព័ត៌មានក្នុងស្រុក[៧៤]។

តាមពិតទៅ បញ្ហានេះគ្រាន់តែជាសកម្មភាពលេចធ្លោជាងគេដែលអាជ្ញាធរស្រុក និងខេត្តបានប្រឹងប្រែងរួមគ្នាដើម្បីបញ្ឈប់វគ្គបណ្តុះបណ្តាលផ្នែកច្បាប់ និងការជួបជុំផ្សេងៗជាមួយសហគមន៍ នៅក្នុងកន្លែងនានាក្នុងតំបន់ព្រៃឡង់ តាំងពីប៉ុន្មានខែមុនមកម្ល៉េះ។ សមាជិកបណ្តាញសហគមន៍ព្រៃឡង់បានពន្យល់ថា ប្រធានភូមិបានទទួលបញ្ជាពីអាជ្ញាធរមូលដ្ឋាន ឲ្យរារាំងរាល់ការប្រជុំនៅក្នុងសហគមន៍របស់ពួកគេ ហើយព្រះសង្ឃក៏បានទទួលបញ្ជាផងដែរ មិនអនុញ្ញាតឲ្យមានការប្រជុំនៅក្នុងបរិវេណវត្តឡើយ។

## ១៣. បណ្តាញសហគមន៍ព្រៃឡង់

សកម្មភាពរបស់សហគមន៍បានកកើតឡើងដំបូងនៅដើមឆ្នាំ២០០០ នៅក្នុងព្រៃឡង់។ គោលបំណងនៃការបង្កើតបណ្តាញនេះ ទីមួយគឺទប់ស្កាត់ការកាប់ព្រៃ

[៧៤] http://www.cchrcambodia.org/admin/media/news/news/english/2011_09_07_indigenouspeoplesissues.pdf

សម្បទាន និងទីពីរឆ្លើយតបទៅនឹងសម្បទានដីដូចជានៅតំបន់ទំរីងដែលសហគមន៍ត្រូវគេបំពាន។ សហគមន៍បានចាប់ផ្តើមចងក្រងក្រុមរបស់ពួកគេ ដើម្បីធ្វើការតស៊ូមតិការពារព្រៃឈើ ហើយនៅឆ្នាំ២០០៧ «បណ្តាញសហគមន៍ព្រៃឡង់» ត្រូវបានបង្កើតឡើង។ សហគមន៍នីមួយៗបានចាប់ផ្តើមដឹងថាពួកគេត្រូវធ្វើការជាមួយគ្នា ដោយហេតុថា តំបន់មួយអាចមិនជួបបញ្ហាដោយផ្ទាល់ក៏ដោយ តែការបាត់បង់ព្រៃឈើនៅកន្លែងផ្សេងទៀត ក៏អាចនឹងបង្កផលប៉ះពាល់ដល់ពួកគាត់ផងដែរ។

ទោះជាមានការជួយពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក តែបណ្តាញនេះឥឡូវអាចដំណើរការដោយខ្លួនឯងបាន ដោយមានក្រុមស្នូលដែលមានអ្នកដឹកនាំចំនួន២០នាក់ ដែលបានជ្រើសរើសដោយការបោះឆ្នោតពីខេត្តទាំងបួននៃតំបន់ព្រៃឡង់ (៥នាក់ក្នុងមួយខេត្ត)។ ក្រុមស្នូលដឹកនាំអ្នកតំណាងសមាជិកចំនួន១០០នាក់ ដែលបានចងក្រងនៅកម្រិតសហគមន៍។ បណ្តាញសហគមន៍ព្រៃឡង់បានរួបរួមគ្នាជាមួយបណ្តាញសហគមន៍សន្តិភាព (CPN) ដោយពួកគេទទួលបានថវិការ និងការគាំទ្របច្ចេកទេសខ្លះពីបណ្តាញនេះ។ បណ្តាញទាំងពីរនេះមានទំនាក់ទំនងជាមួយសមាជិកសកម្មសិទ្ធិជនជាតិដើមភាគតិច និងសមាជិកមិត្តនៃព្រៃឈើ ដែលជាសម្ព័ន្ធមិនមែនផ្លូវការនៃក្រុមនៅមូលដ្ឋាន និងអង្គការតូចៗនានាដែលធ្វើការងារតស៊ូមតិដើម្បីព្រៃឡង់ និងបញ្ហាបរិស្ថានដែលពាក់ព័ន្ធនានា។

សមាជិកបណ្តាញបាន និងកំពុងធ្វើការល្បាតជាទៀងទាត់មួយរយៈមកហើយ ហើយនៅក្នុងឆ្នាំនេះ នឹងចាប់ផ្តើមពិនិត្យតាមដានអំពីការបាត់បង់ដើមច្បោះក្នុងចំណោមសហគមន៍នៅក្នុងខេត្តទាំងបួននៃតំបន់ព្រៃឡង់។[៧៥] ការលេចឡើងនៃក្រុមហ៊ុនសម្បទានសេដ្ឋកិច្ច CRCK នៅស្រុកសណ្តាន់ បានជម្រុញឲ្យសមាជិកបណ្តាញនេះ ប្រឹងប្រែងបន្ថែមទៀតក្នុងការនាំយកបញ្ហាព្រៃឡង់ ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់សហគមន៍ជាតិ និងអន្តរជាតិ។ ក្រុមបណ្តាញសហគមន៍ព្រៃឡង់បានបង្កើនការល្បាតព្រៃរបស់ពួកគេ ដោយរឹបអូសយករណាយន្តជាច្រើនសឹបគ្រឿងពីអ្នកកាប់ឈើល្មើសច្បាប់ ហើយយកព័ត៌មានលំអិតពីពួកអ្នកកាប់ឈើល្មើស

[៧៥] សូមមើលលំអិតនៅផ្នែកលទ្ធផលស្រាវជ្រាវនៅក្នុងរបាយការណ៍នេះ

ច្បាប់ទាំងនោះ មុននឹងដោះលែងពួកគេទៅវិញ ដោយសារសមាជិកបណ្ដាញពុំមានសិទ្ធិអំណាចក្នុងការចាប់ខ្លួនជនល្មើស។ កាលពីដំបូង ពួកគេបានព្យាយាមធ្វើការជាមួយប៉ុស្ដិ៍រដ្ឋបាលព្រៃឈើនៅស្រុកសណ្ដាន់ និងបានបញ្ជូនរណាយន្តជាច្រើនគ្រឿងជាមួយអ្នកកាប់ឈើមួយចំនួនទៅប៉ុស្ដិ៍រដ្ឋបាលព្រៃឈើ មុននឹងពួកគេបោះបង់កិច្ចសហការនេះ ដោយសារតែមន្ត្រីរដ្ឋបាលព្រៃឈើមិនចាត់វិធានការចំពោះបញ្ហានេះ ហើយនឹងមានការឃុបឃិតគ្នាជាមួយអ្នកកាប់ឈើទៀត។[៧៦]

នៅក្នុងឆ្នាំ២០១០ បណ្ដាញនេះបានដាក់ញត្តិទៅស្ថាប័នរាជរដ្ឋាភិបាល រួមទាំងរដ្ឋសភាជាតិ ដើម្បីស្នើសុំអោយរដ្ឋាភិបាលបញ្ឈប់ដីសម្បទាន និងផ្ដល់ការគាំពារដល់ព្រៃឡង់។ នៅតាមសហគមន៍ជាច្រើន សមាជិកបណ្ដាញបានរួបរួមកម្លាំងគ្នាដើម្បីចូលរួមក្នុងដំណើរការអភិបាលកិច្ចរបស់ឃុំ រួមមានផែនការឃុំ និងភ្ជាប់ទំនាក់ទំនងជាមួយមេភូមិ និងក្រុមប្រឹក្សាឃុំដើម្បីដាក់ពាក្យបណ្ដឹង ក៏ដូចជារាយការណ៍ពីសកម្មភាពនានាដែលពួកគេបានធ្វើ ក្នុងគោលបំណងការពារព្រៃឈើ និងរៀបចំគោលគំនិត និងការអភិវឌ្ឍផ្សេងៗដែលពាក់ព័ន្ធ។ ទោះបីជា ដំណើការភ្ជាប់ទំនាក់ទំនងនៅថ្នាក់មូលដ្ឋានមានភាពល្អប្រសើរក្ដី ប៉ុន្តែ មិនមានចំណាត់ការពីកម្រិតណាមួយក្នុងការដោះស្រាយពាក្យបណ្ដឹងនោះឡើយ។ នៅក្នុងអំឡុងឆ្នាំ ២០១១ មានការជំទាស់ជាច្រើន និងមានសន្និសីទការសែតពីសំណាក់សហគមន៍ព្រៃឈើ និងកសិករនៅទូទាំងប្រទេសប្រឆាំងនឹងការអភិវឌ្ឍនានា ដែលគំរាមកំហែងចំពោះការចិញ្ចឹមជីវិត និងសន្តិសុខរបស់ពួកគេ។ បណ្ដាញសហគមន៍ព្រៃឡង់បាននាំមុខនៅក្នុងការជំទាស់មួយនៅទីតាំងក្រុមហ៊ុន CRCK កាលពីខែកុម្ភៈ ដែលមានអ្នកភូមិប្រមាណ៤០០នាក់ មកពីទូទាំងតំបន់ព្រៃឡង់ដែលបានចំណាយរយៈពេល២ថ្ងៃ នៅក្នុងការប្រឈមមុខដាក់គ្នាមួយជាមួយយោធា ប៉ូលីស និងមន្ត្រីមូលដ្ឋាន។ ព្រឹត្តិការណ៍នេះត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដោយសារតែវិធីដែលមន្ត្រីមូលដ្ឋានឆ្លើយតបតាមរយៈការគំរាមកំហែង និងការបំភិតបំភ័យ និងការមិនអនុញ្ញាតអោយអ្នកភូមិចូលប្រើប្រាស់ទឹក ដែលបានឈានដល់ការផ្ទុះជាបាតុកម្ម។

---

[៧៦] សូមមើលលំអិតនៅក្នុងសកម្មភាពរបស់រដ្ឋបាលព្រៃឈើ

បាតុកម្មនេះបានធ្វើអោយមានសន្និសីទនៅទីក្រុងភ្នំពេញ ដែលដឹកនាំដោយសមាជិកបណ្តាញ ហើយបានទាក់ទាញចំណាប់អារម្មណ៍យ៉ាងច្រើន។

នៅខែឧសភា ឆ្នាំ២០១១ បណ្តាញនេះបានដឹកនាំអ្នកតវ៉ាចូលមកក្រុងភ្នំពេញដែលមានអ្នកភូមិប្រមាណ២០០នាក់ ដែលមានទាំងសមាជិកបណ្តាញព្រៃឡង់ និងអ្នកគាំទ្រនៅភ្នំពេញខ្លះ ដោយមានសម្លៀកបំពាក់ដូចក្នុងភាពយន្ត «អវតា» របស់ ជេម កាមេរូន ដែលមានបញ្ចាំងថ្មីៗនេះ។ អ្នកភូមិប្រគុំតន្រ្តីប្រពៃណី សូត្រកំណាព្យ និងច្រៀង ទន្ទឹមនឹងការបង្ហាញពីវប្បធម៌របស់ពួកគេ នៅក្នុងពេលប្រមូលហត្ថលេខាដើម្បីធ្វើញត្តិសម្រាប់សង្គ្រោះព្រៃឈើ។

ថ្វីបើបាតុកម្មបានធ្វើនៅទីលានសន្តិភាព ក្នុងក្រុងភ្នំពេញ ដែលជាកន្លែងមិនសូវទាក់ទាញចំណាប់អារម្មណ៍ក៏ដោយ ប៉ុន្តែបាតុកម្មនេះជាគំនិតច្នៃប្រឌិតថ្មីដែលតុបតែងដោយមានលាបពណ៌គឺជាការទាក់ទាញយ៉ាងខ្លាំង ពីសំណាក់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក និងអន្តរជាតិ ក៏ដូចជាប្រជាជនដែលរស់នៅភ្នំពេញ។ ការតវ៉ានេះមានភាពជោគជ័យធំធេងណាស់ក្នុងការបង្កើនការយល់ដឹង ហើយនៅ ថ្ងៃទី៣០ ខែឧសភា សមាជិករដ្ឋសភាពីគណៈបក្សសមរង្ស៊ី បានផ្ញើលិខិតមួយច្បាប់ទៅនាយករដ្ឋមន្ត្រីស្នើសុំឲ្យលុបចោលរាល់ដីសម្បទានសេដ្ឋកិច្ចនៅក្នុងតំបន់ព្រៃឡង់ តាមការទាមទាររបស់សាធារណជន ដោយសារតែបញ្ហានេះ និងយោងទៅលើញត្តិដែលមានហត្ថលេខាគាំទ្រចំនួនច្រើនជាង ៣០,០០០នាក់។

ក្រុមអ្នកស្លៀកពាក់ដូច «អវតា» បានវិលត្រឡប់មកភ្នំពេញម្តងទៀតនៅខែសីហា ដោយបានបន់ស្រន់នៅព្រះអង្គដងកើ។ ក្រោយមក សកម្មជនប្រមាណ ១០០នាក់ ត្រូវបានឃាត់ខ្លួនមួយរយៈពេលខ្លី ដោយសារបានចែកចាយខិត្តប័ណ្ណដែលស្នើសុំឲ្យរដ្ឋាភិបាលសង្គ្រោះព្រៃឈើ។ នៅខែធ្នូ សមាជិកក្រុម «អវតា» ប្រមាណ២០០នាក់ បានធ្វើបាតុកម្មនៅខេត្តសៀមរាប ដែលពួកគេបានបួងសួងសូមឲ្យមានកិច្ចការពារព្រៃឈើនៅក្នុងពិធីមួយនៅប្រាសាទបាយ័ន។ ការបួងសួងនេះបានធ្វើឡើងក្រោយពីបានចរចាជាមួយប៉ូលីស ដែលកាលពីដំបូងបានឃាត់ខ្លួនសកម្មជនខ្លះៗ និងរារាំងអ្នកតវ៉ាមិនឲ្យចូលក្នុងប្រាសាទ។ ប៉ូលីសបានយល់ព្រម

អនុញ្ញាតឲ្យអ្នកភូមិធ្វើពិធីបួងសួងក្រោយពីបាតុករបានទទូចដោយសន្តិវិធី អំពីសិទ្ធិរបស់ខ្លួនក្នុងការធ្វើពិធីបួងសួងដោយយោងទៅលើរដ្ឋធម្មនុញ្ញកម្ពុជា។ អ្នកតវ៉ា «អវតា» បានផ្តល់នូវប្រសិទ្ធភាពខ្ពស់ក្នុងការបង្កើនការយល់ដឹង និងត្រូវបានផ្សព្វផ្សាយទូលំទូលាយនៅក្នុងប្រព័ន្ធព័ត៌មានក្នុងប្រទេសនៅតាមអ៊ីនធឺណិត និងនៅតាមទូរទស្សន៍អន្តរជាតិផងដែរ។[៧៧]

ការតវ៉ាជាលើកទីពីរនៅទីតាំងក្រុមហ៊ុន CRCK បានកើតឡើងនៅពាក់កណ្តាលខែវិច្ឆិកា ដែលមានអ្នកចូលរួមប្រមាណ៣០០នាក់ មកពីខេត្តទាំងបួន។ លើកនេះ ប្រព័ន្ធព័ត៌មានបានមកយកព័ត៌មានដោយមានអ្នកថតរូបក្នុងស្រុក និងក្រុមមួយមកពីទូរទស្សន៍អាល់ហ្សាហ្សេរ៉ាផងដែរ។ ក្រុមទូរទស្សន៍នេះបានសម្ភាសន៍អ្នកភូមិមួយរូបដែលបានពោលថា គាត់បានដើររយៈពេល៩ថ្ងៃ មកពីស្រុកថាឡាបរិវ៉ាត់ នៅក្នុងខេត្តស្ទឹងត្រែងដើម្បីមកដល់ទីនោះ។ នៅក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងមកក្រុមហ៊ុននេះ និងអាជ្ញាធរនានាបានដឹងអំពីគម្រោងបាតុកម្មនេះ និងបានបញ្ជូនប៉ូលីសតាមរថយន្តជាច្រើន នៅក្នុងការប៉ុនប៉ងបញ្ឈប់ក្រុមបាតុករមិនឲ្យមកដល់ក្រុមហ៊ុននេះ។ ប្រជាពលរដ្ឋនៅក្នុងសហគមន៍ដែលស្ថិតនៅជិតទីតាំងដីសម្បទាននេះបានរាយការណ៍ថា ពួកគេបានទទួលការព្រមានមិនឲ្យចូលរួមនៅក្នុងបាតុកម្មនេះ ពីសំណាក់អាជ្ញាធរមូលដ្ឋាន ដែលបានអះអាងថានឹងបញ្ជូនប៉ូលីសចំនួន៤០០នាក់ មកបញ្ឈប់ការតវ៉ានេះ។ ជាក់ស្តែង មាននគរបាលចំនួនជិត ៥០នាក់ប៉ុណ្ណោះ។

ក្រុមនេះបានមកដល់ទីតាំងនេះនៅវេលាល្ងាច ក្រោយចំណាយពេលពីរថ្ងៃដើម្បីព្យាយាមគេចពីប៉ូលីសដែលប៉ូលីសទាំងនេះជាច្រើន បានរង់ចាំក្នុងព្រៃនៅជុំវិញទីតាំងព្រៃសម្បទាននេះ។ នៅត្រង់ច្រកចូល មានប៉ូលីសដែលគ្មានអាវុធចំនួនប្រមាណ ២០នាក់ កំពុងរង់ចាំទប់ទល់ជាមួយអ្នកតវ៉ា។

កាលពីថ្ងៃមុន នៅពេលដែលអ្នកស្រាវជ្រាវបានមកដល់ទីតាំងក្រុមហ៊ុន CRCK ជាមួយក្រុមអ្នកយកព័ត៌មានទូរទស្សន៍អាល់ហ្សាហ្សេរ៉ា និងអ្នកយកព័ត៌មាន

---

[៧៧] ព័ត៌មាននេះត្រូវបានផ្សព្វផ្សាយជាទូទៅនៅក្នុងសារព័ត៌មានក្នុងស្រុក ដែលរួមទាំង ព័ត៌មាននេះដែលស្រង់ចេញពីរបាយការណ៍ ភ្នំពេញប៉ុស្តិ៍ http://mouthtosource.org/rivers/preylang/2011/05/31/cancel-prey-lang-grants-srp/

កម្ពុជា ប៉ូលីសទាំងនេះមានប្រដាប់ដោយអាវុធអាកា៤៧ ដូច្នេះ អាចមានអ្នកណាម្នាក់បង្គាប់ពួកគេឲ្យទុកអាវុធនៅទីកំបាំងណាមួយ។ អ្នកតវ៉ាបានទាមទារដើម្បីនិយាយជាមួយតំណាងក្រុមហ៊ុន តែត្រូវបានប៉ូលីសប្រាប់ថា នឹងមានអ្នកណាម្នាក់មកនិយាយជាមួយក្នុងពេល៧នាទីខាងមុខ។ បន្ទាប់មកបាតុករនិយាយថាប្រសិនបើគ្មានអ្នកណាមកក្នុងពេល៧នាទី ពួកគេនឹងចូលក្នុងទីតាំងនេះដើម្បីពិនិត្យដោយខ្លួនឯង។ ប្រាំពីរនាទីក្រោយមក និងក្រោយមានការរុញច្រានគ្នាបន្តិចមក ប៉ូលីសបានឈរទៅម្ខាង ក្នុងពេលដែលអ្នកភូមិចូលតាមច្រកទ្វារទៅក្នុងទីតាំងសម្បទាននេះជាមួយសម្លេងបន្ទរព្រមៗគ្នា។ ពួកគេបានដើរសំដៅទៅរោងអារឈើមួយនៅចម្ងាយប៉ុន្មានគីឡូម៉ែត្រនៅម្ខាងនៃទីតាំងសម្បទាននេះ។ នៅពេលដែលអ្នកតវ៉ាបានចូលក្នុងទីតាំងសម្បទាន គេបានឃើញថ្នាលបណ្តុះកូនឈើមួយដែលមានទំហំប្រមាណ១ហិកតា និងហួសពីនោះបន្តិចនៅលើដីទំហំប្រហែលគ្នានេះមានកូនកៅស៊ូជាច្រើនជួរត្រូវបានភ្ជួរចោលកប់ទៅក្នុងដីវិញ។ នៅពេលយប់មកដល់ អ្នកភូមិបន្តចូលទៅក្នុងរោងអារឈើ មុននឹងវិលត្រឡប់មកច្រកទ្វារវិញ និងចាកចេញពីទីនោះ។

ការតវ៉ារបស់បណ្តាញសហគមន៍ព្រៃឡង់ ត្រូវបានគេមើលឃើញនៅទូទាំងប្រទេសកម្ពុជា និងទំនងជាបានលើកទឹកចិត្តឲ្យមានការតវ៉ាផ្សេងទៀតប្រឆាំងនឹងក្រុមហ៊ុនសម្បទាននៅខេត្តក្រចេះ កំពង់ស្ពឺ និងពោសាត់ផងដែរ នៅចុងឆ្នាំ២០១១។ នៅពេលថ្មីៗនេះ កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១១ សារព័ត៌មានខេមបូឌាដេលី បានរាយការណ៍អំពីការតវ៉ាមួយផ្សេងទៀតនៅព្រៃឡង់ក្នុងស្រុករវៀង ដែលលើកនេះទាក់ទងជាមួយការហាមឃាត់ការធ្វើអាជីវកម្មរ៉ែមាសខ្នាតតូច ជាលក្ខណៈសិប្បកម្មពីសំណាក់ប្រជាពលរដ្ឋមូលដ្ឋានដែលត្រូវគេចោទប្រកាន់ថា មន្ត្រីស្រុកបានឃុបឃិតជាមួយក្រុមហ៊ុនមួយដែលបច្ចុប្បន្ននេះកំពុងធ្វើអាជីវកម្មនៅទៅតាំងនោះ។

# ជំពូកទី២: វិធីសាស្ត្រស្រាវជ្រាវ

## ១. គោលបំណង

គោលបំណងនៃការសិក្សានេះ គឺផ្តល់នូវការវិភាគអំពីការប្រើប្រាស់អនុផលពីព្រៃឈើរបស់ប្រជាជនមូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិចនៅតំបន់ព្រៃឡង់ និងប៉ាន់ប្រមាណពីផលប៉ះពាល់ដែលពួកគេជួបប្រទះដោយសារការអភិវឌ្ឍនានា នៅក្នុង និងជុំវិញតំបន់ព្រៃឡង់។ លើសពីនេះ ការសិក្សានេះក៏ចង់ស្វែងយល់ផងដែរ អំពីការគ្រប់គ្រងធនធានធម្មជាតិនៅទូទាំងតំបន់ព្រៃឡង់ ហើយលើកជាសំណើ និងអនុសាសន៍ទៅកាន់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីផ្តល់ជាប្រយោជន៍ទៅដល់ប្រជាជននៅតំបន់ព្រៃឡង់ និងដើម្បីជាការឆ្លើយតបទៅនឹងវេទិកាអចិន្ត្រៃយ៍សហប្រជាជាតិ ស្តីពីកិច្ចការជនជាតិដើមភាគតិច។[៧៨]

## ២. ដែនកំណត់នៃការសិក្សា

ការសិក្សាស្រាវជ្រាវនេះ បានកំណត់ការចុះស្ទង់មតិនៅក្នុងតំបន់ដែលលេចធ្លោជាងគេចំនួនពីរ ដោយសារមិនអាចចុះទៅស្ទង់មតិស៊ីជម្រៅនៅទូទាំងបួនខេត្តនៃតំបន់ព្រៃឡង់ទាំងមូល។ ព្រៃឡង់គ្របដណ្តប់តំបន់ធំទូលាយដែលមានការលំបាកចេញចូល សូម្បីតែនៅពាក់កណ្តាលរដូវប្រាំងក៏ដោយ។ នៅក្នុងអំឡុងពេលដែលកម្ពុជាប្រឈមនឹងទឹកជំនន់ឆ្នាំ២០១១ ដែលជន់លិចតំបន់ព្រៃឡង់ក្នុងវិសាលភាពធំធេង ការធ្វើដំណើរស្ទើរតែមិនអាចប្រព្រឹត្តទៅបានផងនៅក្នុងទីកន្លែងខ្លះៗ ដែលធ្វើឲ្យដំណើរការសម្ភាសបានប្រព្រឹត្តទៅយឺតយ៉ាវ និងការចំណាយក៏កើនឡើងផងដែរ។ ដោយសារសហគមន៍ភាគច្រើនដែលពឹងផ្អែកលើព្រៃឈើនៅកម្ពុជា នៅក្នុងរដូវណាមួយនោះ អ្នកភូមិស្ទើរតែទាំងអស់អាចចាកចេញពីភូមិរយៈពេលជាច្រើនសប្តាហ៍នៅក្នុងពេលមួយ។ ទន្ទឹមនឹងនេះ អ្នកភូមិស្ទើរតែគ្រប់គ្នាទៅចំការវិលជុំ ឬប្រមូលអនុផលព្រៃឈើខ្លះៗ ដូចជានៅក្នុងអំឡុងរដូវមានផ្លែឈើ។ បើទោះជាការ

---

[៧៨] United Nations Permanent Forum on Indigenous Issues

អង្កេតនេះបានធ្វើឡើងតែក្នុងតំបន់មួយចំនួនក៏ដោយ ប៉ុន្តែលទ្ធផលនៃការសិក្សានេះមានលក្ខណៈជាតំណាងសមស្របអំពីការប្រើប្រាស់ដីព្រៃ និងធនធានធម្មជាតិពីសំណាក់សហគមន៍នៅក្នុងតំបន់ព្រៃឡង់។

## ៣. ការជ្រើសរើសតំបន់គោលដៅ

តំបន់គោលដៅដែលមានសក្តានុពល ត្រូវបានអ្នកស្រាវជ្រាវកំណត់អត្តសញ្ញាណក្រោយពីបានពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ។ តំបន់អង្កេតចំនួនពីរត្រូវបាជ្រើសរើសនៅក្នុងស្រុកសណ្ដាន់នៃខេត្តកំពង់ធំ និងនៅស្រុកថាឡាបរិវ៉ាត់នៃខេត្តស្ទឹងត្រែង។ ដូចដែលបានឃើញពីខាងដើមនៅក្នុងរបាយការណ៍នេះ ស្រុកសណ្ដាន់គឺជាចំនុចកណ្ដាលនៃការតវ៉ាថ្មីៗនេះ និងជាទីតាំងដែលមានការបាត់បង់ព្រៃឈើក្នុងទ្រង់ទ្រាយធំ ដោយសារតែសម្បទានដីសេដ្ឋកិច្ចដែលផ្ដល់ដោយរដ្ឋាភិបាល។ សម្បទានដីនៅទីនេះក៏ពង្រីកជាបន្ថែមចូលទៅក្នុងតំបន់ព្រៃឡង់ច្រើនជាងដីសម្បទានសេដ្ឋកិច្ចផ្សេងទៀតទាំងអស់ដែលគេបានដឹង នៅក្នុងពេលបច្ចុប្បន្ន ដែលបង្កផលប៉ះពាល់ដល់សហគមន៍ជាច្រើន។ សហគមន៍គោលដៅនានានៅស្រុកថាឡាបរិវ៉ាត់ រួមមានភូមិស្គង់ផងដែរ។ ការជ្រើសយកទីនេះមានសារៈសំខាន់ណាស់ ដោយសារភូមិស្គង់តំណាងឲ្យសហគមន៍មួយចំនួនតូចដែលមិនមានទំនាស់ជាមួយភាគីណាមួយឡើយក្នុងការដែលស្ថិតនៅក្នុងព្រៃឡង់នេះ។ ហេតុផលជាក់លាក់មួយផ្សេងទៀត នៃការជ្រើសរើសស្រុកថាឡាបរិវ៉ាត់មកសម្ភាសន៍គឺដើម្បីពិនិត្យមើលកំណើននៃការរានឆ្ការយកដីដោយល្មើសច្បាប់ និងជនចំណាកស្រុក។




ផែនទី ៦: ទីតាំងនៃកន្លែងអង្កេត

តារាងទី៤: តំបន់គោលដៅនៃការសិក្សា

| ខេត្ត | កំពង់ធំ | ស្ទឹងត្រែង |
|---|---|---|
| ស្រុក | សណ្ដាន់ | ថាឡាបរិវ៉ាត់ |
| ភូមិ | ១-ឈូក | ១-ស្ពង់ |
| | ២-សំពរ | ២-វាលពោធិ៍ |
| | ៣-ស្រែវាល | ៣-អន្លង់ពែរ |
| | | ៤-ទូល |
| | | ៥-រំដៀង |

## ៤. ការជ្រើសរើសសំណាក និងចុះសិក្សានៅមូលដ្ឋាន

ដោយសារស្រុកសណ្ដាន់ គឺជាតំបន់ដែលធ្លាប់មានបញ្ហាច្រើននៅក្នុងតំបន់ព្រៃឡង់ ការសិក្សានេះបានធ្វើការសម្ភាសនៅក្នុងសហគមន៍ចំនួនបី ដូចជា ភូមិស្រែវាល ភូមិសំពរ និងភូមិឈូក ដែលទទួលរងឥទ្ធិពលខ្លាំងបំផុតពីការអភិវឌ្ឍនានា។

ហើយការសម្ភាសនៅភូមិទាំងនេះបានធ្វើឡើង នៅថ្ងៃ ទី១១ ដល់ ១៤ ខែវិច្ឆិកា ឆ្នាំ២០១១។ ហើយការចុះប្រមូលព័ត៌មានបន្ថែមបានចាប់ផ្តើមពីថ្ងៃទី ២៥ ខែវិច្ឆិកា ដល់ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ នៅភាគខាងជើងនៃតំបន់ព្រៃឡង់ ដែលផ្តោតសំខាន់លើភូមិស្តង់ ភូមិវាលពោធិ៍ និងភូមិទូល។

**-ស្រុកសណ្តាន់ ខេត្តកំពង់ធំ**

អ្នកស្រាវជ្រាវបានគ្រោងសម្ភាសន៍ចំនួន២០គ្រួសារ នៅក្នុងសហគមន៍នីមួយៗ ប៉ុន្តែដោយសារតែសមាជិកភាគច្រើននៅក្នុងសហគមន៍មិននៅក្នុងភូមិ ឬមួយទៅចំការ ឬប្រមូលអនុផលព្រៃឈើ ចំនួនគ្រួសារដែលត្រូវបានសម្ភាសន៍ ត្រូវបានបន្ថយមកត្រឹមតែ១០គ្រួសារ ក្នុងសហគមន៍នីមួយៗ។ ក្រៅពីនេះក៏មាន ការពិភាក្សាចំនួនបីក្រុមផងដែរ ដែលមានអ្នកចូលរួមពី៥ទៅ៨នាក់ក្នុងមួយក្រុមពិភាក្សា។ ការស្រាវជ្រាវនេះ មានសំណួរដាច់ដោយឡែកសម្រាប់អ្នកភូមិ និងសម្រាប់អាជ្ញាធរមូលដ្ឋាន ដោយផ្តោតលើការប្រើប្រាស់អនុផលព្រៃឈើ ជាពិសេសស ដើមច្បោះ និងឥទ្ធិពលនៃការអភិវឌ្ឍនានា ក៏ដូចជាប្រសិទ្ធភាព និងកិច្ចសហប្រតិបត្តិការរបស់អាជ្ញាធរមូលដ្ឋាន និងសកម្មភាពរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងចំណេះដឹងអំពីសិទ្ធិរបស់ពួកគេនៅក្រោមរដ្ឋធម្មនុញ្ញកម្ពុជាផងដែរ។ ពីដំបូងមានការគ្រោងសម្ភាសន៍ប្រធានភូមិទាំងអស់ និងប្រសិនបើអាចធ្វើបានក៏អាចសម្ភាសន៍មន្ត្រីឃុំ និងមន្ត្រីស្រុកផងដែរ ប៉ុន្តែដោយសារតែបាតុកម្ម ក្រុមស្រាវជ្រាវអាចសម្ភាសន៍បានតែប្រធានភូមិមួយរូបប៉ុណ្ណោះ។ ដោយសារតែបញ្ហានានាដែលបានកត់សម្គាល់ពីខាងដើម នៅទីបំផុត មានការសម្ភាសត្រឹមតែ ២៨គ្រួសារ (១០% នៃចំនួនគ្រួសារនៅក្នុងសហគមន៍ចំនួនបីប៉ុណ្ណោះ) ដែលបានធ្វើឡើង ហើយមានមនុស្សចំនួន១៩នាក់ផ្សេងទៀតបានចូលរួមនៅក្នុងការពិភាក្សាទាំងបីក្រុម។ ទោះបីនេះជាតួលេខភាគរយទាបក៏ដោយ ទិន្នន័យដែលប្រមូលបានជាច្រើនពិតជាមានទំនាក់ទំនងជាមួយវត្តមាននៃទិន្នន័យដែលមានស្រាប់បច្ចុប្បន្ន និងជាមួយលទ្ធផលដែលបានមកពីការអង្កេតលើកទី២ ដូច្នេះ យើងមានហេតុផលសមស្របដែលអាចផ្តល់ទំនុកចិត្តថា ចំនួនដែលបានជ្រើសរើសយកមានលក្ខណ:តំណាងសមរម្យ។

## -ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង

អ្នកស្រាវជ្រាវបានគ្រោងសម្ភាសន៍ចំនួន៣០គ្រួសារ (ដែលត្រូវជាប្រមាណ ៣០% នៃសមាជិកសហគមន៍នីមួយៗ) នៅក្នុងភូមិនីមួយៗ ដែលរួមទាំងមន្ត្រីនៅមូលដ្ឋានផង តាមដែលអាចធ្វើបាន។ ទាក់ទងនឹងជនចំណាកស្រុក អ្នកស្រាវជ្រាវមិនអាចកំណត់គោលដៅបានឡើយ ដោយសារមិនអាចដឹងថាក្រុមអ្នកប្រមូលទិន្នន័យនឹងអាចជួបជនចំណាកស្រុកចំនួនប៉ុន្មាននាក់ឡើយ។ មានសំណួរ ជាច្រើនដែលផ្តោតយ៉ាងសំខាន់លើអ្នកភូមិ អាជ្ញាធរមូលដ្ឋាន និងជនចំណាកស្រុក ដែលបានបង្កើតឡើង ដោយមានសំណួរបើក ក្នុងគោលដៅផ្តោតលើការប្រើប្រាស់អនុផលព្រៃឈើ ដើមច្បោះ និងឥទ្ធិពលនៃការអភិវឌ្ឍ ប្រសិទ្ធភាព និងកិច្ចសហប្រតិបត្តិការនៃអាជ្ញាធរ និងចំណេះដឹងអំពីសិទ្ធិនៅក្រោមច្បាប់កម្ពុជា។

ក្រោយធ្វើការសម្ភាសមួយចំនួននៅរំដៀងរួចមក ក្រុមអ្នកប្រមូលទិន្ន័យបានរកឃើញថា តាមពិតរំដៀង ស្ថិតនៅក្រៅអ្វីដែលអ្នកមូលដ្ឋានហៅថា ព្រៃឡង់ ហើយអ្នកភូមិភាគច្រើនបំផុតគឺជាកសិករធ្វើស្រែ និងដាំដំឡូវមី។ គ្មានអ្នកណាម្នាក់មានទំនាក់ទំនងច្រើនជាមួយព្រៃឡង់ឡើយ បើទោះជាអ្នកទាំងនេះភាគច្រើនប្រើប្រាស់សម្ភារៈសាងសង់ពីព្រៃនេះក៏ដោយ។ ក្រុមនេះបានបន្តដំណើរទៅភូមិវាលពោធិ៍ ដែលនៅទីនោះពួកគេបានរកឃើញស្ថានភាពប្រហាក់ប្រហែលគ្នានេះ ក្រោយពីបានរកឃើញថា មានប្រជាជនមួយចំនួនតូចប៉ុណ្ណោះដែលរកអនុផលព្រៃឈើ។ ក្រោយពីពិភាក្សាជាបន្ថែមជាមួយតំណាងពីបណ្តាញសហគមន៍ព្រៃឡង់ គេបានសម្រេចថាត្រូវធ្វើដំណើរទៅភូមិនានាដូចជាអន្លង់ពែរ និងទូលជំនួសវិញ។ ប្រការនេះបាននាំឲ្យពួកគេខាតពេលជាច្រើន ដូច្នេះ ផែនការដំបូងដែលត្រូវសម្ភាសន៍៣០គ្រួសារនៅក្នុងសហគមន៍នីមួយៗក្នុងចំណោមសហគមន៍ទាំងបី មិនអាចធ្វើតទៅទៀតបានឡើយ។លើសពីនេះ អ្នកភូមិភាគច្រើននៅឯចំការ ដូច្នេះអ្នកប្រមូលទិន្នន័យបានចំណាយពេលជាច្រើន ដើម្បីធ្វើដំណើរទៅចំការរបស់អ្នកភូមិក្នុងបំណងសម្ភាសន៍។

នៅទីបំផុត ក្រុមអ្នកប្រមូលទិន្នន័យបានសម្ភាសន៍អ្នកភូមិចំនួន៥៨នាក់ នៅទូទាំងសហគមន៍ទាំងប្រាំ និងមានការពិភាក្សាក្រុមចំនួនបីបន្ថែមទៀត ដែលមានការចូលរួមពីមនុស្សចំនួន៣២នាក់។ ភូមិស្តង់គឺជាគោលដៅសំខាន់បំផុតដែលអ្នកប្រមូលទិន្នន័យបានចាត់ចែងឲ្យមានការសម្ភាសន៍ចំនួន២០នាក់ ក៏ដូចជាការពិភាក្សាក្រុមចំនួនមួយនៅក្នុងពេលល្ងាចផងដែរ។

# ជំពូកទី៣: លទ្ធផលស្រាវជ្រាវ

## ១.ជីវភាព

### ១.១. សាសនា / ក្រុមជនជាតិដើម

ក្នុងចំណោមសហគមន៍ទាំងអស់ ដែលបានជ្រើសរើសក្នុងការស្រាវជ្រាវ សហគមន៍ទាំងអស់មានប្រជាជនជាអ្នកកាន់សាសនាព្រះពុទ្ធ ហើយមានតែភូមិមួយប៉ុណ្ណោះគឺភូមិស្រែវាល ក្នុងស្រុកសណ្តាន់ដែលបានអះអាងថាភាគច្រើនជា «ជនជាតិដើម» ដែលមានប្រជាជន៨១% ជាជនជាតិកួយ។ តំណាងសមាជិកបណ្តាញព្រៃឡង់នៅស្រុកសណ្តាន់បានពោលថា ប្រជាជនភាគច្រើននៅឃុំដងកាំបិត និងឃុំមានរិទ្ធិ គឺជាជនជាតិកួយ ប៉ុន្តែនៅកន្លែងដទៃទៀតក្នុងស្រុកសណ្តាន់ មានប្រជាជនរស់នៅចម្រុះគ្នារវាងខ្មែរ និងជនជាតិដើម។ បើទោះជាភូមិទាំងនេះមានជនជាតិកួយ ឬខ្មែរក៏ដោយ ពួកគេមានជំនឿលើព្រៃអារក្សរួមគ្នា ដែលមិនត្រូវបានចាត់ទុកថាជាទម្លាប់ទូទៅរបស់ជនជាតិខ្មែរទូទៅឡើយ។[៧៩]



រូបភាពទី ៣: ស្ត្រីជនជាតិកួយដឹកត្រីដែលទើបនេសាទបាន

ដោយមិនរាប់បញ្ចូលប្រជាជន ដែលចំណាកស្រុក អ្នកតបសម្ភាសន៍ចំនួន៩២% បានឆ្លើយថា ពួកគេប្រតិបត្តិជំនឿមូលដ្ឋានរបស់ជនជាតិដើមភាគតិច។ នៅក្នុងការពិភាក្សាក្រុមប្រជាជនចំនួន១០០% ពោលថា ពួកគេប្រតិបត្តិតាមជំនឿប្រពៃណី ក្នុងមូលដ្ឋាន។ ជាការគួរឲ្យចាប់អារម្មណ៍ លើកលែងតែភូមិស្រែវាល មានតែអ្នកឆ្លើយតបសម្ភាសន៍

---

[៧៩] ក្រុមអ្នកស្រាវជ្រាវមិនបានសាកសួរជនចំណាកស្រុកនៅភូមិទួល អំពីជំនឿប្រពៃណីឡើយ ដោយសារពួកគេមិនមែនជាអ្នករស់នៅក្នុងព្រៃឡង់ ដូច្នេះពួកគេមិនត្រូវបានរាប់បញ្ចូលនៅក្នុងការគណនាចំនួនប្រជាជនដែលជាអ្នកប្រតិបត្តិប្រពៃណីជនជាតិដើមភាគតិចឡើយ។

ចំនួន២ នាក់ បានអះអាងថាពួកគេជាជនជាតិកួយ អ្នកក្រៅពីនោះពោលថា ពួកគេជាជនជាតិខ្មែរ។ ប្រការនេះមិនអាចច្បាស់លាស់ពិតប្រាកដឡើយ ដោយហេតុថាមានសញ្ញាណអវិជ្ជមានសម្រាប់ការប្រកាសខ្លួនថាជាក្រុមជនជាតិដើមភាគតិច។ ជាញឹកញាប់ ជនជាតិដើមភាគតិចរងការមាក់ងាយពីសំណាក់ជនជាតិខ្មែរជាច្រើន និងច្រើនត្រូវគេហៅជាពាក្យប្រមាថ។ ដោយសារតែសម្ពាធនេះ អ្នកទាំងនោះជាច្រើននឹងមិនទទួលស្គាល់ដោយចំហថា ខ្លួនមកពីសហគមន៍ជនជាតិដើមភាគតិចឡើយ។ លើសពីនេះ ជនជាតិដើមភាគតិចជាច្រើនបានពោលនៅក្នុងការពិភាក្សាមិនផ្លូវការថា ពួកគេមានអារម្មណ៍ថាក្នុងនាមជាជនជាតិដើមភាគតិចបានទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមាន ចំពោះសិទ្ធិរបស់ពួកគេជាពលរដ្ឋជាជនជាតិខ្មែរ។ នេះគឺផ្ទុយពីការពិតដែលថាក្នុងនាមជាជនជាតិដើម ពួកគេគួរតែទទួលបានការអនុគ្រោះនៅក្នុងករណីនៃការទាមទារសិទ្ធិដីធ្លីជាប្រពៃណី និងសិទ្ធិដទៃទៀត ដែលមានចែងនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ។

ការបាត់បង់ព្រៃអារក្សរបស់ពួកគេ ដោយសារតែការអភិវឌ្ឍទៅអនាគត ត្រូវបានអ្នកតបសម្ភាសន៍ទាំងអស់ដែលជាអ្នកប្រតិបត្តិជំនឿជនជាតិដើម មើលឃើញថាគ្មានអ្វីក្រៅពីមហន្តរាយឡើយ។ ពួកគេអះអាងថា ទង្វើនេះនឹងបំផ្លាញសាសនារបស់ពួកគេ បង្កឲ្យមានជម្ងឺ នាំមកនូវការឈឺចាប់ដល់គ្រួសារ និងសហគមន៍ទាំងមូល និងនាំឲ្យពួកគេបាត់បង់ប្រពៃណី។ ទិដ្ឋភាពនេះនៅមិនទាន់រាប់បញ្ចូលអ្នកតបសម្ភាសន៍ដែលជាជនចំណាកស្រុកនៅឡើយទេ ប៉ុន្តែមានការកត់សម្គាល់ថា អ្នកតបសម្ភាសន៍មួយចំនួនដែលមិនបានប្រតិបត្តិជំនឿនេះ ក៏បានពោលផងដែរថា វាមានឥទ្ធិពលអវិជ្ជមានលើសហគមន៍របស់ពួកគេ។

វាជាការបង្ហាញឲ្យឃើញច្បាស់ថា សហគមន៍ជាច្រើននៅទីនេះគួរតែបានទទួលសិទ្ធិជា «ជនជាតិដើមភាគតិច» នៅក្រោមគោលការណ៍ណែនាំដែលមានស្រាប់ក្នុងច្បាប់ភូមិបាល។[៨០] សហគមន៍ខ្មែរនៅជុំវិញព្រៃឡង់រស់នៅតាមរបៀបស្ទើរតែដូចគ្នាទៅនឹងសហគមន៍ជនជាតិកួយ ដោយមានជំនឿដូចគ្នាជាច្រើន ក៏ដូចជា

[៨០] ច្បាប់ភូមិបាល ឆ្នាំ ២០០១ មាត្រា ២៣

មានការពឹងផ្អែកស្ទើរតែទាំងស្រុងលើធនធានព្រៃឈើផងដែរ។ មាត្រា ២៣ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ចែងថា «សហគមន៍ជនជាតិដើមភាគតិចគឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះនៅលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាត ទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព»។ តាមរយៈសេចក្តីអធិប្បាយនេះ ទោះបីអ្នកខ្លះអាចមិននិយាយអំពីអ្វីដែលត្រូវចាត់ទុកថាជាភាសាជនជាតិដើមភាគតិចក៏ដោយ ពួកគេមានលក្ខណៈសមស្របតាមលក្ខខណ្ឌទាំងអស់ ហើយក្នុងន័យនេះពួកគេគួរតែបានទទួលកិច្ចការពារ ដូចជា សហគមន៍ជនជាតិកួយផងដែរ។

## ១.២. អក្ខរភាព

កង្វះការអប់រំត្រូវបានអ្នកតបសម្ភាសន៍លើកឡើងជាទៀងទាត់ថា ជាបញ្ហាចំបងមួយ នៅពេលដែលពួកគេឆ្លើយទៅនឹងសំណួរនានា នៅក្នុងអំឡុងពេលនៃការអង្កេត។ សំណួរនេះមិនបានសួរទៅអ្នកតបសម្ភាសន៍នៅក្នុងភូមិចំនួនបីក្នុងស្រុកសណ្តាន់ឡើយ។

មនុស្សពេញវ័យចំនួន ៦៥% នៅក្នុងភូមិនានាក្នុងស្រុកថាឡាបរិវ៉ាត់ គឺជាអ្នកមិនចេះអក្សរ ដោយកូនរបស់អ្នកតបសម្ភាសន៍មានត្រឹមតែ ៥៥% ដែលបានទទួលការអប់រំតាមទម្រង់ណាមួយ។ តួលេខអំពីការអប់រំរបស់រំកុមារមានកម្រិតទាបខ្លាំងណាស់ និងមិនទំនងជាអាចផ្តល់ការឆ្លុះបញ្ចាំងដោយសុក្រឹត្យអំពីថាតើកុមារប៉ុន្មាននាក់ដែលពិតជាបានទទួលការសិក្សានៅតាមសាលារៀនឡើយ។ យើងមិនដឹងទេថាតើកូនរបស់អ្នកតបសម្ភាសន៍ប៉ុន្មាននាក់ស្ថិតក្នុងអាយុចូលរៀន ដូច្នេះតួលេខពិតប្រាកដអាចមានខ្ពស់ជាងនេះ។ សហគមន៍ទាំងនេះមានសាលារៀនមួយ ប៉ុន្តែនោះមិនមែនជាការធានាថាពួកគេមានគ្រូដែលធ្វើការពេញម៉ោងឡើយ ដូចក្នុងករណីនៃសហគមន៍នានានៅក្នុងតំបន់ដាច់ស្រយាលនៅទូទាំងកម្ពុជាផងដែរ ។

ជាការច្បាស់ណាស់ថា កម្រិតនៃការអប់រំមានឥទ្ធិពលជាខ្លាំងមកលើសមត្ថភាពរបស់អ្នកភូមិ ក្នុងការយល់ដឹងអំពីការពន្យល់របស់អាជ្ញាធរនានានៅក្នុងកិច្ចប្រជុំ

ទាំងឡាយ។ ដូចគ្នានេះដែរ មនុស្សជាច្រើនមិនអាចអានឯកសារនានាដែលពួកគេត្រូវផ្តិតមេដៃដើម្បីផ្តល់ជាកិច្ចព្រមព្រៀងនោះឡើយ។

## ១.៣. ការប្រើប្រាស់អនុផលព្រៃឈើ/ជ័រទឹក



រូបភាពទី ៤: អ្នកភូមិកំពុងដឹកជញ្ជូនឫស្សី

ការគណនាកម្រិត នៃការពឹងផ្អែកលើ អនុផលព្រៃឈើ ដោយយោងតាមទិន្នន័យ ដែលប្រមូលបាន ទាមទារឲ្យមានការដកចេញទិន្នន័យខ្លះ ទើបអាចបានតួលេខសុក្រឹត្យ ដោយសារទិន្នន័យមកពីភូមិរំដៀង បានធ្វើឲ្យមានភាពខុសគ្នាជាខ្លាំង។ ដូច្នេះ ប្រសិនបើយើងមិនរាប់បញ្ចូលទិន្នន័យមកពីភូមិរំដៀង ក្នុងចំណោមអ្នកតបសម្ភាសន៍ ៨៨% ដែលនៅសល់ បានពឹងផ្អែកលើអនុផលព្រៃឈើសម្រាប់ការចិញ្ចឹមជីវិត ដោយក្នុងនោះការដងជ័រគឺជាប្រភពចំបងនៃប្រាក់ចំណូលមានចំនួន៧៨%។ សម្រាប់អ្នកតបសម្ភាសន៍ភាគច្រើន ប្រាក់ចំណូលតិចតួចដែលបានពីអនុផលព្រៃឈើ ត្រូវបានប្រើប្រាស់សម្រាប់ការចំណាយសំខាន់ៗ ដូចជាទិញអំបិល និងស្បៀងអាហារដទៃទៀតដែលពុំមាននៅក្នុងមូលដ្ឋាន ឬសម្រាប់ទិញអ្វីៗផ្សេងទៀត ដូចជា ឥន្ធនៈ ឬបារីជាដើម។

ជាចម្លើយរួមសម្រាប់សហគមន៍ដែលបានជ្រើសរើសក្នុងការសិក្សាគឺថា ការបាត់បង់ព្រៃឈើនឹងធ្វើអោយខូចប្រយោជន៍ដល់ជីវភាពរស់នៅរបស់ពួកគេ។ ការរស់នៅស្ទើរតែមិនអាចបរប្រព្រឹត្តទៅបានដោយគ្មានប្រាក់ចំណូល សន្តិសុខស្បៀង សម្ភារៈសាងសង់ ឱសថ និងគ្មានអ្វីមន្សល់សម្រាប់កូនចៅជំនាន់ក្រោយ។

តួលេខសរុបដែលបានពីការអង្កេតនានា ពិតជាឆ្លើយតបយ៉ាងច្បាស់ទៅនឹងតួលេខ៨០% ដែលបានស្នើឡើងពីខាងដើម អំពីការពឹងផ្អែកលើការដងជ័រ (MacDonald 2004)។ ការបាត់បង់ព្រៃឈើនឹងមានឥទ្ធិពលជាមហន្តរាយមកលើស

ហាគមន៍ទាំងអស់នេះ ហើយគ្មានហេតុផលណាមួយដែលត្រូវសង្ស័យទេដែលថាវានឹងមានឥទ្ធិពលមកលើសហាគមន៍ដទៃទៀតក្នុងតំបន់ព្រៃឡង់តាមកម្រិតខុសៗគ្នា។ លទ្ធផលបង្ហាញថា អ្នកភូមិច្រើនជាង ៨០% នៅក្នុងសហាគមន៍ទាំងនេះពឹងផ្អែកស្ទើរតែទាំងស្រុងលើអនុផលព្រៃឈើជាប្រភពប្រាក់ចំណូល ក្នុងនោះការដងជ័រគឺជាប្រភពចំណូលចំបង មានយ៉ាងហោចណាស់៧៥% នៃអ្នកភូមិទាំងអស់នៅក្នុងតំបន់ព្រៃឡង់។

គួរកត់សម្គាល់ថា អ្នកស្រាវជ្រាវចាប់អារម្មណ៍ថា អ្នកនាំផ្លូវម្នាក់នៅក្នុងសហគមន៍នៅសណ្ដាន់អាចមានឥទ្ធិពលមកលើលទ្ធផលទាំងនោះ ដោយអាចនាំផ្លូវក្រុមអ្នកស្រាវជ្រាវ ទៅរកអ្នកភូមិដែលរងគ្រោះដោយសារក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយ ដោយសារអ្នកតបសម្ភាសន៍ទាំងអស់ លើកលែងតែម្នាក់នៅក្នុងសហាគមន៍នោះ ដែលមិនពឹងផ្អែកលើអនុផលព្រៃឈើ វាធ្វើអោយតួលេខនេះមានភាពទាបជាងគេក្នុងចំណោមភូមិទាំងបី។ ដូច្នេះ មានការចាប់អារម្មណ៍ថាអ្នកនាំផ្លូវពុំមានឥទ្ធិពលច្រើនឡើយមកលើលទ្ធផលនេះ ទោះបីការសង្ស័យរបស់អ្នកស្រាវជ្រាវអាចត្រូវក៏ដោយ។

ទាក់ទងនឹងការដាំដំណាំស្រូវ គ្មានអ្នកណាម្នាក់ក្នុងចំណោមអ្នកតបសម្ភាសន៍ចំនួន ៥៨% ដែលជាអ្នកដាំស្រូវ និងរកជ័រ អាចដាំស្រូវបានគ្រប់គ្រាន់សម្រាប់ផ្ដល់ជាប្រភពប្រាក់ចំណូលឡើយ។ លើសពីនេះ ប្រជាកសិករជាច្រើនដែលដាំដំណាំស្រូវនៅលើដីចំការវិលជុំ ធ្វើឲ្យពួកគេពឹងផ្អែកលើព្រៃឈើស្ទើរតែ ១០០%។ រវាងសហាគមន៍ខ្មែរ និងសហាគមន៍ជនជាតិកួយ គេពុំឃើញមានភាពខុសគ្នាច្រើនឡើយ ទាក់ទងនឹងការប្រើប្រាស់ធនធានព្រៃឈើ។ ក្នុងន័យនេះ គេមានហេតុផលសមស្របដើម្បីជឿថា សូម្បីតែមានការអង្កេតធំធេងច្រើនជាងនេះក៏ដោយ លទ្ធផលដែលបានមកនឹងពុំមានភាពខុសគ្នាច្រើនឡើយ។ អ្នកតបសម្ភាសន៍ចំនួន ១០០% នៅក្នុងសហាគមន៍ទាំង៨ ប្រើប្រាស់អនុផលព្រៃឈើផ្សេងទៀតនៅក្នុងជីវភាពប្រចាំថ្ងៃ ដូចជា សម្ភារៈសាងសង់ អាហារ ឱសថ ។ល។ ដោយអ្នកទាំងនោះអាចត្រឹមចិញ្ចឹមជីវិតគ្រប់គ្រាន់ តែប៉ុណ្ណោះ ដោយមិនទាក់ទងនឹងប្រភពចំបងនៃប្រាក់ចំណូលឡើយ។

## ១.៨. ប្រាក់ចំណូលពីអនុផលព្រៃឈើ/ជ័រទឹក

ក្រុមអ្នកស្រាវជ្រាវបានសុំឲ្យអ្នកតបសម្ភាសន៍ធ្វើការប៉ាន់ប្រមាណ អំពីប្រាក់ចំណូលរបស់ពួកគេពីធនធានធម្មជាតិដែលបានពីព្រៃឡង់ក្នុងមួយខែៗ។ នេះជាប្រាក់ចំណូលសុទ្ធ និងមិនរាប់បញ្ចូលផលចំណូលដែលបានពីវត្ថុមានដោយមិនបង់ថ្លៃសម្រាប់សម្ភារៈសាងសង់ ស្បៀងអាហារ ឱសថ។ល។ ប្រាក់ចំណូលមានភាពខុសគ្នាពី ២,០០០រៀល (០.៥០ ដុល្លាអាមេរិក) ទៅ ៦០០,០០០រៀល (១៥០.០០ ដុល្លារអាមេរិក) ក្នុងមួយខែ សម្រាប់បុគ្គលម្នាក់ៗ ដែលមានដើមច្បោះច្រើនជាង ១,០០០ដើម។ ប្រាក់ចំណូលជាមធ្យមសម្រាប់អ្នកតបសម្ភាសន៍ទាំងអស់គឺ ៥០,០០០រៀល (១២.៥០ដុល្លាអាមេរិក) ក្នុងមួយខែ ប៉ុន្តែគច្រើនបំផុតរកបានក្នុងរវាង ១០,០០០រៀល និង ៣០,០០០រៀល (២.៥០ និង ៧.៥០ដុល្លាអាមេរិក) ក្នុងមួយខែ។ ភាពខុសគ្នានេះមួយផ្នែកបណ្តាលមកពីប្រការដែលថា គ្រួសារខ្លះសម្រេចធ្វើការដាំស្រូវ និងដំណាំផ្សេងទៀត ដែលភាគច្រើនលក់នៅក្នុងសហគមន៍ទាំងនេះ។ អ្នកដទៃទៀតលក់ជ័រ ឬអនុផលព្រៃឈើ និងទិញស្រូវពីអ្នកភូមិផ្សេងទៀត ចំណែកអ្នកដទៃទៀតដាំស្រូវផង និងរកជ័រទឹកផង។ ភាពខុសគ្នានៃចំនួនដើមច្បោះដែលបុគ្គលម្នាក់ៗកាន់កាប់ ច្រើនតែដោយសារសិទ្ធិបន្តមរតកនៅក្នុងសហគមន៍ និងការលក់ដូររវាងបុគ្គល និងគ្រួសារនានា។

នៅក្នុងទីតាំងសិក្សាទាំងពីរ អ្នករកជ័រអាចរកប្រាក់ចំណូលបានជាមធ្យមចន្លោះពី ៣,០០០រៀល (០.៧៥ដុល្លារអាមេរិក) ទៅ ៥,០០០រៀល (១.២៥ដុល្លារអាមេរិក) ពីដើមជ័រមួយដើមក្នុងរយៈពេលមួយឆ្នាំ។ ភាពខុសគ្នានៃប្រាក់ចំណូលអាស្រ័យទៅលើទំហំ គុណភាព និងប្រភេទនៃដើមជ័រដែលផ្តល់ផល។ សម្រាប់អ្នកតបសម្ភាសន៍ភាគច្រើន ប្រាក់ចំណូលដែលពួកគេរកបានពីអនុផលព្រៃឈើគ្រប់គ្រាន់សម្រាប់តែបំពេញភាពចាំបាច់សំខាន់ៗក្នុងការរស់នៅតែប៉ុណ្ណោះ ហើយច្រើនតែជាការបំពេញបន្ថែមលើចំណូលពីដំណាំស្រូវ ដែលមានត្រឹមតិចតួច ចំណែកភាគច្រើននៃអាហារ និងតម្រូវការដទៃទៀតប្រចាំថ្ងៃក៏បានមកពីព្រៃឈើផងដែរ។ ក្នុងន័យនេះ វាជាកម្រិតគ្រប់គ្រាន់សម្រាប់តែរស់។ អ្នកភូមិខ្លះអាចមានដើមច្បោះជាច្រើន និងមិនដាំស្រូវឡើយ ប៉ុន្តែពួកគេទិញអង្ករពីអ្នកភូមិដទៃដោយដោះដូរ

ជាមួយប្រាក់ដែលពួកគេរកបានពីការលក់ជ័រទឹក។

ការសិក្សានេះពិតជាមានកម្រិតកំណត់ ក្នុងការទទួលបានគំនិតពិតប្រាកដអំពីថាតើគ្រួសារនីមួយៗដែលរស់នៅពឹងអាស្រ័យក្នុងតំបន់ព្រៃឡង់ អាចរកប្រាក់ចំណូលបានប៉ុន្មានពីព្រៃឈើ។ ដើម្បីឲ្យបានសុក្រឹត្យជាងនេះ អាចទាមទារឲ្យមានការសិក្សាធំជាង និងពិស្តារជាងមុន ដែលជាការប្រសើរគួតែក្នុងរយៈពេលមួយឆ្នាំពេញដើម្បីកំណត់ថ្លៃធនធានទាំងអស់ដែលយកចេញពីព្រៃ និងអ្វីដែលត្រូវទិញ។ អ្នកតំណាងនៃបណ្ដាញព្រៃឡង់ បានផ្ដល់ប៉ាន់ប្រមាណអំពីប្រាក់ចំណូលដែលទទួលបានពីអនុផលព្រៃឈើប្រមាណ ២០,០០០រៀល ទៅ ៣០,០០០រៀល (៥.០០ ទៅ ៧.៥០ដុល្លារអាមេរិក) ក្នុងមួយថ្ងៃ សម្រាប់មួយគ្រួសារ ដោយគិតទាំងអាហារ ឱសថ សម្ភារៈសាងសង់ និងអ្វីផ្សេងក្រៅពីនេះ។ បើពួកគេមិនអាចចូលរកអនុលផលព្រៃឈើបាន ពួកគេត្រូវទិញ ដូចជា អាហារ ឱសថ សម្ភារៈសាងសង់ជាដើម។ ការបាត់បង់ព្រៃឈើ ឬការដែលមិនអាចចូលរកអនុផលព្រៃឈើគឺជាការពាក់ព័ន្ធយ៉ាងធ្ងន់ធ្ងរចំពោះការចិញ្ចឹមជីវិត និងសន្តិសុខស្បៀងរបស់គ្រួសារដែលពឹងអាស្រ័យលើព្រៃឈើ។

ភូមិនានាដូចជា ភូមិស្ពង់ និងភូមិទូល មានការទាក់ទងតិចតួចណាស់ជាមួយពិភពខាងក្រៅ ដោយសារគេត្រូវចំណាយពេលជាច្រើនម៉ោងតាមទោចក្រយានយន្ត ទើបអាចមកកាន់ទីផ្សារដែលនៅជិតបំផុតបាន ដែលធ្វើឲ្យការធ្វើដំណើរនេះត្រូវចំណាយខ្ពស់ជាបង្គួរ។ ជាក់ស្ដែង ភូមិស្ពង់ជាសហគមន៍ដាច់ស្រយាលជាងគេបំផុតដែលមានតែកូនតូបលក់ទំនិញតូចមួយប៉ុណ្ណោះ ដែលមានដាក់លក់ត្រឹមវត្ថុសំខាន់ៗមួយចំនួនតូចមកពីខាងក្រៅភូមិ ដូចជាអំបិល ប៊ីចេង មីកញ្ចប់ និងបារីថោកៗមួយចំនួន។ លើសពីនេះ ជាទូទៅ ជ័រទឹកពីភូមិស្ពង់ត្រូវបានដឹកជញ្ជូនទៅទីផ្សារត្រឹមតែប៉ុន្មានជើងប៉ុណ្ណោះក្នុងមួយឆ្នាំ តាមរថយន្តដឹកទំនិញដែលអាចចូលមកដល់ភូមិតែក្នុងរដូវប្រាំងតែប៉ុណ្ណោះ។ នេះមានន័យថាភាគច្រើនបំផុតនៃពាណិជ្ជកម្ម បានធ្វើឡើងតែនៅក្នុងសហគមន៍ដែលធ្វើឲ្យសាច់ប្រាក់មានតួនាទីតិចតួចនៅក្នុងជីវភាពប្រចាំថ្ងៃ។ ក្នុងន័យនេះអ្នកភូមិពិតជាពឹងផ្អែកលើធនធានព្រៃឈើដែលស្ថិតនៅជុំវិញពួកគេ ជាជាងការប្រើប្រាស់សាច់ប្រាក់ក្នុងចលនាសេដ្ឋកិច្ច។ មូល

ហេតុដែលអ្នកភូមិនៅសណ្ដាន់ បានអះអាងថាមានដើមច្បោះច្រើនខ្លាំងជាងនៅតំបន់នេះគឺដោយសារសហគមន៍នានាអាចប្រើប្រាស់ទីផ្សារងាយស្រួលជាង ហើយមានទំនាក់ទំនង និងពឹងផ្អែកលើសាច់ប្រាក់ក្នុងចលនាសេដ្ឋកិច្ច។ សញ្ញាផ្សេងទៀតអំពីលក្ខខណ្ឌនៃប្រាក់ចំណូលទំនងជាខុសគ្នាគឺថា មានតែប្រជាជនមួយចំនួនតូចនៅភូមិស្ដង់មានទោចក្រយានយន្តតែមួយ ហើយគិតមកទល់ដើមឆ្នាំ២០១១មានទូរស័ព្ទត្រឹមតែមួយគ្រឿងប៉ុណ្ណោះ នៅក្នុងភូមិនេះទាំងមូល ធៀបនឹងភូមិនានានៅស្រុកសណ្ដាន់ ដែលគ្រួសារជាច្រើនមានទោចក្រយានយន្ត ហើយទូរស័ព្ទក៏មានជាទូទៅជាងផងដែរ។ គេប្រហែលជាអាចនិយាយបានថា ប្រជាជននៅភូមិស្ដង់មិនមែនជាអ្នកប្រើប្រាស់សម្ភារៈច្រើនឡើយ ដោយសារតែវិសាលភាពគ្របដណ្ដប់នៃទូរទស្សន៍ទើបតែមាននៅក្នុងឆ្នាំ ២០១១ តែប៉ុណ្ណោះ ដែលមុននេះទូរទស្សន៍មួយចំនួនតូចដែលមាននៅក្នុងសហគមន៍នេះ ច្រើនតែប្រើប្រាស់សម្រាប់ពិធីនានាក្នុងសហគមន៍ ដើម្បីបញ្ចាំងវីស៊ីឌី និងឌីវីឌីតែប៉ុណ្ណោះ។ មួយវិញទៀត ភូមិស្ដង់មានការប្រើប្រាស់សម្ភារៈក្នុងកម្រិតដ៏ទាបដែលមិនមែនជាបញ្ហានៃប្រាក់ចំណូលទាប និងបញ្ហានៃការរកទិញទំនិញទេ ប៉ុន្តែជាបញ្ហាដែលប្រជាជនរស់នៅក្នុងសេដ្ឋកិច្ចដែលមិនសុាំជាមួយនឹងការប្រើប្រាស់របស់ទាំងនោះក្នុងជីវភាពរបស់ពួកគេ។



រូបភាពទី ៥: ការដងជ័រតាមប្រពៃណី

## ១.៥. ចំនួនដើមច្បោះ

ប្រការគួរឲ្យចាប់អារម្មណ៍ គឺចំនួនដើមច្បោះដែលបានអះអាងដោយប្រជាជនថាជារបស់ខ្លួននៅក្នុងតំបន់ដែលអង្កេតទាំងពីរនេះ មានភាពខុសគ្នាជាខ្លាំង។

ចំនួនដើមច្បោះ ដែលប្រជាជនម្នាក់ៗក្នុងសហគមន៍ក្នុងស្រុកថាឡាបរិវ៉ាត់អះអាងថាជារបស់ខ្លួនគឺជាមធ្យមចំនួន៣២០ដើម ចំណែកនៅស្រុកសណ្ដាន់គឺចំនួន៩៤០ដើម។ ហេតុផលនៃភាពខុសគ្នាជាខ្លាំងបែបនេះ នៅពុំបានដឹងច្បាស់នៅឡើយទេ។ អ្នកតបសម្ភាន៍នៅក្នុងភូមិឈូក សុទ្ធតែអះអាងថាខ្លួនមានដើមច្បោះច្រើនជាង ១,៥០០ដើម ហើយប្រសិនបើយើងមិនគិតបញ្ចូលតួលេខទាំងនេះទេ តួលេខមធ្យមនឹងថយចុះមកត្រឹមជិត៦០០ដើម។ យោងតាមអ្នកតំណាងនៃបណ្ដាញព្រៃឡង់ម្នាក់នៅស្រុកសណ្ដាន់ តួលេខជាមធ្យមគឺជិត ៤០០ដើម ក្នុងមួយគ្រួសារ។ វាប្រហែលជាមានអ្វីដែលត្រូវធ្វើជាមួយនឹងសហគមន៍ដ៏ដាច់ស្រយាល នៅស្រុកថាឡាបរិវ៉ាត់នេះផងដែរ។

## ១.៦. ការផ្ដល់សំណងចំពោះអនុផលព្រៃឈើ

រាល់សំណងដែលត្រូវសងទៅឲ្យអ្នកភូមិ ដោយសារតែការបាត់បង់ដើមច្បោះដែលបណ្ដាលមកពីសកម្មភាពរបស់ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច ត្រូវគិតគូរពីអាយុកាលនៃដើមឈើនៅពេលគណនាតម្លៃនៃដើមឈើ ដោយសារដើមច្បោះត្រូវបានបន្តជាមរតកពីជំនាន់មួយទៅជំនាន់មួយផ្សេងទៀត។ ប្រាក់សំណងដែលផ្ដល់ដោយក្រុមហ៊ុន CRCK ដល់អ្នកភូមិមួយចំនួននៅស្រុកសណ្ដាន់មានត្រឹមតែ ១០,០០០រៀល (២.៥០ដុល្លារអាមេរិក) ប៉ុណ្ណោះក្នុងច្បោះមួយដើម ដែលត្រូវនឹងតម្លៃសម្រាប់រយៈពេល ២ ទៅ ៣ឆ្នាំ នៃការប្រមូលជ័រទឹក ដែលដើមច្បោះទាំងនោះអាចផ្ដល់ផលជាច្រើនទសវត្សរ៍។ តួលេខសមហេតុផលជាងនេះ គួរតែច្រើនជាង ១០០,០០០រៀល (២៥.០០ដុល្លារអាមេរិក) ដែលយ៉ាងហោចណាស់អាចផ្ដល់សក្ដានុពលសម្រាប់អ្នកភូមិក្នុងការវិនិយោគលើជំនួញផ្សេង។ ជម្រើសមួយផ្សេងទៀត គួរតែក្រុមហ៊ុនបង់ថ្លៃគិតជាភាគរយនៃតម្លៃដើមឈើនីមួយៗ គិតជាម៉ែត្រគូបនៃឈើមូល។ តាមតម្លៃបច្ចុប្បន្នដែលមានប្រមាណ ៣០០ដុល្លារអាមេរិកក្នុងមួយម៉ែត្រគូបសម្រាប់ដើមច្បោះ[៨១] តួលេខនេះបង្ហាញថា អ្នកភូមិក្នុងករណីនេះគួរតែទទួលបានប្រាក់ច្រើនជាងបច្ចុប្បន្ននេះឆ្ងាយណាស់។

---

[៨១] រូបបានមកពីអង្គការការពារធនធានធម្មជាតិ (NRPG)

ទាក់ទងនឹងភាពជាម្ចាស់លើដើមច្បោះ ប្រការសំខាន់គឺត្រូវកត់សម្គាល់ថា សហគមន៍ជាច្រើននៅក្នុង និងជុំវិញតំបន់ព្រៃឡង់បានសហការគ្នាអះអាង«ភាពជាម្ចាស់» លើដើមច្បោះ ស្ទើរតែទាំងអស់នៅក្នុងព្រៃនេះទាំងមូល ដោយតំបន់នានាត្រូវបានបែងចែករវាងសហគមន៍ និងបន្ទាប់មករវាងអ្នកភូមិម្នាក់ៗដោយត្រូវមានការឯកភាពគ្នាជាសមូហភាពលើព្រំប្រទល់នៅថ្នាក់មូលដ្ឋាន។ អ្នកភូមិម្នាក់អាចមានដើមច្បោះចំនួន ៥០០ដើម ប៉ុន្តែប្រើប្រាស់ជាក់ស្តែងត្រឹមតែ ៤០០ដើមប៉ុណ្ណោះ ចំណែកដើមច្បោះដទៃទៀត ត្រូវបានចាត់ទុកថានៅតូចពេក មិនអាចប្រមូលផលជាជុំកំភួនឡើយ ប៉ុន្តែដើមច្បោះតូចៗទាំងនោះនៅតែត្រូវចាត់ទុកថាជាកម្មសិទ្ធិរបស់ពួកគេរហូតដល់មានទំហំសមល្មម។ គេអាចនិយាយដោយងាយថា ប្រសិនបើអ្នកណាម្នាក់កាប់ដើមច្បោះនៅព្រៃឡង់ ពួកគេនឹងត្រូវជំពាក់ប្រាក់សំណងដល់អ្នកណាម្នាក់។

មានប្រជាជនចំនួនបីនាក់បានអះអាងថា ក្រុមហ៊ុននានាត្រូវតែផ្តល់សំណងជូនប្រជាជនអោយយុត្តិធម៌សម្រាប់ការបាត់បង់ដើមច្បោះ។ ប្រជាជនមិនបានបញ្ជាក់អំពីសំណូមពរអោយជាក់លាក់ ថាតើសំណងគួរតែធ្វើឡើងដោយរបៀបណា ប៉ុន្តែពួកគេបានបញ្ជាក់ថា សំណងបែបណាក៏ដោយអោយតែមានការឯកភាពគ្នារវាងភាគីទាំងពីរ។ ប្រជាជនចង់មានអនុផលព្រៃឈើសម្រាប់ការចិញ្ចឹមជីវិតជាជាងការទទួលយកសំណង ហើយពួកគេមានគំនិតតិចតួច ឬគិតមិនចេញថាតើពួកគេអាចរស់នៅបានដោយគ្មានដើមច្បោះដោយរបៀបណា។ ការផ្តល់សំណងត្រូវបានគេមើលឃើញថា ជាតម្រូវការដើម្បីជំនួសអោយអ្វីដែលប្រជាជនបាត់បង់សម្រាប់ការរស់នៅប្រចាំថ្ងៃ ប៉ុន្តែវាមិនមែនជាវិធីដ៏ចាំបាច់ដើម្បីចាប់ផ្តើមជីវិត ឬជំនួញថ្មីដ៏ពេញលេញឡើយ។

## ១.៧. កម្មសិទ្ធិដី និងឯកសារផ្លូវការសម្រាប់គ្រួសារ

ជាការពិត ការប៉ាន់ប្រមាណឲ្យបានសុក្រឹត្យអំពីស្ថានភាពកម្មសិទ្ធិដីនៅទូទាំងព្រៃឡង់គឺជាការលំបាកមួយ ដោយសារតែមានឯកសារតិចតួចប៉ុណ្ណោះដែលបង្ហាញពីការកាន់កាប់ដី។ សូម្បីតែអ្នកភូមិដែលរស់នៅភូមិរបស់ពួកគេជាច្រើនជំនាន់ក៏មិនមានសៀវភៅគ្រួសារ ឬអត្តសញ្ញាណប័ណ្ណ ដែលចេញដោយភ្នាក់ងាររដ្ឋា

ភិបាលដែរ។ ដោយសារតែភាពដាច់ស្រយាល និងគ្មានទំនាក់ទំនងជាមួយពិភពខាងក្រៅ បានធ្វើអោយសហគមន៍ព្រៃឡង់ ក៏ដូចជាភស្តុតាងនានារបស់អ្នកស្រុកដូចជារូបថត សាលា និងការកត់ត្រានានាអំពីសុខភាពគឺមានការខ្វះខាត។ បន្ថែមពីនេះតាមការបញ្ជាក់ពីអ្នកភូមិស្ពង់ដែលរស់នៅទីនោះតាំងពីយូរ សហគមន៍មួយចំនួនដូចជាភូមិក្របីមួយ នៅស្រុកថាឡាបរិវ៉ាត់ មិនមាននៅមុនឆ្នាំ២០០៥ទេ។ ភូមិនេះបានទាក់ទាញជនចំណាកស្រុកអោយចូលទៅនៅក្នុងតំបន់ព្រៃឈើ ឬសហគមន៍ព្រៃឈើ និងចូលកាន់តែជ្រៅទៅតំបន់ថ្មីៗ។

ទាក់ទងនឹងកម្មសិទ្ធិដី អ្នកភូមិ ៧៩% ពុំមានឯកសារបញ្ជាក់កម្មសិទ្ធិដីឡើយ ហើយបានទាមទារសិទ្ធិលើដីដូនតា នៅលើចំណែកដីព្រៃ និងផ្ទះសំបែងរបស់ពួកគេ។ សហគមន៍ទាំងអស់បានមកតាំងនៅទីនេះជាយូរ តាមដែលអ្នកភូមិទាំងនេះអាចចាំបាន ហើយអ្នកទាំងនេះភាគច្រើនបានពន្យល់ថា ពួកគេមានតែការព្រមព្រៀងផ្ទាល់មាត់នៅក្នុងសហគមន៍ទាក់ទងនឹងដីព្រៃ ឬដើមឈើជាក់លាក់។ អ្នកភូមិមួយចំនួននៅភ្នំឈូកបានពោលថា ពួកគេមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរនៅក្នុងសហគមន៍នេះ ចំណែកអ្នកផ្សេងទៀតនៅភូមិស្រែវាល បានរក្សាទុកប័ណ្ណបញ្ជាក់កម្មសិទ្ធិដីកសិកម្មរបស់ខ្លួនតាំងពីសម័យសម្តេចសីហនុ ដែលនៅក្រោមច្បាប់ភូមិបាលឆ្នាំ២០០១ ត្រូវអស់សុពលភាពរួចទៅហើយ។[៨២] គ្រួសារនានាដែលមានដីស្រែជាអចិន្ត្រៃយ៍គឺជាអ្នកដែលមានឯកសារបញ្ជាក់កម្មសិទ្ធិ តាមទម្រង់ណាមួយបើទោះជាឯកសារទាំងនោះជាច្រើនផុតសុពលភាពទៅហើយក៏ដោយ។ ទោះបីពួកគេមកពីខេត្តដទៃក៏ដោយ អ្នកចំណាកស្រុកចំនួន៧នាក់នៅភូមិទូល បានអះអាងថាដីរបស់ពួកគេក៏ជាដីរបស់ដូនតាផងដែរ និងបានផ្តល់មកឲ្យពួកគេតាមរយៈសាច់ញាតិនៅក្នុងភូមិនេះ។

នៅស្រុកថាឡាបរិវ៉ាត់ អ្នកតបសម្ភាសន៍នៅក្នុងការអង្កេតនេះត្រូវបានសួរអំពីអត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារ ដើម្បីបញ្ជាក់ថាពួកគេបានរស់នៅក្នុងសហគមន៍ទាំងនេះ។ ជាលទ្ធផលប្រជាជន៩០% នៃអ្នកដែលបានចូលរួមក្នុងការអង្កេត មានយ៉ាងហោចណាស់ទម្រង់ណាមួយនៃអត្តសញ្ញាណទាំងពីរនេះ។

---

[៨២] មាត្រាទី ៧ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ ចែងថា រាល់"កម្មសិទ្ធិ" នៅមុនឆ្នាំ ១៩៧៩ លែងមានសុពលភាពហើយ។

ជាការច្បាស់ណាស់ថា ប្រជាពលរដ្ឋភាគច្រើនបំផុតអាចបានត្រឹមតែទាមទារសិទ្ធិលើដីពីដូនតា ហើយសិទ្ធិបែបនេះមានត្រឹមតែជាការព្រមព្រៀងផ្ទាល់មាត់នៅក្នុងសហគមន៍នីមួយៗទាំងនេះប៉ុណ្ណោះ។ ការបាត់បង់ដីនិង/ឬដើមឈើទាំងនេះលំបាកនឹងជំនួសបានណាស់ដោយសារតែគ្រប់ដើមឈើដែលមាន និងព្រៃឈើនៅជិតសហគមន៍ត្រូវបានក្លាយជាកម្មសិទ្ធិរបស់អ្នកដទៃណាម្នាក់រួចទៅហើយ។ ឆ្ងាយពីភូមិបន្តិច ដី និងដើមឈើ គឺជារបស់សហគមន៍ដទៃ។ បើអោយរៀបរាប់ថាដីស្រែដីធ្លី ឬដើមឈើណាជារបស់អ្នកណា គឺវាមិនមានភាពច្បាស់លាស់ឡើយ ដោយសារនេះជារបៀបដែលសហគមន៍នានានៅក្នុងព្រៃឡង់ជាអ្នកចាត់ចែង ដើម្បីចៀសវាងពីជម្លោះវាងគ្នា និងគ្នាចំពោះដីកម្មសិទ្ធិ។ គេពុំឃើញមានភាពខុសគ្នាច្រើនឡើយនៃអត្រាកម្មសិទ្ធិដីរវាងសហគមន៍ខ្មែរ និងកួយដែលអត្រាកម្មសិទ្ធិដីមានប្រហាក់ប្រហែលគ្នានៅក្នុងសហគមន៍នីមួយៗ។



រូបភាពទី ៦: វាស្រែអចិន្ត្រៃយ៍ ដែលកម្រមានជាទូទៅ នៅក្នុងសហគមន៍ខ្លះ

## ១.៨. ការកែប្រែរបបចិញ្ចឹមជីវិត

លើកលែងតែអ្នកតបសម្ភាសន៍នៅភូមិរំដៀង អ្នកតបសម្ភាសន៍ដទៃទៀតទាំងអស់មកពីទីតាំងអង្កេតនានាពោលថា ពួកគេមិនចង់កែប្រែរបបចិញ្ចឹមជីវិតជាប្រពៃណីដែលពឹងផ្អែកលើព្រៃឈើ ទៅជារបៀបរស់នៅបែបទំនើប ឬការរស់នៅខុសពីមុន ដូចជាធ្វើការឲ្យក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចឡើយ។ មានតែអ្នកតបសម្ភាសន៍ចំនួនពីរនាក់ប៉ុណ្ណោះ ដែលបានពោលថា ពួកគេមានចំណាប់អារម្មណ៍ធ្វើការឲ្យក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច ប៉ុន្តែអ្នកទាំងពីរបានគូសបញ្ជាក់ថា ពួកគេចង់

ធ្វើការបណ្តោះអាសន្នតែប៉ុណ្ណោះដើម្បីរកប្រាក់បន្ថែម ឬនៅក្នុងករណីមានការបន្ទាន់ប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ អ្នកទាំងពីរនេះបានពោលថា ពួកគេចង់បន្តរបៀបរស់នៅដូចបច្ចុប្បន្ននេះ និងមិនចង់ឲ្យក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចចូលមកក្នុងតំបន់របស់ពួកគេឡើយ ដោយសារក្រុមហ៊ុនទាំងនោះនឹងបំផ្លាញរបរចិញ្ចឹមជីវិតរបស់ពួកគេ។

រាល់ផលប្រយោជន៍រយៈពេលខ្លី ពីការងារជាមួយក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចនឹងត្រូវទូទាត់ តាមយៈការបាត់បង់ធនធានព្រៃឈើដែលចាំបាច់សម្រាប់ការរស់នៅប្រចាំថ្ងៃរស់ពួកគេ។ នៅស្រុកសណ្តាន់ ប្រជាជនមួយចំនួនបាននិយាយអំពីសមាជិកគ្រួសាររបស់ពួកគេដែលធ្វើការរយៈពេលខ្លីនៅក្នុងចំការកៅស៊ូទំរីង ប៉ុន្តែពួកគេធ្វើតែនៅពេលដែលពួកគេត្រូវការប្រាក់បន្ថែមជាបន្ទាន់ប៉ុណ្ណោះ ដូចជាដើម្បីទិញថ្នាំសម្រាប់ព្យាបាលសមាជិកគ្រួសារ។ ពួកគេមិនចូលចិត្តការងារនេះឡើយ ដោយសារប្រាក់កម្រៃទាប ជាញឹកញាប់ពួកគេមិនបានទទួលប្រាក់កម្រៃទាន់ពេលវេលា ហើយពួកគេមានថ្ងៃឈប់សម្រាកយ៉ាងច្រើនត្រឹម១ទៅ២ថ្ងៃប៉ុណ្ណោះក្នុងមួយខែ។ ផ្ទុយទៅវិញ អ្នកតបសម្ភាសន៍ទាំង១០០% ពេញចិត្តចំពោះរបៀបរស់នៅបច្ចុប្បន្នរបស់ពួកគេ ដោយសារព្រៃឈើផ្តល់អ្វីៗទាំងអស់ដែលគេត្រូវការដូចជាសម្រាប់សាងសង់ផ្ទះ អាហារ ប្រាក់ចំណូល។

លើសអ្វីៗទាំងអស់ អ្នកតបសម្ភាសន៍បាននិយាយអំពីសន្តិសុខដែលព្រៃឈើផ្តល់ឲ្យពួកគេ ដែលជាកង្វល់ចំបងរបស់ពួកគេ។ អ្នកតបសម្ភាសន៍ម្នាក់បង្ហាញពីសញ្ចេតនាដែលបានបន្ទរយ៉ាងច្បាស់ *«មានព្រៃឈើ យើងមានអ្វីៗទាំងអស់ដែលយើងត្រូវការជាចាំបាច់ដើម្បីរស់ ហើយយើងពុំដែលដាច់ពោះឡើយ។ មានព្រៃឈើ យើងមានអារម្មណ៍ថាអនាគតរបស់គ្រួសារយើងនឹងមានសុវត្ថិភាព»*។



រូបភាពទី ៧: ពលរដ្ឋជនជាតិដើមភាគតិចកំពុងរៀបចំអាហារថ្ងៃត្រង់ដោយប្រើប្រាស់ផ្ទាល់នូវធនធានធម្មជាតិដែលមាននៅនឹងកន្លែង

## ២. ផលប្រយោជន៍ពីការអភិវឌ្ឍ

ក្នុងន័យនេះ លទ្ធផលពីតំបន់ទាំងពីរត្រូវតែដាក់ដាច់ដោយឡែកពីគ្នាដោយសារសំណួរដែលលើកឡើងនៅក្នុងតំបន់នីមួយៗមានភាពខុសគ្នាបន្តិច។ លើសពីនេះ បញ្ហានានាដែលសហគមន៍បានប្រឈមនៅស្រុកសណ្ដាន់ មានលក្ខណៈខុសគ្នាយ៉ាងច្រើន ធៀបនឹងបញ្ហានៅស្រុកថាឡាបរិវ៉ាត់។ ទីមួយ ផលប្រយោជន៍ពីការអភិវឌ្ឍ ដែលអ្នកតបសម្ភាសន៍នៅសណ្ដាន់បានអះអាងមានតែការសាងសង់ផ្លូវប៉ុណ្ណោះ ប៉ុន្តែភាគច្រើនបាននិយាយថា ទោះបីជួនកាលផ្លូវថ្មីនេះមានប្រយោជន៍សម្រាប់ប្រជាជនក្នុងការចូលទៅរកអនុផលព្រៃឈើក៏ដោយ ផ្លូវទាំងនេះក៏បានជួយក្នុងការបង្កើនសកម្មភាពកាប់ឈើល្មើសច្បាប់ និងការទន្ទ្រានយកដីធ្លីផងដែរ។

អ្នកដងជ័រ និងអ្នករកអនុផលព្រៃឈើភាគច្រើនបានពោលថា ពួកគេបានប្រឹងប្រែងយ៉ាងខ្លាំងដើម្បីបញ្ចៀសការប្រើប្រាស់ផ្លូវថ្មីនេះ ដោយសារតែប៉ុស្តិ៍ត្រួតពិនិត្យរបស់រដ្ឋបាលព្រៃឈើមួយកន្លែង ដែលមានមន្ត្រីរដ្ឋបាលព្រៃឈើតែងតែបានបញ្ឈប់ដំណើររបស់ប្រជាជនមូលដ្ឋាន។ ពួកគេបានពន្យល់ថាប្រសិនបើពួកគេប្រើប្រាស់ផ្លូវនេះ ពួកគេនឹងត្រូវមន្ត្រីរដ្ឋបាលព្រៃឈើឃាត់ខ្លួនហើយបន្ទាប់មកមន្ត្រីទាំងនោះនឹងទាមទារការបង់ប្រាក់តាមតែទំនើងចិត្ត (ចំពោះសេចក្ដីលំអិត សូមអានផ្នែកស្ដីពី«សកម្មភាពរបស់រដ្ឋបាលព្រៃឈើ»)។ ការត្អូញត្អែរជាទូទៅមួយផ្សេងទៀតគឺថាផ្លូវនេះត្រូវបានបំផ្លាញ ដោយសារតែរថយន្តដឹកឈើធំៗពីក្រុមហ៊ុនសម្បទានចំការកៅស៊ូ និងស្ថិតក្នុងស្ថានភាពអាក្រក់ក្រៃលែង។ ទោះជាការជួសជុលផ្លូវបានធ្វើឡើងបានពាក់កណ្ដាលនៅពាក់កណ្ដាលខែវិច្ឆិកា ឆ្នាំ២០១១ ក៏ដោយ តែផ្លូវនេះត្រូវបានគេរំពឹងថានឹងត្រូវខូចខាយ៉ាងឆាប់រហ័សនៅពេលរដូវភ្លៀងធ្លាក់ បូករួមទាំងចរាចរឡានធនធ្ងន់។

អ្នកតបសម្ភាសន៍ភាគច្រើនមកពីភូមិស្រែវាលនៃស្រុកសណ្ដាន់ ធ្វើដំណើរតាមផ្លូវនេះធៀបនឹងតាមច្រកតូចៗនៅក្នុងព្រៃ ដើម្បីទៅកាន់ទីផ្សារនៅស្រុកសណ្ដាន់ ត្រូវចំណាយពេលជាងពីរដង យូរជាងតាមច្រកក្នុងព្រៃទៅទៀត ដែលនាំឲ្យមានកំណើនថ្លៃចំណាយក្នុងការធ្វើដំណើរ។ ប្រជាជននៅភូមិភ្នំឈូក និងសំបូរ

បានឃើញផលប្រយោជន៍តិចតួចពីផ្លូវថ្នល់នេះ ដោយសារផ្លូវនេះមិនស្ថិតនៅជិតភូមិ របស់ពួកគេឡើយ។

តំណាងមកពីបណ្តាញសហគមន៍ព្រៃឡង់ នៅស្រុកសណ្តាន់បានពោលថា មានទំនាក់ទំនងតិចតួចណាស់ រវាងក្រុមហ៊ុន CRCK និងសហគមន៍មូលដ្ឋានដែលនៅក្បែរនោះ។ គាត់បានលើកឡើងថា មានការបាត់ក្របីចំនួន៨ក្បាល នៅពេលដែលក្របីទាំងនោះវង្វេង នៅក្នុងតំបន់សម្បទាន ប៉ុន្តែមិនមានការផ្តល់សំណងឡើយ។ លើសពីនេះគាត់បានរាយការណ៍ថាសត្វមួយចំនួនបានងាប់ ហើយមនុស្សមួយចំនួនបានធ្លាក់ខ្លួនឈឺក្រោយពីប្រើប្រាស់ទឹកពីស្ទឹងដែលហូរកាត់ក្រុមហ៊ុន CRCK។ គាត់បានកត់សម្គាល់ថា បញ្ហានេះមិនបានកើតឡើងមុនពេលដែលក្រុមហ៊ុន CRCK ចាប់ផ្តើមនៅទីនោះទេ។



រូបភាពទី ៨: ផ្លូវថ្មីៗដែលនាំមកនូវការបំផ្លិចបំផ្លាញតំបន់ព្រៃឡង់

ក្នុងតំបន់សិក្សានៅស្រុកថាឡាបរិវ៉ាត់ ពុំមានសកម្មភាពរបស់ក្រុមហ៊ុនសម្បទានដោយផ្ទាល់ទេនៅក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ ហើយមានការអភិវឌ្ឍតិចតួចនៅក្នុងតំបន់ព្រៃដាច់ស្រយាល គិតមកទល់ចុងឆ្នាំ២០១១។ បើទោះជាបែបនេះក៏ដោយ អ្នកតបសម្ភាសន៍ជាច្រើនពុំមានយោបល់គាំទ្រឡើយ បើផ្អែកតាមបទពិសោធន៍របស់សហគមន៍ផ្សេងៗទៀតអំពីបញ្ហាដែលធ្លាប់ជួបប្រទះកន្លងទៅនៅក្នុងតំបន់របស់ពួកគេ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ និងដើមទសវត្សរ៍ឆ្នាំ ២០០០។

យោងតាមការសម្ភាសន៍សមាជិកក្រុមប្រឹក្សាឃុំ ភូមិរំដៀងវាលពោធិ៍ និង អន្លង់ពែរ នៃស្រុកថាឡាបរិវ៉ាត់ សុទ្ធតែមានប្រវត្តិជួបបញ្ហាជាមួយក្រុមហ៊ុនភាពីម៉ិច រវាងឆ្នាំ ១៩៩៥ និង២០០២ នៅពេលដែលភាគច្រើននៃកន្លែងនានាក្នុងតំបន់ព្រៃឡង់ត្រូវបានបែងចែកជាព្រៃសម្បទាន។[៨៣] នៅក្នុងអំឡុងពេលនេះ អ្នកភូមិជាច្រើនបានបាត់បង់ដើមច្បោះរបស់ខ្លួន ហើយមន្ត្រីនានាបានអធិប្បាយស្រដៀងគ្នាអំពីបញ្ហានានាដូចដែលយើងបានឃើញសព្វថ្ងៃនេះនៅក្នុងស្រុកសណ្តាន់ ទាក់ទងនឹងការរានឆ្ការយកដី និងការកាប់ឈើល្មើសច្បាប់ដែលកើតមានជាទូទៅ នៅខាងក្រៅតំបន់សម្បទាន។ ប្រជាជននៅភូមិទូល ក៏បានរាយការណ៍អំពីការបាត់បង់ដើមច្បោះជាច្រើនរយដើមនៅក្នុងដើមទសវត្សរ៍ឆ្នាំ១៩៩០ផងដែរ។

ប្រធានភូមិម្នាក់ចាប់អារម្មណ៍ថា ដីសម្បទានសេដ្ឋកិច្ចអាចផ្តល់ប្រយោជន៍ដោយនាំមកនូវការងារដែលផ្តល់កម្រៃខ្ពស់ដល់សហគមន៍ ប៉ុន្តែ មន្ត្រីម្នាក់ទៀតក៏បានបន្ទរផងដែរ អំពីអ្វីដែលជាចំណាប់អារម្មណ៍របស់អ្នកតបសម្ភាសន៍ដទៃទៀតដែលថាប្រជាពលរដ្ឋមូលដ្ឋានខ្វះជំនាញចាំបាច់ ក្នុងការទទួលបានការងារដ៏ល្អនៅក្នុងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច។ ប្រធានភូមិខ្លះក៏បានលើកឡើងផងដែរថាក្រុមហ៊ុនបាននាំអ្នកពីក្រៅដើម្បីធ្វើការងារជំនាញ ដែលនាំឲ្យមានកំណើនជនចំណូលស្រុកមកក្នុងតំបន់របស់ពួកគេ។ អ្នកតបសម្ភាសន៍ដទៃទៀត ពោលថាពួកគេពុំឃើញមានផលប្រយោជន៍អ្វី ពីការមកដល់នៃក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចមកក្នុងសហគមន៍របស់ពួកគេឡើយ មានតែចំណុចអវិជ្ជមាន ពោលគឺការបាត់បង់វប្បធម៌ និងសន្តិសុខគ្រួសារ។ សម្រាប់មនុស្សជាច្រើនក្នុងភូមិដាច់ស្រយាលបំផុតដូចជាភូមិស្ពង់ នៅស្រុកថាឡាបរិវ៉ាត់គោលគំនិតអំពីវត្តមានការងារ និងធ្វើការឲ្យក្រុមហ៊ុនគឺជាគំនិតចម្លែកសុទ្ធសាធ។

ចំពោះសំណួរថាតើការអភិវឌ្ឍដូចជាក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច អាចផ្តល់ផលប្រយោជន៍អោយប្រជាជនក្នុងភូមិយ៉ាងដូចម្តេច អ្នកតបសម្ភាសន៍ទាំងអស់បានបដិសេធចំពោះវត្តមានក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច ហើយអ្នកខ្លះបានលើកឡើងថាពួកគេចង់រស់នៅក្នុងសភាពដូចដើម ដោយសារពួកគេសប្បាយចិត្តចំពោះ

[៨៣] សូមអានរបាយការណ៍ Global Witness report "Family Trees" 2007.

ជីវិតបែបប្រពៃណីរបស់ពួកគេ។ អ្នកតបសម្ភាសន៍មួយចំនួនបានស្នើថា ក្រុមហ៊ុនសម្បទាន គួរតែចុះផ្ទាល់ដល់សហគមន៍ និងរៀនសូត្រពីសហគមន៍មូលដ្ឋាន ក៏ដូចជាការចិញ្ចឹមជីវិតរបស់ពួកគេ មុនពេលដែលក្រុមហ៊ុនកាប់ព្រៃឈើ។ អ្នកតបសម្ភាសន៍ដែលជាជនជាតិកួយ បានបង្ហាញពីការព្រួយបារម្ភជាខ្លាំងគួរអោយកត់សម្គាល់ សម្រាប់អនាគត់របស់ពួកគេ ដោយសារតែពួកគេមានការយល់ដឹងតិចតួច ឬគ្មានការយល់ដឹងអំពីរបៀបចិញ្ចឹមជីវិតផ្សេងទៀត ហើយទំនងជាត្រូវប្រឈមការលំបាកជាខ្លាំងដើម្បីសម្របខ្លួនជាងសហគមន៍ខ្មែរទូទៅ។



រូបភាពទី៩: ក្រុមហ៊ុនដីសម្បទាន CRCK នៅស្រុកសណ្ដាន់

នៅទូទាំងកន្លែងអង្កេតទាំងពីរ ចម្លើយភាគច្រើនបំផុតគឺការបដិសេធទាំងស្រុង ចំពោះវត្តមានក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចណាមួយ នៅក្នុងតំបន់ព្រៃឡង់។ ទស្សនៈរបស់មនុស្សភាគច្រើនបំផុត គឺថាក្រុមហ៊ុនទាំងនេះគ្រាន់តែជាក្រុមហ៊ុន កាប់ឈើក្រោមការបិទបាំង ហើយពួកគេធ្វើតែសកម្មភាពល្មើសច្បាប់ដែលជាញឹកញាប់មានការឃុបឃិតជាមួយមន្ត្រី នៅមូលដ្ឋាន និងមន្ត្រីថ្នាក់ខេត្ត។ ការយល់ឃើញជាទូទៅ អំពីហេតុផលរបស់រដ្ឋាភិបាលក្នុងការផ្ដល់ដីសម្បទានសេដ្ឋកិច្ច គឺថាកិច្ចការនេះបានធ្វើឡើង ដើម្បីជាប្រយោជន៍របស់មនុស្សមួយចំនួនតូច និងមិនផ្ដល់ប្រយោជន៍ដល់ប្រទេសដូចដែលមន្ត្រីជាន់ខ្ពស់មួយចំនួនក្នុងរដ្ឋាភិបាល បានអះអាងនោះឡើយ។[៨៤]

នៅពេលសាកសួរនាយកដ្ឋានជនជាតិដើមភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ «តើសហគមន៍ជនជាតិដើមភាគតិចទាំងនេះគួរធ្វើអ្វីខ្លះ ដើម្បីការពារដីប្រពៃណីរបស់ខ្លួនពីក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច?» សំណួរនេះត្រូវបានគេឆ្លើយថា ប្រជាជនគួរតែចងក្រងគ្នាដើម្បីការពារទឹកដីរបស់ពួកគេ។ នេះគ្រាន់តែជាយោបល់

[៨៤] អត្ថបទក្នុងខេមបូឌាដេលី "ការពុះច្រៀកប្រទេសកម្ពុជា" ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១២ ដោយ Paul Vrieze and Kuch Naren

មួយ ហើយគ្មានការផ្តល់សេចក្តីលំអិតអំពីថាតើសហគមន៍គួរធ្វើដូចម្តេចដើម្បីការពារដីប្រពៃណីរបស់ពួកគេឡើយ។

## ៣.ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន/ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

គ្មាននរណាម្នាក់ក្នុងចំណោមសហគមន៍ទាំងប្រាំបីក្នុងការសិក្សា បាននិយាយថាពួកគេបានទទួលការសាកសួរពីមន្ត្រីរដ្ឋាភិបាល ទាក់ទងនឹងក្រុមហ៊ុនសម្បទាដែលនឹងកើតមានទេ។ ទាក់ទងនឹងសកម្មភាពរបស់ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច អ្នកតបសម្ភាសន៍ចំនួន ៤៦% ពោលថា ពួកគេមិនដឹងអ្វីសោះ ចំណែក ១៨% ពោលថាក្រុមហ៊ុននេះកំពុងបង្កើតអាជីវកម្មជីកយករ៉ែ និងចំការកៅស៊ូ ហើយ ៥៥%ទៀត ពោលថាសកម្មភាពចំបងរបស់ក្រុមហ៊ុនគឺសកម្មភាពល្មើសច្បាប់ ដូចជាកាប់ឈើ និងការទន្ទ្រានយកដី ហើយក្រុមហ៊ុនទាំងនេះច្រើនតែមានខ្សែជាមន្ត្រីជាន់ខ្ពស់ ឬបុគ្គលដែលមានខ្នងក្រាស់។

មន្ត្រីចំនួនពីររូបនៅភូមិរំដៀង និងអន្លង់ពែរបានរាយការណ៍ថាពួកគេបានទទួលការណែនាំអំពីសម្បទានរ៉ែ នៅក្នុងតំបន់របស់ពួកគេដូចជា ក្រុមហ៊ុនត្រេនសូល ទីតាន័រ និងក្រុមហ៊ុនទ្រីភាព។ ប៉ុន្តែគ្មានអ្នកណាម្នាក់អាចរម្លឹកឡើងវិញអំពីអ្វីដែលមានចែងនៅក្នុងឯកសារនោះ និងមិនយល់អំពីអ្វីដែលបានប្រាប់មកពួកគេឡើយ ដោយសារតែពួកគេពុំសូវមានចំណេះដឹង។ ដូចគ្នានេះដែរ គ្មានអ្នកណាម្នាក់បានទទួលការណែនាំអំពីការអភិវឌ្ឍទៅអនាគត ពីសំណាក់ក្រុមហ៊ុនណាមួយ ឬមន្ត្រីណាម្នាក់នៅក្នុងការប្រជុំតាមភូមិនោះទេ ប៉ុន្តែពួកគេត្រូវបានគេស្នើសុំឲ្យផ្តិតមេដៃលើឯកសារសម្រាប់ការអភិវឌ្ឍនានាដូចជា សាងសង់ផ្លូវថ្នល់ ស្ពាន សាលារៀន និងសម្បទាសុខភាព ប៉ុន្តែមិនមែនសម្រាប់ដីសម្បទានណាមួយឡើយ។ ទោះជាយ៉ាងនេះក្តី ដោយសារតែប្រជាជនមិនមានចំណេះដឹង ដូច្នេះពួកគេមិនដឹងច្បាស់ថាឯកសារដែលពួកគាត់បានផ្តិតមេដៃនោះនិយាយពីអ្វីឡើយ។

នៅក្នុងពេលសម្ភាសន៍ ប្រជាជនប្រមាណជិតពាក់កណ្តាលបានពោលថា អាជ្ញាធរមូលដ្ឋានម្នាក់ បានមកសុំពួកគេឲ្យផ្តិតមេដៃលើឯកសារដើម្បីការពារព្រៃ

ឈើ និងបញ្ឈប់ការកាប់ឈើល្មើសច្បាប់ និងការទន្ទ្រានយកដីពីសំណាក់ក្រុមហ៊ុន។ នៅក្នុងពេលពិភាក្សាតាមក្រុម អ្នកចូលរួមចំនួន៨០% បានពោលដូចគ្នានេះ ប៉ុន្តែគ្មានអ្នកណាម្នាក់ដែលអាចឆ្លើយបានទៅនឹងសំណួរជាបន្ថែម អំពីថាតើឯកសារនោះចែងអំពីអ្វីឡើយ ដោយសារពួកគេមិនត្រូវបានអនុញ្ញាតឲ្យ ឬមិនអាចអានឯកសារទាំងនោះ។ មានតែមនុស្សម្នាក់ប៉ុណ្ណោះដែលអាចកំណត់អត្តសញ្ញាណថាស្ថាប័នណាមួយនៃរដ្ឋាភិបាលដែលពាក់ព័ន្ធ ពោលគឺរដ្ឋបាលព្រៃឈើ។ ពួកគេទំនងជាយោងទៅលើការប៉ុនប៉ងរបស់រដ្ឋបាលព្រៃឈើ ក្នុងការទទួលបានការឯកភាពលើតំបន់សហគមន៍ព្រៃឈើនានា ដូចជាតំបន់សហគមន៍នៅសណ្ដាន់ ក្នុងឆ្នាំ ២០១១ ប៉ុន្តែគ្មានអ្នកណាម្នាក់យល់ពីរឿងនេះឡើយ ។ គួរកត់សម្គាល់ផងដែរថា នៅពេលផ្ដិតមេដៃដើម្បីទទួលយកសហគមន៍ព្រៃឈើ នៅសហគមន៍ស្រែវាលមានអ្នកតបសម្ភាសន៍មួយចំនួនបានរាយការណ៍ថា ប្រធានភូមិ និងប្រធានឃុំ បានទាមទារអត្តសញ្ញាណប័ណ្ណរបស់ពួកគេ និងនៅពុំទាន់បានប្រគល់មកឲ្យវិញនៅឡើយទេ។

**ប្រអប់ ៩: សម្រង់ចេញពីអត្ថបទសារព័ត៌មានខេមបូឌាដេលី «ពុះច្រៀកប្រទេសកម្ពុជា» ថ្ងៃទី ១០ ខែមីនា ឆ្នាំ ២០១២**

សមាជិកសភាពីគណបក្សប្រជាជនលោក ជាម យៀប បានការពារដាច់ខាតចំពោះគោលនយោបាយរបស់រដ្ឋាភិបាល ក្នុងការអនុម័តឲ្យមានកំណើនយ៉ាងឆាប់រហ័សនៃចំការកសិ-ឧស្សាហកម្ម ដោយអះអាងថា វាជាគំរូសេដ្ឋកិច្ចសមស្របមួយសម្រាប់អភិវឌ្ឍន៍ប្រទេស និងកាត់បន្ថយភាពក្រីក្រ។ លោកបានពោលថា "កំណើនយ៉ាងខ្លាំងនៃដីសម្បទានសេដ្ឋកិច្ច បានធ្វើឡើងស្របជាមួយគោលនយោបាយអភិវឌ្ឍន៍របស់រដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស"។ ការបន្ថែមក្រសួងពាក់ព័ន្ធទាំងឡាយបានចាត់វិធានការចាំបាច់ទាំងអស់ក្នុងការសិក្សា និងបញ្ចៀសរាល់ផលប៉ះពាល់បរិស្ថាន និងសង្គមដែលបណ្ដាលពីសម្បទាននានា។ លោកជាម យៀប បានពោលថា ក្នុងករណីដែលផលប៉ះពាល់អវិជ្ជមានពិតជាកើតឡើង ឥទ្ធិពលសរុបក៏នៅតែវិជ្ជមានដែរ។ លោកបានបន្តថា "ផលប៉ះពាល់/ពីសម្បទាននានា/ មានត្រឹមតិចតួចប៉ុណ្ណោះ បើប្រៀបធៀបនឹងផលប្រយោជន៍សេដ្ឋកិច្ចសម្រាប់ប្រទេស។ «គ្មានអ្វីល្អឥតខ្ចោះឡើយ ការអភិវឌ្ឍតែងតែមានផលប៉ះពាល់។ យើងទទួលស្គាល់ថាសម្បទានដីសេដ្ឋកិច្ចសម្រាប់ដាំកៅស៊ូ និងកសិ-ពាណិជ្ជកម្ម ដទៃទៀតមានឥទ្ធិពលមកលើប្រជាពលរដ្ឋមូលដ្ឋាន និងបរិស្ថាន។ ពលរដ្ឋរងគ្រោះគួរតែយល់ថា ពួកគេគួរតែលះបង់ដើម្បីប្រទេសជាតិ ដើម្បីជួយរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។»

ស្នាមមេដៃត្រូវបានស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលប្រើប្រាស់ជាទូទៅ ដើម្បីសុំការអនុញ្ញាតពីសហគមន៍សម្រាប់ការអភិវឌ្ឍនានា ដូចជាសាលារៀន និងផ្លូវថ្នល់ ឬសម្រាប់ការដាក់ញត្តិ និងសំណើសុំផ្សេងៗទៅមន្ត្រីនានា។ នៅពេលសួរថាតើមានមន្ត្រីណាមកទាក់ទង ដើម្បីសុំឲ្យផ្ដិតមេដៃនៅលើឯកសារណាមួយផ្សេងទៀតដែរឬទេ? មានការបង្ហាញយ៉ាងច្បាស់ថា ជារឿងដែលកើតមានដោយកម្រដែលថា មានអ្នកណាម្នាក់យល់ថាតើពួកគេចុះហត្ថលេខាលើឯកសារអ្វី ហើយពួកគេបានពឹងផ្អែកទាំងស្រុងលើមន្ត្រីនានា ឬបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធដើម្បីធ្វើការពន្យល់។ អ្នកតបសម្ភាសន៍បានរៀបរាប់អំពីការដែលពួកគេផ្ដិតមេដៃដើម្បីសាងសង់សម្បទាសុខភាព សាលារៀន ផ្លូវថ្នល់ និងទទួលមុង។ អ្នកខ្លះបានផ្ដល់យោបល់ថា ប្រការទាំងនេះកម្រកើតមានណាស់ លើកលែងតែការផ្ដិតមេដៃសាងសង់សាលារៀន។

អ្នកតបសម្ភាសន៍មួយចំនួននៅស្រុកសណ្ដាន់ បានឲ្យដឹងថាឯកសារនានាដែលពួកគេបានយល់ គឺការអំពាវនាវដល់រដ្ឋាភិបាលឲ្យបញ្ឈប់ការផ្ដល់សម្បទានដីសេដ្ឋកិច្ច ការកាប់ឈើល្មើសច្បាប់។ល។ តាមពិតទៅគឺជាសំណើសុំការឯកភាពចំពោះសកម្មភាពរបស់ក្រុមហ៊ុនសម្បទានទៅវិញទេ។ ដោយសារមិនអាចទទួលបានឯកសារបែបនេះ អ្នកស្រាវជ្រាវមិនអាចដឹងពីការពិតបានឡើយ។ មន្ត្រីម្នាក់បានពោលថា គាត់យល់ថារដ្ឋាភិបាលគួរតែផ្ដល់ «ព្រៃរេចរឹល» ទៅឲ្យក្រុមហ៊ុនដីសម្បទានដីសេដ្ឋកិច្ច តែមិនមែនជាព្រៃក្រាស់ដែលនៅល្អឡើយ ព្រោះវាហួសពីករណីដែលត្រូវផ្ដល់អោយ។ មនុស្សមួយចំនួននៅស្រុកសណ្ដាន់បានបន្ទរសំដីនេះ ដោយអ្នកខ្លះត្អូញត្អែរថា សហគមន៍ព្រៃឈើដែលពួកគេទទួលបាន គ្រាន់តែជា «ព្រៃរេចរឹល» ចំណែកក្រុមហ៊ុនទទួលបានព្រៃក្រាស់ដែលនៅមានគុណភាពល្អ។

នៅក្នុងកិច្ចប្រឹងប្រែងដើម្បីស្វែងយល់ ថាតើមន្ត្រីមូលដ្ឋានបានស្ថិតក្រោមសម្ពាធដែរ ឬទេ មន្ត្រីនានានៅស្រុកថាឡាបរិវ៉ាត់ត្រូវបានសាកសួរ ថាតើពួកគេធ្លាប់បានទទួលបញ្ជាពីអាជ្ញាធរជាន់ខ្ពស់ឲ្យផ្ដិតមេដៃលើឯកសារនានា ដែលទាក់ទងនឹងការអភិវឌ្ឍនានាដែរឬទេ។ មន្ត្រីបួនរូបបានពោលថា «គ្មានទេ» ប៉ុន្តែ មន្ត្រីម្នាក់បានឆ្លើយថាគាត់បានទទួលបញ្ជាឲ្យស្វែងរកការឯកភាពលើសហគមន៍ព្រៃឈើ តាម

រយៈការទទួលបានស្នាមមេដៃពីសហគមន៍របស់គាត់។ គាត់មិនបានផ្តល់យោបល់ថែមទៀតឡើយ។

នៅក្នុងការសន្និដ្ឋាន យើងអាចនិយាយបានថា គ្មានការពិគ្រោះយោបល់ទាល់តែសោះជាមួយ អ្នកភូមិ ទាក់ទងនឹងគម្រោងដីសម្បទានសេដ្ឋកិច្ចនានា នៅស្រុកសណ្តាន់។ លើសពីនេះ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន ក៏បានទទួលស្គាល់ជាចំហផងដែរថា ខ្លួនមិនបានទទួលឯកសារវាយតម្លៃហេតុប៉ះពាល់បរិស្ថានពីក្រុមហ៊ុនឡើយ (គិតត្រឹមថ្ងៃសម្ភាសន៍)។ មន្ត្រីនៅភូមិស្រែវាលដែលរក្សាទុកអត្តសញ្ញាណប័ណ្ណរបស់អ្នកភូមិ បង្កឲ្យមានការព្រួយបារម្ភជាពិសេស។ គេមិនដឹងពីមូលហេតុដែលគាត់ធ្វើបែបនេះឡើយ ប៉ុន្តែវាបានបង្ហាញអំពីការរំលោភបំពានរបស់ពួកគេមកលើអ្នកភូមិ (សូមអានផ្នែកស្តីពីអាជ្ញាធរមូលដ្ឋាន) ហើយការធ្វើបែបនេះមិនទំនងជាដើម្បីផលប្រយោជន៍របស់សហគមន៍ឡើយ។ ជួនកាលមេដឹកនាំសហគមន៍ត្រូវស្ថិតនៅក្រោមសម្ពាធពីអាជ្ញាធរជាន់ខ្ពស់ ដើម្បីរកការចុះហត្ថលេខាលើឯកសារពីសហគមន៍របស់ពួកគេ។

## ៤. ការបណ្តុះបណ្តាលអំពីច្បាប់នៅកម្ពុជា និងសិទ្ធិមនុស្ស

### ៤.១. ការបណ្តុះបណ្តាលទៅកាន់សហគមន៍

គ្មានហេតុផលក្នុងការមិនរាប់បញ្ចូលសហគមន៍ណាមួយ ទៅក្នុងការគណនានេះឡើយ ដោយសារអ្នកតបសម្ភាសន៍នៅក្នុងសហគមន៍ទាំង៨ នៅទូទាំងទីតាំងដែលបានសិក្សាទាំងពីរ បានពោលថា ពួកគេបានទទួលការបណ្តុះបណ្តាលខ្លះៗស្តីពីច្បាប់របស់កម្ពុជា និងអំពីសិទ្ធិមនុស្ស។ ក្នុងពេលដែលអ្នកតបសម្ភាសន៍ចំនួន ៥៦% បានចូលរួមនៅក្នុងការបណ្តុះបណ្តាលខ្លះៗដែលរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាល ស្តីពីសិទ្ធិមនុស្ស ច្បាប់ស្តីពីព្រៃឈើ និងសិទ្ធិចំពោះកម្មសិទ្ធិដីធ្លី មានតែអ្នកតបសម្ភាសន៍ចំនួន៨នាក់ប៉ុណ្ណោះ (៦,៣%) ដែលអាចនិយាយប្រកបដោយទំនុកចិត្តអំពីអ្វីដែលពួកគេបានរៀនសូត្រ និងមានតែ៣នាក់ (២,៣៦%) បានអះអាងថា មានការយល់ដឹងបានល្អ។ ការពិភាក្សាក្នុងក្រុមបានឲ្យដឹងថា ៦០% បានទទួលការបណ្តុះបណ្តាលខ្លះៗ ប៉ុន្តែដោយមានភាគច្រើននិយាយថា ពួកគេមិន

បានយល់ពេញលេញ ឬ ឥឡូវនេះពួកគេបានភ្លេចទៅហើយនូវអ្វីដែលបាននិយាយនៅពេលនោះ។ ដូចជាករណីភាគច្រើននៅទូទាំងការអង្កេតនេះផងដែរ កង្វះការអប់រំត្រូវបានលើកឡើងថា ជាមូលហេតុនៃការមិនយល់ពីវគ្គបណ្តុះបណ្តាលនានា។ អ្នកតបសម្ភាសន៍ជាច្រើនប្រាថ្នាចង់រៀនសូត្របន្ថែមទៀតអំពីច្បាប់ និងបានស្នើសុំឲ្យអង្គការមិនមែនរដ្ឋាភិបាលផ្តល់វគ្គបណ្តុះបណ្តាលបន្ថែមទៀតអំពីសិទ្ធិរបស់ពួកគេ ក្នុងនាមជាពលរដ្ឋកម្ពុជា។

ទោះបីកិច្ចប្រឹងប្រែងដើម្បីអប់រំប្រជាជនទំនងជាមានជាទូទៅក៏ដោយ កិច្ចការនេះទំនងជាផ្តល់ជោគជ័យក្នុងកម្រិតកំណត់តែប៉ុណ្ណោះ។ ប្រការសំខាន់ជាងនេះ គឺប្រជាពលរដ្ឋភាគច្រើនបំផុតឥឡូវនេះបានដឹងថាពួកគេពិតជាមានសិទ្ធិ បើយោងតាមរដ្ឋធម្មនុញ្ញកម្ពុជា ដែលនេះជាជំហានសំខាន់មួយ។ ប៉ុន្តែក្នុងពេលដែលប្រជាជនប្រមាណ ៦០% បានទទួលការបណ្តុះបណ្តាលតាមទម្រង់ខុសៗគ្នា មានតែប្រជាជនចំនួន៨នាក់ប៉ុណ្ណោះ ក្នុងចំណោមជាង៧០នាក់ នៅចងចាំអំពីចំណេះដឹងជាច្រើនដែលពាក់ព័ន្ធ។

## ៤.២. ការបណ្តុះបណ្តាលទៅកាន់មន្ត្រីមូលដ្ឋាន

ទាក់ទងនឹងការបណ្តុះបណ្តាល ដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋានចំនួនបួននាក់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ដែលពីរនាក់មានការយល់ដឹងតិចតួច ម្នាក់និយាយថាគាត់បានយល់គោលៗ ប៉ុន្តែតិចតួចប៉ុណ្ណោះ ហើយម្នាក់ទៀតមកពីភូមិវាលពោធិ៍បានយល់ដឹងយ៉ាងល្អអំពីវគ្គបណ្តុះបណ្តាល។ នៅពេលសួរថាពួកគេបានដឹងអ្វីខ្លះអំពីសិទ្ធិរបស់អ្នកភូមិ/សហគមន៍របស់ពួកគេ ពួកគេទាំងអស់បានដឹងថា ប្រជាជនមានសិទ្ធិការពារដីធ្លី និងព្រៃឈើរបស់ពួកគេ ពីការទន្ទ្រានល្មើសច្បាប់ពីក្រុមហ៊ុនសម្បទាន ប៉ុន្តែមានតែម្នាក់ប៉ុណ្ណោះ ដែលបានយល់អំពីដំណើរការដែលពាក់ព័ន្ធ។

ក្រុមអ្នកប្រមូលព័ត៌មានបានសួរអាជ្ញាធរមូលដ្ឋានថា តើពួកគេយល់អំពីនិយមន័យអំពីការតវ៉ាដោយស្របច្បាប់ និងការតវ៉ាល្មើសច្បាប់ដែរឬទេ។ ម្នាក់ៗបានកំណត់ថា ការតវ៉ាល្មើសច្បាប់ មានរូបភាពជាអំពើហឹង្សា ឬ មានប្រើប្រាស់អាវុធ ដូច

ជា ដំបង ឬ កាំបិត។ ទាក់ទងនឹងនិយមន័យអំពីការតវ៉ាស្របច្បាប់ ពីរនាក់មិនអាចឆ្លើយបានឡើយ ហើយម្នាក់ឆ្លើយថាការដើរជាក្បួន ការស្រែក និងគ្រវីទង់ ឬបដា។ ចំណែកមន្ត្រីក្រៅពីនោះដែលមកពីភូមិរំដៀង និងវាលពោធិ៍ពោលថាជាការតវ៉ាតាមរយៈការតស៊ូមតិដោយប្រើប្រាស់ឯកសារស្របច្បាប់ ប្រព័ន្ធព័ត៌មាន និងតាមរយៈការដាក់ពាក្យបណ្ដឹង ទៅតាមបែបបទផ្លូវការ។ អ្នកប្រមូលព័ត៌មានក៏បានសាកសួរអាជ្ញាធរមូលដ្ឋាន ថាតើពួកគេបានដឹងអ្វីខ្លះអំពីច្បាប់ស្ដីពីដីសម្បទានសេដ្ឋកិច្ច/ការអភិវឌ្ឍអាជីវកម្មរ៉ែ។ បួននាក់បានពោលថា ពួកគេគ្មានយោបល់ទេ ចំណែកម្នាក់មកពីវាលពោធិ៍ ពោលថាគាត់យល់ច្បាស់ ដោយពន្យល់បានល្អអំពីថារដ្ឋាភិបាលគួរផ្ដល់តែដីព្រៃរេចរឹលទៅក្រុមហ៊ុនសម្បទាន ហើយពួកគេត្រូវសុំការឯកភាពពីប្រជាជននៅក្នុងមូលដ្ឋាន។ មន្ត្រីនានាមកពីភូមិរំដៀង វាលពោធិ៍ និងទួល បានទទួលការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ ពីរដ្ឋាភិបាលទាក់ទងនឹងច្បាប់ស្ដីពីព្រៃឈើ ប៉ុន្តែអ្នកទាំងបីនាក់បានពោលថា ពួកគេមានការយល់ដឹងក្នុងកម្រិតកំណត់អំពីអ្វីដែលពួកគេបានរៀន។

កម្រិតទាបនៃការអប់រំជាមូលដ្ឋានគឺជាឧបសគ្គចំបង ពីព្រោះមន្ត្រីភាគច្រើនមានកម្រិតនៃការអប់រំទាប ប្រហាក់ប្រហែលគ្នានឹងប្រជាជនក្នុងភូមិដែរ។ មន្ត្រីទាំងអស់ស្វាគមន៍វគ្គបណ្ដុះបណ្ដាលសម្រាប់សហគមន៍របស់ពួកគេ មិនថាពីសំណាក់រដ្ឋាភិបាល ឬមួយពីអង្គការមិនមែនរដ្ឋាភិបាល ហើយទាំងអស់គ្នាពោលថាប្រការសំខាន់ប្រជាពលរដ្ឋត្រូវតែយល់អំពីសិទ្ធិរបស់ពួកគេ ដើម្បីពួកគេអាចតវ៉ាជំទាស់នឹងសកម្មភាពល្មើសច្បាប់ និងការពារព្រៃឈើ។

ប្រការសំខាន់គឺនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិដើមភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ ពិតជាបានឆ្លើយតបថា រដ្ឋាភិបាលសូមស្វាគមន៍ការបណ្ដុះបណ្ដាលដែលផ្ដល់ដោយអង្គការមិនមែនរដ្ឋាភិបាល «ដោយសារការអប់រំមានសារៈសំខាន់សម្រាប់អ្នកភូមិ ដើម្បីពួកគេយល់ដឹងអំពីសិទ្ធិរបស់ខ្លួន»។

### ៤.៣. ការគំរាមកំហែងចំពោះវគ្គបណ្ដុះបណ្ដាល

អ្នកភូមិនៅស្រុកថាឡាបរិវ៉ាត់ ត្រូវបានសាកសួរបន្ថែមថាតើពួកគេបានទទួលការគំរាមកំហែងដែលទាក់ទងនឹងការចូលរួមនៅក្នុងវគ្គបណ្ដុះបណ្ដាលនានាដែរ ឬទេ។ នៅក្នុងអំឡុងពេលសម្ភាសន៍ គ្មានអ្នកណាម្នាក់អះអាងថាបានរងការគំរាមកំហែងឡើយ ប៉ុន្តែនៅក្នុងការពិភាក្សាជាក្រុម អ្នកភូមិមួយចំនួននៅក្នុងសហគមន៍មួយបានពោលថា ពួកគេបានទទួលការព្រមានពីប្រធានភូមិរបស់ពួកគេ មិនឲ្យចូលរួមនៅក្នុងវគ្គបណ្ដុះបណ្ដាលអង្គការសង្គមស៊ីវិលឡើយ។

ការប៉ុនប៉ងនានាពីសំណាក់អាជ្ញាធរមូលដ្ឋាន ក្នុងការបំភិតបំភ័យដើម្បីបញ្ឈប់ប្រជាពលរដ្ឋពីការទទួលបាននូវការបណ្ដុះបណ្ដាល ពុំទំនងជាមានប្រសិទ្ធភាពឡើយ ដោយសារប្រជាពលរដ្ឋហាក់ដូចជាមានការប្ដេជ្ញាកាន់តែមោះមុតក្នុងការរៀនសូត្រអំពីសិទ្ធិរបស់ពួកគេ។ ទោះយ៉ាងណា មានការប៉ុនប៉ងជាច្រើនដង និងជួនកាលប្រកបដោយជោគជ័យពីសំណាក់មន្ត្រីនៅមូលដ្ឋាន ក្នុងការបញ្ឈប់វគ្គបណ្ដុះបណ្ដាល ដោយប្រើប្រាស់ការគំរាមកំហែងចាប់ខ្លួន និងទម្រង់ខុសៗគ្នានៃការបំភិតបំភ័យ។

## ៥. ផលប៉ះពាល់លើបរិស្ថាន

អ្នកភូមិ និងអាជ្ញាធរមូលដ្ឋាននៅស្រុកថាឡាបរិវ៉ាត់ ត្រូវបានសួរថាតើពួកគេយល់ថា ព្រៃឈើមានសារៈសំខាន់បែបណាចំពោះកម្ពុជា និងតើមានឥទ្ធិពលអ្វីខ្លះដែលកើតឡើង ប្រសិនបើព្រៃឈើត្រូវគេរានឆ្ការអស់? ចម្លើយមានភាពខុសគ្នាជាខ្លាំង ក្នុងនោះ អ្នកតបសម្ភាសន៍ចំនួន ៥៧% ពោលថាផលប្រយោជន៍សំខាន់នៃព្រៃឈើគឺ ការកាត់បន្ថយនូវការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ ចំណែកអ្នកដទៃទៀត បានកត់សម្គាល់ខុសៗគ្នាអំពីផលប្រយោជន៍នៃព្រៃឈើដូចជា សេដ្ឋកិច្ច ការនាំចេញ ការងារ ការសាងសង់ និងសន្តិសុខគ្រួសារ។ មានតែប្រជាជនចំនួន៤នាក់ប៉ុណ្ណោះ ពុំមានចម្លើយ។ ទាក់ទងនឹងឥទ្ធិពលនៃការបាត់បង់ព្រៃឈើ ចម្លើយស្ទើរតែដូចគ្នា ដោយ ៥៧% បានពោលថា វានឹងបង្កឲ្យមានការប្រែប្រួលអាកាសធាតុ និងនាំមកនូវគ្រោះមហន្តរាយធម្មជាតិកាន់តែច្រើនឡើង។ ឥទ្ធិពល

ដទៃទៀតដែលបានលើកឡើងគឺ ការខូចខាតចំពោះសេដ្ឋកិច្ច គ្មានការងារធ្វើ គ្មានអ្វីសម្រាប់សាងសងសង់ផ្ទះ គ្មានសត្វ និងគ្មានសន្តិសុខគ្រួសារ។ មានការកត់សម្គាល់ថា ក្នុងចំណោមមន្ត្រីមូលដ្ឋានដែលបានសម្ភាសន៍ បានឆ្លើយថា «ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ» តបនឹងសំណួរទាំងពីរ និងពិតជាមានការយល់ដឹងបានល្អអំពីបញ្ហានេះ។

## ៦. ចំណាត់ការដោយផ្ទាល់

ទិន្នន័យនឹងត្រូវវិភាគដាច់ដោយឡែក ដោយសារសំណួរមានភាពខុសគ្នាបន្តិចបន្តួច ដែលធ្វើឲ្យមានការលំបាកក្នុងការរួមបញ្ចូលទៅក្នុងលទ្ធផល។ ដោយសារ ពុំសូវមានអវត្តមានដីសម្បទានសេដ្ឋកិច្ចនៅក្នុងតំបន់អង្កេតទីពីរ លទ្ធផលនានាត្រូវបានរំពឹងថាមានភាពខុសគ្នាជាច្រើន។ សំណួរខ្លះដែលទាក់ទងនឹងការពាក់ព័ន្ធរបស់អាជ្ញាធរមូលដ្ឋាននៅក្នុងការតវ៉ា ត្រូវបានឆ្លើយតបនៅក្នុងផ្នែកស្តីពី អាជ្ញាធរមូលដ្ឋាន។

### *ស្រុកសណ្តាន់*

អ្នកប្រមូលព័ត៌មាន បានសួរប្រជាជនថាតើពួកគេបានចាត់វិធានការនានាដោយផ្ទាល់ដែរឬទេ ដើម្បីការពារព្រៃប្រពៃណីរបស់ពួកគេ ដូចជា ការតវ៉ា ការល្បាតព្រៃអារក្សរបស់ពួកគេ ឬពិនិត្យតាមដានដើមច្បោះរបស់ពួកគេ។ ជាការឆ្លើយតបអ្នកតបសម្ភាសន៍ចំនួន ៦៦% បានចាត់វិធានការក្នុងទម្រង់ខ្លះៗ ចំណែក ៥៥% បានចូលរួមនៅក្នុងការតវ៉ា។ អ្នកតបសម្ភាសន៍ចំនួន ៣៣% មិនបានចាត់វិធានការណាមួយឡើយ ប៉ុន្តែ មួយភាគបីនៃអ្នកទាំងនោះបានពោលថាពួកគេនឹងចូលរួមនៅក្នុងការតវ៉ាណាមួយទៅអនាគត ដោយសារអ្នកដទៃទៀតនៅក្នុងភូមិបានត្រឡប់មកពីចូលរួមនៅក្នុងការតវ៉ាមួយក្នុងពេលថ្មីៗនេះ កាន់តែមានការប្តេជ្ញាចិត្តមោះមុតជាងមុន ដោយឥឡូវពួកគេជឿថាការតវ៉ាអាចមានប្រសិទ្ធភាព។ ទិន្នន័យនេះសន្និដ្ឋានថាអ្នកតបសម្ភាសន៍ចំនួន ៨៥% បច្ចុប្បន្ននេះបានពិនិត្យតាមដានដើមច្បោះរបស់ពួកគេ និង/ឬ ធ្វើការល្បាតដើម្បីការពារដើមច្បោះទាំងនោះ។ ការពិនិត្យតាមដានបាន

ធ្វើឡើងជាផ្នែកមួយនៃកិច្ចប្រឹងប្រែងរបស់បណ្តាញសហគមន៍ព្រៃឡង់ ក្នុងការប្រមូលទិន្នន័យ អំពីកំណើនយ៉ាងខ្លាំងនៃការបាត់បង់ដើមច្បោះនៅទូទាំងព្រៃនេះ។ សហគមន៍ទាំងបី ក៏បានចាប់ផ្តើមចាត់ចែងការល្បាតដោយខ្លួនគេផ្ទាល់ផងដែរ ចំពោះអ្នកកាប់ឈើល្មើសច្បាប់ ដោយទទួលជោគជ័យគួរឲ្យកត់សម្គាល់ ប៉ុន្តែដូចមានកត់សម្គាល់នៅក្នុងផ្នែកស្តីពី «សកម្មភាពរបស់រដ្ឋបាលព្រៃឈើ» កិច្ចប្រឹងប្រែងនានារបស់សហគមន៍ ដើម្បីធ្វើការជាមួយរដ្ឋបាលព្រៃឈើមិនមានប្រសិទ្ធភាពឡើយ។ នៅពេលសួរថាតើពួកគេបានតវ៉ាទៅអាជ្ញាធរនានាឬទេ អ្នកតបសម្ភាសន៍ចំនួន៦០% ពោលថា «គ្មានទេ»។ ប្រជាជនជាច្រើនមានអារម្មណ៍ថា ជាការចំណាយពេលឥតប្រយោជន៍ ដោយសារតែអំពើពុករលួយរបស់អាជ្ញាធរមូលដ្ឋាន។

### *ស្រុកថាឡាបរិវ៉ាត់*

ក្រុមអ្នកស្រាវជ្រាវមិនបានសួរសំណួរដូចគ្នា ដល់ជនចំណាកស្រុកឡើយ។ នៅពេលសួរថាតើពួកគេចង់ចូលរួមនៅក្នុងការតវ៉ាតាមកន្លែងដទៃ ក្នុងតំបន់ព្រៃឈើនេះដែរឬទេ ៨៣% នៃអ្នកដែលតបសម្ភាសន៍បានពោលថា «ចង់» ដែលរួមទាំងមន្ត្រី២នាក់ ក្នុងចំណោម៥នាក់ផងដែរ។ នៅក្នុងការពិភាក្សាតាមក្រុម មានការគាំទ្រ១០០% ឲ្យមានការតវ៉ា ក្នុងនោះមនុស្សជាច្រើនបានពោលថាហេតុផលតែមួយដែលពួកគេមិនទៅចូលរួមគឺការខ្វះប្រាក់ដោយសារពួកគេត្រូវទ្រទ្រង់គ្រួសាររបស់ពួកគេ។

សមាជិកសហគមន៍នៅក្នុងភូមិស្តង់ និងភូមិទូល បានចាប់ផ្តើមការពិនិត្យតាមដានដើមច្បោះរបស់ពួកគេ ហើយបច្ចុប្បន្ននេះបានធ្វើការល្បាតជាទៀងទាត់ ប៉ុន្តែពុំមានទិន្នន័យគ្រប់គ្រាន់ សម្រាប់ប៉ាន់ស្មានអំពីភាគរយនៃសហគមន៍ទាំងនេះដែលពាក់ព័ន្ធនៅឡើយ។ ប្រជាជននៅក្នុងភូមិទាំងពីរនេះ បានរាយការណ៍ថា បានបញ្ឈប់អ្នកកាប់ឈើល្មើសច្បាប់ជាច្រើន និងបានរឹបអូសឈើ និងរណាយន្តជាច្រើនគ្រឿង ដែលបន្ទាប់មកបានប្រគល់ទៅឲ្យមន្ត្រីរដ្ឋបាលព្រៃឈើនៅក្នុងមូលដ្ឋាន។

មានតែមនុស្សម្នាក់ប៉ុណ្ណោះដែលបានរិះគន់ចំពោះអាជ្ញាធរមូលដ្ឋាននេះ គឺសមាជិកបណ្តាញសហគមន៍ព្រៃឡង់ ដែលបានដាក់ពាក្យបណ្តឹងជាញឹកញាប់ទៅអាជ្ញាធរមូលដ្ឋាន និងទៅថ្នាក់ខេត្ត ព្រមទាំងទៅថ្នាក់រដ្ឋាភិបាល ដែលជាផ្នែកមួយនៃការតវ៉ារបស់បណ្តាញសហគមន៍ព្រៃឡង់។ ម្នាក់ផ្សេងទៀត បានត្អូញត្អែរទៅអង្គការ

មិនមែនរដ្ឋាភិបាលមួយ ប៉ុន្តែប្រជាជនជាច្រើនបានត្អូញត្អែរតែទៅសមាជិកគ្រួសារ ឬទៅអ្នកភូមិដទៃទៀតប៉ុណ្ណោះ។ ប្រជាជនភាគច្រើនមិនបានត្អូញត្អែរ ឬដាក់ពាក្យបន្ដឹងទៅអ្នកណាម្នាក់ឡើយ ហើយភាគច្រើនបានអះអាងប្រការនេះថាជាការឥតប្រយោជន៍ ដោយសារអាជ្ញាធរមូលដ្ឋានឬរដ្ឋាភិបាលប្រព្រឹត្តអំពើពុករលួយ ឬពួកគេបាត់បង់ជំនឿលើរដ្ឋាភិបាល ក្នុងការអនុវត្តច្បាប់របស់ប្រទេស។

ជាក់ស្ដែង អ្នកទាំងនេះជាច្រើនបានឃើញបញ្ហានេះទាំងអស់នៅមុនព្រឹត្តិការណ៍នៅទម្រីង និងនៅក្នុងអំឡុងពេលនៃសម្បទានព្រៃឈើ មានន័យថាសហគមន៍នានាមានឆន្ទៈមោះមុតក្នុងការគាំទ្រគ្នាទៅវិញទៅមក។ ការបន្ដអភិវឌ្ឍន៍របស់បណ្ដាញសហគមន៍ព្រៃឡង់ គឺពិតជាកម្លាំងជម្រុញ ដែលធ្វើឲ្យអ្នកភូមិចេញល្បាត ពិនិត្យតាមដានដើមឈ្មោះ និងធ្វើការតវ៉ា។ ពួកគេក៏យល់ផងដែរថា កិច្ចប្រឹងប្រែងរួមគ្នារបស់សហគមន៍នៅទូទាំងព្រៃនេះ មិនទំនងជានឹងអាចបញ្ចុះបញ្ចូលរាជរដ្ឋាភិបាលកម្ពុជាឲ្យចាត់វិធានការឡើយ។ កិច្ចប្រឹងប្រែងរបស់អង្គការមិនមែនរដ្ឋាភិបាល ពិតជាបានជួយពួកគេ ក្នុងការចាត់ចែងបានប្រសើរជាងមុន និងបង្កើនការយល់ដឹងអំពីសិទ្ធិរបស់ពួកគេនៅក្រោមរដ្ឋធម្មនុញ្ញ ប៉ុន្តែអ្នកតបសម្ភាសន៍ភាគច្រើនបានស្នើសុំឲ្យមានការបន្តគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល ជាពិសេស លើការអបរំ និងពង្រឹងការអនុវត្តច្បាប់។

ជាការច្បាស់ណាស់ថា មានអ្នកភូមិកាន់តែច្រើនឡើងដែលអស់សង្ឃឹមនៅក្នុងសហគមន៍ទាំងអស់នេះ ដែលចង់ចូលរួមនៅក្នុងការតវ៉ា។ ក្នុងពេលដែលអ្នកភូមិមកពីខេត្តទាំងបួនបានចូលរួមនៅក្នុងកិច្ចប្រឹងប្រែងយ៉ាងច្រើនបែបនេះ ដើម្បីចូលរួមនៅក្នុងការតវ៉ានៅសណ្ដាន់ វាមានហេតុផលច្បាស់លាស់ក្នុងការជឿជាក់ថា ស្មារតីរបស់ពួកគេមានកម្រិតខ្ពស់ប្រហាក់ប្រហែលគ្នា នៅក្នុងសហគមន៍ជុំវិញតំបន់ព្រៃឡង់។ សូម្បីតែអ្នកដែលពុំមានការពាក់ព័ន្ធជាមួយអនុផលព្រៃឈើក៏ដោយ ក៏បានគាំទ្រពេញទំហឹងដល់ការតវ៉ា និងចង់ឲ្យចូលរួមផងដែរប្រសិនបើអាចធ្វើបាន ដើម្បីគាំទ្រដល់អ្នកភូមិជាមួយគ្នា។

ក្នុងគ្រានេះ អ្នកស្រាវជ្រាវមិនបានទទួលគំនិតណាមួយពីរដ្ឋាភិបាលឡើយ ដែលទាក់ទងនឹង «តើអង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋាភិបាលគួរសហការជាមួយ

គ្នាលើសកម្មភាពអ្វីខ្លះ ដើម្បីបញ្ឈប់ការកាប់ឈើល្មើសច្បាប់ និងសម្បទានដែលអនុវត្តមិនត្រឹមត្រូវ?» នាយកដ្ឋានជនជាតិដើមភាគតិចនៃក្រសួងអភិវឌ្ឍន៍ជនបទ និងនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន បានផ្តល់ចម្លើយដែលមិនសូវមានការប្តេជ្ញាថា «រាល់សកម្មភាពនៅក្រោមច្បាប់នានាដែលនៅជាធរមាន»។

## ៧. ការជឿជាក់លើរដ្ឋាភិបាល

អ្នកប្រមូលទិន្នន័យ បានសួរអ្នកតបសម្ភាសន៍ថាតើពួកគេមានការជឿជាក់លើរដ្ឋាភិបាលជាតិក្នុងការដោះស្រាយបញ្ហានានានៃការកាប់ឈើល្មើសច្បាប់ និងការទន្ទ្រានយកដីធ្លីដែរឬទេ។ គ្មានអ្នកណាម្នាក់ក្នុងចំណោមពួកគេនៅក្នុងទីតាំងអង្កេតណាមួយជឿថា មន្ត្រីរដ្ឋាភិបាលនឹងចាត់វិធានការណាមួយក្នុងនាមពួកគេឡើយ។ នេះជាទស្សនៈជារួមដោយសារ «គ្មានអ្នកណាម្នាក់ស្តាប់ការតវ៉ារបស់ប្រជាជនមូលដ្ឋានឡើយ» ហើយ «រដ្ឋាភិបាលមានចំណាប់អារម្មណ៍តែលើការគាំទ្រដល់ជំនួញធំៗតែប៉ុណ្ណោះ»។

ផ្ទុយទៅវិញ អាជ្ញាធរបួនរូបក្នុងចំណោមអាជ្ញាធរចំនួនប្រាំរូបនៅមូលដ្ឋានក្នុងស្រុកថាឡាបរិវ៉ាត់បានពោលថា ពួកគេមានទំនុកចិត្តទាំងស្រុងលើរដ្ឋាភិបាលក្នុងការដោះស្រាយរាល់បញ្ហានានា។ មន្ត្រីក្រៅពីនេះ ពោលថារដ្ឋាភិបាលមិនដែលស្តាប់ប្រជាពលរដ្ឋក្រីក្រទេ ដូច្នេះ គាត់មិនរំពឹងថាមានចំណាត់ការណាមួយនឹងត្រូវអនុវត្តដើម្បីគាំទ្រដល់អ្នកភូមិឡើយ។ អ្នកតបសម្ភាសន៍មួយចំនួនបានពោលថា ពួកគេខ្វះទំនុកចិត្តលើរដ្ឋាភិបាល ដោយសារមានច្បាប់ជាច្រើនរួចមកហើយសម្រាប់ការពារព្រៃឈើ និងសិទ្ធិរបស់ប្រជាពលរដ្ឋ ប៉ុន្តែរដ្ឋាភិបាលទំនងជាគ្មានប្រសិទ្ធភាព និងគ្មានធ្វើអ្វីសោះក្នុងការពង្រឹងច្បាប់ទាំងនោះ។ អារម្មណ៍ជារួមគឺរដ្ឋាភិបាលមានចំណាប់អារម្មណ៍គាំទ្រតែអ្នកជំនួញធំៗ និងបុគ្គលដែលជាប់ខ្សែស្រឡាយតែប៉ុណ្ណោះ។ សេចក្តីសន្និដ្ឋានតែមួយគត់គឺកង្វះទាំងស្រុងនូវទំនុកចិត្តលើរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហានានាដែលសហគមន៍ព្រៃឡង់កំពុងប្រឈម។

## ៨. អាជ្ញាធរមូលដ្ឋាន

មានការកត់សម្គាល់នៅក្នុងការអង្កេតថា ជាញឹកញាប់អាជ្ញាធរមូលដ្ឋានបានចេញសេចក្តីព្រមានដល់ប្រជាជនរដ្ឋមូលដ្ឋាន ជាពិសេស ទាក់ទងនឹងការតវ៉ា។ ក្នុងពេលដែលការគំរាមកំហែងទាំងនេះភាគច្រើនបានធ្វើឡើងដោយប្រយោល ការព្រមាននៅស្រុកសណ្តាន់មិនឲ្យចូលរួមនៅក្នុងការតវ៉ាប្រឆាំងនឹងក្រុមហ៊ុនសម្បទានកៅស៊ូ CRCK បាននាំឲ្យគ្រួសារអ្នកជំទាស់នៅភូមិស្រែវាល បានទទួលការបដិសេធពីរដ្ឋាភិបាលក្នុងការផ្តល់ជំនួយសង្គ្រោះបន្ទាន់ក្នុងករណីទឹកជំនន់ ដែលបានចេញនៅក្រោយមានទឹកជំនន់យ៉ាងមហន្តរាយនៅក្នុងខែកញ្ញា និងតុលា ឆ្នាំ ២០១១។[៨៥] ប្រហែលជាពិត ដែលសកម្មភាពមិនល្អភាគច្រើនកើតឡើង ដូចជាកូនរបស់អ្នកភូមិត្រូវគេបដិសេធមិនអោយចូលរៀននៅសាលារៀនក្នុងមូលដ្ឋាន ដោយសារសមាជិកម្នាក់នៃគ្រួសារនោះបានចូលរួមក្នុងការតវ៉ាប្រឆាំង។

ក្រុមអ្នកតបសម្ភាសន៍ត្រូវបានសួរថា តើប្រធានភូមិបានគាំទ្រការតវ៉ារបស់ពួកគេដែរឬទេ។ ក្នុងចំណោមប្រធានភូមិទាំង៨នាក់ មានបួននាក់បានអធិប្បាយថា អព្យាក្រឹត្យដោយបដិសេធមិនរាំងអ្នកភូមិពីរតវ៉ា និងជួនកាលព្យាយាមក្នុងការផ្តល់គំនិតថែមទៀងផង។ ទន្ទឹមនឹងនេះពួកគេមិនគាំទ្រអ្នកភូមិយ៉ាងសកម្មទេ ដោយសារតែមានសម្ពាធមកពីមន្ត្រីជាន់ខ្ពស់។ នៅក្នុងពេលពិភាក្សាតាមក្រុម អ្នកចូលរួមមកពីសហគមន៍មួយបានចោទប្រកាន់ប្រធានភូមិម្នាក់ក្នុងចំណោមប្រធានភូមិ «អព្យាក្រឹត្យ» ទាំងបួនថាបានឃុបឃិតជាមួយអ្នកកាប់ឈើល្មើសច្បាប់ ប៉ុន្តែអ្នកភូមិមិនអាច ឬគ្មានបំណងធ្វើការពន្យល់លំអិតឡើយ។ មានតែមេភូមិចំនួនបីនាក់ប៉ុណ្ណោះដែលត្រូវគេមើលឃើញថាគាំទ្រអ្នកភូមិយ៉ាងសកម្ម ប៉ុន្តែម្នាក់នៅស្រុកសណ្តាន់បានទទួលការចោទប្រកាន់ថាឃុបឃិតជាមួយមន្ត្រីឃុំ និងស្រុកនៅក្នុងសកម្មភាពល្មើសច្បាប់ជាច្រើន។

ការតវ៉ាធ្ងន់ធ្ងរបំផុតបានផ្តោតទៅអាជ្ញាធរឃុំ និងស្រុកនៅសណ្តាន់ ដែលត្រូវបានចោទប្រកាន់ ពីការពាក់ព័ន្ធដោយផ្ទាល់ក្នុងការកាប់ឈើល្មើច្បាប់ ការទន្ទ្រាន

---

[៨៥] គួរកត់សម្គាល់ថា បញ្ជីសំណួរសម្រាប់ជនចំណាកស្រុកមិនមានអំពីប្រធានបទនេះទេ ដូច្នេះមិនបានបញ្ចូលនៅក្នុងលទ្ធផលនេះឡើយ។

យកដី និងការឃុបឃិតជាមួយក្រុមហ៊ុន CRCK នៅក្នុងសកម្មភាពល្មើសច្បាប់។ ប៉ូលីសមូលដ្ឋានក៏រងការចោទប្រកាន់អំពីការពាក់ព័ន្ធយ៉ាងធ្ងន់ធ្ងរនៅក្នុងការកាប់ឈើល្មើសច្បាប់ផងដែរ ដោយអ្នកតបសម្ភាសន៍ម្នាក់បានអះអាងថា មន្ត្រីប៉ូលីសមូលដ្ឋានត្រូវបានមន្ត្រីថ្នាក់ស្រុកជួលឲ្យកាប់ដើមច្បោះប្រមាណ ៥,០០០ដើម នៅឃុំដងកាំបិត ក្នុងអំឡុងឆ្នាំ ២០១១។ អ្នកតបសម្ភាសន៍ជាច្រើននៅស្រុកសណ្តាន់បានបង្ហាញឈ្មោះមន្ត្រីជាន់ខ្ពស់ជាច្រើនថានៅពីក្រោយខ្នងសកម្មភាពទន្ទ្រានយកដី និងការកាប់ឈើល្មើសច្បាប់នៅក្នុងស្រុកនេះ។

នៅក្នុងពេលសម្ភាសនៅស្រុកថាឡាបរិវ៉ាត់ មានតែមន្ត្រីមូលដ្ឋានម្នាក់ប៉ុណ្ណោះដែលបានទទួលរងការគំរាមកំហែង ឬស្ថិតក្រោមសម្ពាធពីអាជ្ញាធរជាន់ខ្ពស់ក្រោយពីគាត់ និងអ្នកភូមិបានចាប់អ្នកធ្វើសកម្មភាពកាប់ឈើល្មើសច្បាប់។

នៅពេលសាកសួរថាតើរដ្ឋាភិបាលគួរធ្វើអ្វីខ្លះ ដើម្បីបញ្ឈប់ការកាប់ឈើល្មើសច្បាប់ និងការខូចខាតដែលបណ្តាលមកពីការអភិវឌ្ឍ ដូចជាក្រុមហ៊ុនដីសម្បទាន និងអាជីវកម្មរ៉ែ មន្ត្រីនានាឆ្លើយខុសៗគ្នាដូចជា៖ រដ្ឋាភិបាលគួរចុះមកផ្ទាល់ និងមើលពីស្ថានភាពជាក់ស្តែងដោយខ្លួនឯង បង្កើតច្បាប់ថ្មីៗដើម្បីបញ្ឈប់ការទន្ទ្រានមកលើដីសហគមន៍ បញ្ឈប់សកម្មភាពក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច និងធ្វើការជាមួយសហគមន៍ដើម្បីការពារព្រៃឈើ។

នៅពេលសាកសួរតើអង្គការមិនមែនរដ្ឋាភិបាលគួរធ្វើបែបណា ដើម្បីសហការជាមួយរដ្ឋាភិបាល ក្នុងការបញ្ឈប់ការកាប់ឈើល្មើសច្បាប់ និងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច/អាជីវកម្មរ៉ែ មន្ត្រីចំនួនបួនរូបគ្រាន់តែឆ្លើយថា ពួកគេត្រូវសហការ និងធ្វើការជាមួយគ្នា។ អ្នកដទៃទៀតនិយាយថា វាគ្មានអ្វីខុសគ្នាទេ ដោយសារអំពើពុករលួយនៅតែបន្ត សូម្បីតែរដ្ឋាភិបាលបានអនុម័តច្បាប់ព្រៃឈើហើយក៏ដោយ។

## ៩. សកម្មភាពរបស់រដ្ឋបាលព្រៃឈើ

នៅស្រុកសណ្តាន់ អ្នកតបសម្ភាសន៍ភាគច្រើនជឿថា មន្ត្រីរដ្ឋបាលព្រៃឈើបានផ្តល់កិច្ចការពារដល់អ្នកកាប់ឈើល្មើសច្បាប់ និងជួយក្រុមហ៊ុន CRCK ក្នុងការពង្រីកប្រតិបត្តិការរបស់ពួកគេ។ អ្នកតបសម្ភាសន៍ទាំងអស់ និងអាជ្ញាធរមូលដ្ឋាននៃ

កន្លែងអង្កេតទាំងពីរបានអះអាងថា មន្ត្រីរដ្ឋបាលព្រៃឈើ បានប្រើប្រាស់តំណែងរបស់ខ្លួនក្នុងការជម្រិតទារយកប្រាក់ ជាងការពារព្រៃឈើ។ អ្នកតបសម្ភាសន៍មួយចំនួនជឿថា នេះក៏ដោយសារតែមន្ត្រីរដ្ឋបាលព្រៃឈើនៅក្នុងមូលដ្ឋានត្រូវផ្តល់ «ការគាំទ្រ» ដល់មន្ត្រីជាន់ខ្ពស់នៅថ្នាក់ខេត្តនិង/ឬនីថ្នាក់ជាតិ ហើយគ្មានជម្រើសឡើយនៅក្នុងបញ្ហានេះ។ ឧទាហរណ៍មួយ អ្នកតបសម្ភាសន៍មួយចំនួនអះអាងថា មន្ត្រីរដ្ឋបាលព្រៃឈើបានតាមដានពួកគាត់ចូលទៅក្នុងព្រៃ ដោយព្យាយាមជម្រិតទារ «ប្រាក់» ក្នុងពេលដែលពួកគាត់ទៅដងជ័រ និងរកអនុផលព្រៃឈើ។

អ្នកតបសម្ភាសន៍ភាគច្រើនបំផុត ចង់ឲ្យមានការបញ្ឈប់នូវការទារយក «ប្រាក់» មិនផ្លូវការទាំងនេះ ប៉ុន្តែ ប្រជាជនពីររូបនៅស្រុកសណ្តាន់បានពោលថា ប្រសិនបើមានការកំណត់កម្រៃនេះជាលក្ខណៈស្តង់ដារ និងមានកម្រិតសមហេតុផល ពួកគេនឹងមិនបដិសេធក្នុងការបង់ប្រាក់ ដើម្បីអាចចូលទៅប្រមូលអនុផលព្រៃឈើឡើយ។ ការចោទប្រកាន់ច្រើនជាងគេគឺ «ប្រាក់» ដែលទារយកនេះ ប្រែប្រួលជារៀងរាល់ថ្ងៃ និងជូនកាលវាខ្ពស់ជាងតម្លៃអនុផលព្រៃឈើដែលពួកគេអាចរកបានទៅទៀត។ «ប្រាក់» ដែលពួកគេទារយកសម្រាប់ជ័រទឹកមួយកានគឺ ១,០០០រៀល (០.២៥ដុល្លារអាមេរិក) ប៉ុន្តែ យោងតាមអ្នកតបសម្ភាសន៍ជាច្រើន ការយកកម្រៃកម្រិតនេះអាចប្រែប្រួលខុសគ្នាជាខ្លាំង រហូតដល់១០,០០០រៀល (២.៥០ដុល្លារអាមេរិក) ដែលមានតម្លៃស្ទើរតែស្មើនឹងថ្លៃជ័រទឹកមួយកាននៅក្នុងទីផ្សារក្នុងមូលដ្ឋាន។ ប្រសិនបើអ្នកភូមិមិនមានប្រាក់គ្រប់គ្រាន់ដើម្បីបង់ទេ មន្ត្រីរដ្ឋបាលព្រៃឈើ តាមធម្មតានឹងតាមពួកគេទៅដល់ផ្សារ ដើម្បីប្រមូលយក «ប្រាក់» របស់ពួកគេនៅពេលអ្នកភូមិលក់ផលិតផលនោះ។

## ១០. ជនចំណាកស្រុក

យើងបានព្យាយាមបំភ្លឺថាតើជនចំណាកស្រុកទាំងនេះពិតជាបានទិញដី ឬមានដីដែលបានការរានឆ្ការព្រៃយក (បើទោះជាល្មើសច្បាប់) ឬក៏ឆ្ការព្រៃយកដីឲ្យអ្នកដទៃ។ ជាអកុសល្យ ក្រុមអ្នកប្រមូលទិន្នន័យមិនអាចចូលជួបជនចំណាកស្រុកដែលអ្នកស្រាវជ្រាវបានជួបកាលពីខែមេសា ឆ្នាំ ២០១១ឡើយ ហើយនៅទីបំផុតមាន

តែប្រជាជនចំនួនប្រាំពីរនាក់ប៉ុណ្ណោះដែលបានទទួលការសម្ភាសន៍ នៅក្នុងភូមិទូល។



រូបភាពទី ១០: ព្រៃឈើដែលជនចំណាកស្រុកបានរានឆ្ការនៅស្រុកថាឡាបរីវ៉ាត់ ខែមេសា ឆ្នាំ ២០១១

ជនចំណាកស្រុកចំនួនប្រាំមួយនាក់ ក្នុងចំណោមប្រាំពីរនាក់ នៅភូមិទូល គឺជាអ្នកមកពីខេត្តកំពត និងម្នាក់ទៀតមកពីខេត្តតាកែវ។ គ្រួសារចំណាកស្រុកចំនួនពីរគ្រួសារ បានចូលមកក្នុងតំបន់នេះ តាំងពី ៦ ឬ៧ ឆ្នាំមុនម្លេះ ចំណែកឯ៥គ្រួសារផ្សេងទៀតទើបតែមកដល់ក្នុងអំឡុងឆ្នាំ ២០១១ ប៉ុណ្ណោះ។ គ្រួសារទាំងអស់នេះអះអាងថាមានដីរវាង ១ ទៅ ៣ ហិកតា ហើយបានដាំស្រូវ ដំឡូងមី និង/ឬស្វាយចន្ទី។ គ្មានអ្នកណាម្នាក់ក្នុងចំណោមអ្នកតបសម្ភាសន៍នៅក្នុងការអង្កេតនេះមានឯកសារចុះបញ្ជីដីធ្លីឡើយ ហើយទាំងអស់គ្នាសុទ្ធតែបានអះអាងថា ជាដីដូនតាដែលបានចែកតាមរយៈសាច់ញាតិនៅភូមិទូល។

ក្នុងចំណោមអ្នកដែលបានសម្ភាស មានតែម្នាក់ប៉ុណ្ណោះដែលបានអះអាងថាបានបង់ «កម្រៃ» ទៅឲ្យប្រធានភូមិ ជាស្រាអង្ករចំនួន២លីត្រ ដើម្បីទទួលការអនុញ្ញាតអោយចូលមកតាំងទីលំនៅនៅតំបន់នេះ។ តបនឹងសំណួរដែលសួរថា ហេតុអ្វីគាត់មកនៅក្នុងតំបន់ព្រៃឡង់? ជនចំណាកស្រុកចំនួនប្រាំមួយនាក់ បានពោលថាពួកគេមកទីនេះដោយសារពួកគេពុំមានដីដាំដំណាំ។ ម្នាក់បានពោលថា ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចនៅខេត្តកំពតបានរំលោភយកដីឪពុកម្ដាយរបស់ពួកគេ ដែលធ្វើឲ្យពួកគេគ្មានដីធ្លី។ ទាក់ទងនឹងការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ព្រៃ

ឡង់ បួនក្នុងចំណោមគ្រួសារទាំងប្រាំ រកបានប្រាក់ពីការដងជ័រទឹក និង/ប្រមូលអនុផលព្រៃឈើឲ្យអ្នកដទៃទៀតនៅក្នុងភូមិ។

មានសម្ភារៈសម្រាប់សាងសង់ផ្ទះដោយមិនចាំបាច់បង់ថ្លៃ ត្រូវប្រជាជនមើលឃើញថាជាផលប្រយោជន៍ចំបងមួយ ហើយនៅក្នុងករណីចំនួនបីដែលពួកគេបាននិយាយ គឺការដែលអាចបរបាញ់សត្វព្រៃបាន អាចជួយគ្រួសាររបស់ពួកគេ។ ជាការពិត អាចមានជនចំណាកស្រុកក្នុងចំនួនច្រើនជាងនេះដែលធ្វើការបរបាញ់ដោយសារប្រជាជនជាច្រើន មិនប្រាប់ឲ្យដឹងជាចំហអំពីការបរបាញ់សត្វព្រៃរបស់ពួកគេ។ គេអាចនិយាយបានថា កំណើនចំនួនប្រជាជននៅក្នុងមូលដ្ឋាន ពិតជាធ្វើឲ្យមានផលប៉ះពាល់មកលើសត្វព្រៃដែលកំពុងរងការគំរាមកំហែងរួចមកហើយ នៅក្នុងតំបន់ព្រៃឡង់នេះ។

នៅក្នុងសំណួរមួយទៅកាន់អ្នកភូមិនៅស្រុកថាឡាបរិវ៉ាត់ដែលថា តើពួកគេរងគ្រោះពីការទន្ទ្រានយកដីធ្លីដែរឬទេ។ មានតែអ្នកតបសម្ភាសន៍ចំនួន៣នាក់ នៅភូមិរំដៀង និងម្នាក់នៅវាលពោធិ៍ បានពោលថា ពួកគេមានបញ្ហានេះ។ បីគ្រួសារបានបាត់បង់ដីដោយសារតែជនចំណាកស្រុក ចំណែកមួយគ្រួសារទៀតមានជម្លោះដីធ្លីជាមួយអ្នកជិតខាង។ គ្មានអ្នកណាម្នាក់ក្នុងចំណោមសហគមន៍ចំនួន៣ផ្សេងទៀតបាត់បង់ដីធ្លីឡើយនៅក្នុងពេលថ្មីៗនេះ ប៉ុន្តែ មនុស្សមួយចំនួននៅភូមិស្ពង់បាននិយាយអំពីការបាត់បង់ដីធ្លីដោយសារក្រុមហ៊ុនកាលពីប៉ុន្មានឆ្នាំមុន ពោលគឺនៅមុនពេលមានការបង្ខំឲ្យក្រុមហ៊ុនចេញ។

តាមរយៈការអង្កេតនេះ វាមិនអាចយល់បានច្បាស់លាស់អំពីអ្វីដែលកើតឡើងទាក់ទងនឹងជនចំណាកស្រុកនៅថាឡាបរិវ៉ាត់ទេ ដោយសារជនចំណាកស្រុកដែលបានចូលរួមក្នុងការសិក្សានេះ គឺសុទ្ធតែនៅក្នុងសហគមន៍តែមួយ។ ការសន្និដ្ឋានតែមួយដែលអាចផ្តល់ទំនុកចិត្តគឺថាប្រជាពលរដ្ឋជាច្រើន បច្ចុប្បន្ននេះកំពុងមកតាំងទីលំនៅក្នុងតំបន់ព្រៃឡង់ ជាពិសេសមកពីខេត្តកំពត។ ការរានឆ្ការយកដីក្នុងទ្រង់ទ្រាយធំ មិនអាចកើតឡើងដោយគ្មានការកត់សម្គាល់ពីសំណាក់អាជ្ញាធរមូលដ្ឋាននោះឡើយ។

## ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

មានចំនួនក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទូទាំងប្រទេស បានកើនឡើងយ៉ាងច្រើន នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះដែលបង្កឲ្យមានការរងគ្រោះជាច្រើន ជាពិសេសដល់សហគមន៍ដែលរស់នៅតាមដងព្រៃ ដូចជាសហគមន៍នៅព្រៃឡង់។ រូបភាពពីផ្កាយរណបខាងក្រោមនេះបង្ហាញពីកំណើនយ៉ាងច្រើននៃការបាត់បង់ព្រៃឈើ ដោយសារតែដីសម្បទានសេដ្ឋកិច្ចនៅក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះនៅភូមិភាគកណ្តាលនៃប្រទេសកម្ពុជា។ ដីសម្បទានសេដ្ឋកិច្ចដែលគួរឲ្យកត់សម្គាល់ជាងគេដែលមានទំហំ១៥គីឡូម៉ែត្រ x គីឡូម៉ែត្រ ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃបឹងពែរ ប៉ុន្តែក៏មានតំបន់ដែលមានវិសាលភាពធំៗនៅភាគខាងត្បូង និងខាងលិចព្រៃឡង់ ព្រមទាំងភាគខាងកើតនៅត្រើយម្ខាងនៃទន្លេមេគង្គផងដែរ។ ការវិវត្តនៃទីតាំងក្រុមហ៊ុន CRCK អាចមើលឃើញ ហើយគិតមកទល់ខែមីនា ឆ្នាំ ២០១២ ផ្ទៃដីដែលបានរានឆ្ការហើយមានទំហំ ២គីឡូម៉ែត្រ x ៥គីឡូម៉ែត្រ។




ផែនទី៧: រូបភាពពីផ្កាយរណបអំពីភូមិភាគកណ្តាលនៃប្រទេសកម្ពុជាដែលបង្ហាញពីកន្លែងទើបរានឆ្ការថ្មីៗ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មិនបានធ្វើឡើងអោយសព្វជ្រុងជ្រោយ ហើយគ្មានយុទ្ធសាស្ត្រក្នុងការគាំទ្រអោយមាននិរន្តរភាព នៃការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី និងការអភិវឌ្ឍប្រកបដោយសមធម៌គឺជាស្នូលនៃបញ្ហា។ ឧទាហរណ៍ បើទោះជាក្របខណ្ឌច្បាប់តម្រូវអោយមានការពិនិត្យឡើងវិញនូវសម្បទាន មុនពេល

ផ្តល់ដីសម្បទានក៏ដោយ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន មិនបានទទួលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់ក្រុមហ៊ុន CRCK នៅមុនការផ្តល់សម្បទាននេះឡើយ។ ជាក់ស្តែង យ៉ាងហោចណាស់៦ខែ បន្ទាប់ពីដីសម្បទានត្រូវបានអនុម័តដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានបានទទួលស្គាល់ដោយចំហថា ពួកគេនៅតែមិនទាន់បានទទួលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬពីក្រុមហ៊ុនឡើយ[៨៦]។ ប៉ុន្តែពួកគេនៅតែបន្តធ្វើការអះអាងដោយច្របូកច្របល់ថា ពួកគេអនុវត្តតាមគោលការណ៍ណែនាំស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

១. រាជរដ្ឋាភិបាល គួរតែកំណត់អោយគោរពតាមការតម្រូវរបស់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
២. រាជរដ្ឋាភិបាល គួរតែដាក់ឲ្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្លាយជាដំណើរការដែលមានតម្លាភាព និងអនុញ្ញាតឲ្យសាធារណជនអាចទទួលបានឯកសារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក៏ដូចជាផ្តល់យោបល់បន្ថែម។
៣. ត្រូវដាក់អោយមានការផ្តល់យោបល់ ដើម្បីបំពេញភាពខ្វះចន្លោះជាក់ស្តែងនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន[៨៧] និងបញ្ជាក់អោយច្បាស់អំពីដំណើរការទាំងមូល ដើម្បីធានាឲ្យមានការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មុននឹងមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀង។
៤. នៅក្នុងករណីនៃទីតាំងក្រុមហ៊ុន CRCK ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវតែពន្យល់អំពីមូលហេតុដែលខ្លួនមិនបានបញ្ជូនរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មកនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន មុនពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងដែលជាលក្ខខណ្ឌត្រូវអនុវត្តនៅក្រោមប្រកាសនេះ។ ម្យ៉ាងទៀត នាយកដ្ឋាន

[៨៦] សំគាល់: រហូតតមកទល់ពេលសម្ភាស នាយកដ្ឋាន EIA មិនទាន់បានទទួលរបាយការណ៍ EIA/IEIA ពីក្រុមហ៊ុន CRCK ឡើយ។
[៨៧] ចំពោះព័ត៌មានបន្ថែម សូមអាន ‘ដំណើរការ EIA/ESIA’ ដែលជាផ្នែកមួយនៅក្នុងជំពូកស្តីពីលទ្ធផល។

វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវពន្យល់ឲ្យបានពេញលេញអំពីប្រការដែលក្រុមហ៊ុនមិនអនុវត្តតាមគោលការណ៍ណែនាំ នៅក្នុងករណីដែលមិនបានដាក់ជូនរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

៥. នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គួរធ្វើអធិការកិច្ចទីតាំងក្រុមហ៊ុន CRCK ឡើងវិញ ដោយមិនបាច់ជូនដំណឹងជាមុនដើម្បីស្រាវជ្រាវថាតើក្រុមហ៊ុនបានគោរពតាមលក្ខខណ្ឌ ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងឬទេ។ ប្រសិនបើ ក្រុមហ៊ុនមិនបានគោរពតាមកិច្ចព្រមព្រៀង គួរតែលុបចោលសម្បទាននេះ។

៦. ក្រុមហ៊ុនCRCK ត្រូវចាត់ចែងឲ្យមានការពិភាក្សាជាចំហជាមួយសហគមន៍មូលដ្ឋាន និងផ្តល់សំណងត្រឹមត្រូវដល់អ្នកភូមិដែលបានបាត់បង់ដីធ្លី និងធនធានផ្សេងៗ ដូចជា ដើមច្បោះជាដើម។

៧. អង្គការមិនមែនរដ្ឋាភិបាល គួរព្យាយាមលើកទឹកចិត្តឲ្យមានការពិភាក្សាអំពីសំណងដូចក្នុងករណីសម្បទាន CRCK ដោយសារព្រៃឈើនៅទីនេះត្រូវការពេលច្រើនជំនាន់ដើម្បីវិលទៅរកស្ថានភាពដើមវិញ។ ដូច្នេះ សហគមន៍ទាំងនេះត្រូវបានទទួលសំណងត្រឹមត្រូវ។

៨. អង្គការមិនមែនរដ្ឋាភិបាល គួរតែបង្កើតអោយមានកិច្ចប្រជុំជាមួយសហគមន៍ដែលរងផលប៉ះពាល់ រួមបញ្ចូលទាំងជនជាតិគួយដើម្បីស្វែងរកដំណោះស្រាយជួយពួកគេអោយបន្សាំជាមួយនឹងជីវិតថ្មី តាមរយៈការអប់រំ និងការគាំទ្រផ្នែកហិរញ្ញវត្ថុដូចជាកម្ចីខ្នាតតូច។

## ពង្រឹងការអនុវត្តច្បាប់

តាមរយៈការកាប់ឈើល្មើសច្បាប់ ដែលកើតឡើងជាទូទៅក្នុងកម្រិតធ្ងន់ធ្ងរនៅទូទាំងតំបន់ព្រៃឡង់ គេត្រូវការជាបន្ទាន់នូវការបង្រ្កាបសកម្មភាពល្មើសច្បាប់ទាំងនេះ។ ជាសំណាងអាក្រក់ រដ្ឋបាលព្រៃឈើ និងមន្ត្រីមូលដ្ឋាន ទំនងជាបានពាក់ព័ន្ធនៅក្នុងសកម្មភាពល្មើសច្បាប់ជាច្រើនដែលបានកើតឡើង ដូច្នេះមិនអាចពឹងផ្អែកលើស្ថានប័ននេះសម្រាប់ពង្រឹងការអនុវត្តច្បាប់ឡើយ។

ភាគច្រើនបំផុតនៃសកម្មភាពល្មើសច្បាប់ ដែលកំពុងកើតឡើងអាចបញ្ឈប់បានជាបន្ទាន់ប្រសិនបើស្ថាប័ននានានៃរដ្ឋាភិបាលអនុវត្តតាមមុខនាទីរបស់ខ្លួន ដូចមានចែងនៅក្នុងច្បាប់កម្ពុជា។

**រាជរដ្ឋាភិបាលគួរតែ ៖**

១. បង្កើតគណកម្មការឯករាជ និងពេញសមត្ថភាពមួយដើម្បីស៊ើបអង្កេតលើការចោទប្រកាន់ចំពោះមន្ត្រីមូលដ្ឋាន ហើយចាត់វិធានការផ្លូវច្បាប់ចំពោះដីកាដែលបានស៊ើបអង្កេតឃើញ។

២. ធ្វើការជាដៃគូរជាមួយបណ្តាញព្រៃឡង់ ដើម្បីបង្កើតយុទ្ធសាស្ត្ររួមសម្រាប់គ្រប់គ្រងនិងការពារព្រៃឡង់។ កិច្ចការនេះ គួរតែបញ្ចូលការគ្រប់គ្រងនៃប៉ុស្តិ៍ត្រួតពិនិត្យរបស់រដ្ឋបាលព្រៃឈើនៅទូទាំងព្រៃឈើក្នុងតំបន់នេះ ជាពិសេសជាមួយនឹងមន្ត្រីដែលទើបនឹងចាត់តាំងថ្មីពីខាងក្រៅតំបន់ព្រៃឡង់។ ការធ្វើបែបនេះ នឹងបញ្ឈប់បានស្ទើរតែជាបន្ទាន់នូវការកាប់ឈើល្មើសច្បាប់ធំៗដែលកើតមាននៅជុំវិញព្រៃឡង់។ ការធ្វើបែបនេះក៏អាចមានប្រសិទ្ធភាពនៅផ្នែកដទៃទៀតនៃផ្ទៃប្រទេសផងដែរ។

## ការអប់រំ និងសិទ្ធិនៅក្រោមច្បាប់កម្ពុជា

ជាការច្បាស់ណាស់ថា ប្រជាពលរដ្ឋភាគច្រើនដែលរស់នៅក្នុងព្រៃឡង់មានការយល់ដឹងតិចតួចអំពីសិទ្ធិរបស់ពួកគេនៅក្រោមច្បាប់កម្ពុជា។ ប៉ុន្តែការប៉ុនប៉ងដោយអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងបណ្តាខែកន្លងទៅថ្មីៗនេះ បានបង្កើនយ៉ាងច្រើននូវចំណេះដឹងក្នុងចំណោមសហគមន៍នៅមូលដ្ឋាន អំពីប្រការដែលថាពួកគេមានសិទ្ធិជាពលរដ្ឋកម្ពុជា។ ក្នុងន័យនេះមានសំណើជាច្រើនឲ្យមានការបណ្តុះបណ្តាលច្រើនថែមទៀត។ តាមរយៈការសម្ភាសជាមួយមន្ត្រីនៃក្រសួងអភិវឌ្ឍន៍ជនបទ មានការបង្ហាញថា រដ្ឋាភិបាលស្វាគមន៍ចំពោះការអប់រំថែមទៀតអំពីច្បាប់និងសិទ្ធិដោយសារ «ការយល់ដឹងរបស់អ្នកភូមិអំពីសិទ្ធិរបស់ពួកគេមានសារៈសំខាន់ណាស់»។ ដោយសារការផ្អាកវគ្គបណ្តុះបណ្តាលអំពីសិទ្ធិមនុស្សកើតឡើងជាដំបូងពីថ្នាក់ស្រុក និងថ្នាក់ឃុំដែលមានមន្ត្រីខេត្តកំពង់ធំនៅពីក្រោយខ្នង ចំណាត់ការគួរតែធ្វើឡើងនៅក្នុងកំរិតទាំងនោះជាមួយនឹងការគាំទ្រដោយអាជ្ញាធរថ្នាក់ជាតិ។

១. អង្គការមិនមែនរដ្ឋាភិបាលគួរតែបន្ត និងពង្រីកកិច្ចប្រឹងប្រែងដើម្បីអប់រំសហគមន៍នៅតំបន់ព្រៃឡង់ ចំណែករដ្ឋាភិបាលត្រូវតែផ្តល់ការគាំទ្រយ៉ាងសកម្មដល់ពួកគេនៅក្នុងដំណើរការនេះ ដើម្បីធានាថាអាជ្ញាធរមូលដ្ឋានមិនអាចបញ្ឈប់វគ្គបណ្តុះបណ្តាលដោយចិត្តឯងបានឡើយ។

២. អង្គការមិនមែនរដ្ឋាភិបាល គួរតែបង្កើនកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួនថែមទៀត ដើម្បីឲ្យកាន់តែសមស្របសម្រាប់ចំណេះដឹង របៀបរបបនៃការរៀន និងបរិបទរបស់សហគមន៍ដើម្បីបង្កើនការចងចាំ និងការអនុវត្តអ្វីដែលបានរៀន។

៣. សហគមន៍គួរតែបានទទួលការអប់រំដែលទាក់ទងនឹងផលវិបាកនានា ដែលអាចកើតឡើងពីការ «ផ្តិតមេដៃ» លើឯកសារនានាដែលពួកគេមិនអាចអានបាន។

## ព្រៃការពារ

ក្នុងពេលដែលរដ្ឋបាលព្រៃឈើកំពុងអង្កេតតំបន់ព្រៃឡង់ក្នុងបំណងលើកស្នើជាព្រៃការពារគេមានព័ត៌មានតិចតួចណាស់អំពីផែនការជាក់ស្តែងរបស់ស្ថាប័ននេះ។

១. រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋបាលព្រៃឈើត្រូវធ្វើឲ្យសហគមន៍មូលដ្ឋានបានចូលរួមនៅក្នុងការគ្រប់គ្រងតំបន់ការពារនៅក្នុងព្រៃឡង់។ សហគមន៍ទាំងនេះបានបង្កើនលទ្ធភាពរួចមកហើយ ក្នុងការការពារធនធានធម្មជាតិដ៏មានតម្លៃ ចំណែកសកម្មភាពរបស់រដ្ឋបាលព្រៃឈើក្នុងពេលបច្ចុប្បន្ននេះនៅស្រុកសណ្តាន់ និងកន្លែងដទៃបង្ហាញយ៉ាងច្បាស់ថា គេមានការសង្ឃឹមតិចតួចណាស់ក្នុងការទទួលបានជោគជ័យ តែតាមរយៈស្ថាប័នដែលមានស្រាប់របស់រដ្ឋាភិបាល។

២. គួរតែលុបចោលដីសម្បទានក្រុមហ៊ុនCRCK និងដាំព្រៃឡើងវិញ ដោយសារវាស្ថិតនៅក្នុងតំបន់ព្រៃក្រាស់ មិនមែនព្រៃរេចរឹលដូចមានការតម្រូវនៅក្នុងច្បាប់ឡើយ។ ក្រុមហ៊ុន ធី ង៉ា និងសម្បទានកៅស៊ូ PNT ក៏គួរតែលុបចោលដែរ ហើយតំបន់សម្បទានទាំងនេះគួរតែយ៉ាងហោចណាស់ត្រូវបានដាក់

បញ្ចូលជាផ្នែកមួយនៃតំបន់ទ្រនាប់សម្រាប់ព្រៃការពារនៅតំបន់ព្រៃឡង់ និង ដាំដើមឈើឡើងវិញ។

៣. ក្រុមហ៊ុនសម្បទានទាំងអស់ និងអាជ្ញាបណ្ណ័រុករករ៉ែ ព្រមទាំងគម្រោងទំនប់ ឬហេដ្ឋារចនាសម្ព័ន្ធនានានៅក្នុងតំបន់ព្រៃឡង់ គួរតែត្រូវបានពិនិត្យឡើងវិញ និងគិតអំពីសិទ្ធិ និងតម្រូវការរបស់សហគមន៍នានានៅមូលដ្ឋាន។ ព័ត៌មាននៃការវាយតម្លៃចំពោះប្រព័ន្ធជលសាស្ត្ររបស់ USAID និងទិន្នន័យផ្សេងៗទៀត ដែលគាំទ្រដល់គម្រោងគ្រប់គ្រងប្រកបដោយនិរន្តរភាពរបស់សេវាប្រព័ន្ធអេកូឡូស៊ី ត្រូវតែគិតពិចារណា ដោយសារជម្រាលព្រៃឡង់គួរតែត្រូវបានគេចាត់ទុកជាសារៈសំខាន់ចំពោះប្រយោជន៍ជាតិ។

៤. ការដាំព្រៃឈើ និងស្តារអោយប្រសើរឡើងវិញនៃទីតាំងក្រុមហ៊ុនCRCK និងកន្លែងដែលត្រូវបានបំផ្លិចបំផ្លាញធ្ងន់ធ្ងរផ្សេងៗទៀត គឺជាប្រយោជន៍ដល់ផែនការរបស់រដ្ឋបាលព្រៃឈើសម្រាប់គម្រោងរ៉េដ ហើយការចូលរួមរបស់សហគមន៍ នៅក្នុងដំណើរការនេះនឹងអាចជួយពួកគេក្នុងការស្តារជីវភាពរបស់ពួកគេ។

៥. អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍អ្នកផ្តល់ជំនួយគួរតែអំពាវនាវដល់រដ្ឋាភិបាល ដើម្បីដាក់បញ្ចូលតំបន់ច្រករបៀងរវាងដែនជម្រកសត្វព្រៃបឹងពែរ ទៅក្នុងព្រៃការពារចុងក្រោយនៅតំបន់ព្រៃឡង់។ តំបន់នេះគួរតែរួមបញ្ចូលដីសម្បទានសេដ្ឋកិច្ចនៅសណ្តាន់ និងរវៀង និងផ្តល់កិច្ចការពារបន្ថែមដល់សហគមន៍រងគ្រោះ។ ការធ្វើបែបនេះនឹងធានាផងដែរថាទីជម្រាលស្ទឹងសែននឹងនៅតែអាចរក្សាមុខនាទីតាមធម្មជាតិរបស់វាបាន។

## អាជីវកម្មរ៉ែ

មានភស្តុតាងមិនច្បាស់លាស់មួយចំនួនអំពីកំណើន នៃការព្រួយបារម្ភអំពីការកើនឡើងនៃចំនួនអណ្តូងរ៉ែមាសនៅក្នុងតំបន់ព្រៃឡង់។ ប្រការដែលគួរឲ្យកត់សម្គាល់ គឺសក្តានុពលនៃការបញ្ចេញសារធាតុគីមីពុលខ្លាំងមកក្នុងទឹកសម្រាប់ផឹកនៅសហគមន៍ក្នុងតំបន់ខ្សែទឹកខាងក្រោម ដែលរួមទាំង ទីរួមខេត្តនានា ដូចជាកំពង់ធំ និងកំពង់ចាមជាដើម។

១. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល គួរតែអនុញ្ញាតឲ្យសាធារណជនទទួលបានព័ត៌មានអំពីអាជ្ញាប័ណ្ណអាជីវកម្មរ៉ែ ដែលបានចេញ និងគួរតែប្រកាសជាសាធារណៈអំពីផែនការរបស់ខ្លួន សម្រាប់រាល់គម្រោងអភិវឌ្ឍន៍នៅក្នុងទីតាំងនានានៃតំបន់ព្រៃឡង់។ ក្នុងនេះគួរតែមានការពិភាក្សាពិស្តារជាមួយសហគមន៍អ្នករងគ្រោះមុននឹងអនុញ្ញាតឲ្យមានការអភិវឌ្ឍកើតឡើង។

២. ត្រូវមានការពិនិត្យគុណភាពទឹកឲ្យបានទូលំទូលាយ ពីសំណាក់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីធានាថាគ្មានការអនុញ្ញាតឲ្យសារធាតុគីមីពុលលេចធ្លាយចូលទៅក្នុងប្រភពទឹកក្រោមដីបានឡើយ។

៣. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល គួរតែពន្យល់អំពីអ្វីដែលបានគ្រោងទុកសម្រាប់ទីតាំងខ្លួង នៅភូមិស្រែវាល ក្នុងស្រុកសណ្ដាន់ នៅឆ្នាំ ២០១០ ដូចមានបង្ហាញនៅផ្នែកខាងដើមនៃរបាយការណ៍នេះ។

៤. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលគួរតែស្ថិតក្នុងដំណើរការផែនការសំខាន់ដែលអាចរួមចំណែកអោយមាននិរន្តរភាពនៃការគ្រប់គ្រងទេសភាព។

៥. រដ្ឋបាលជលផល គួរតែធ្វើការពិសោធន៍ជាមូលដ្ឋានសម្រាប់លោហៈធាតុ និងសារធាតុកខ្វក់ផ្សេងៗនៅក្នុងខ្សែរទឹកខាងក្រោម ដើម្បីជួយធានាថាសារធាតុពុលកម្រិតខ្ពស់មិនហូរចូលប្រភពអាហារនៅសហគមន៍។

## សិទ្ធិចំពោះដីធ្លី

ស្ថានភាពនៃសិទ្ធិចំពោះដីធ្លី មិនទំនងជាមានការរីកចម្រើនទៅមុខឡើយនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារគ្មានការចុះបញ្ជីដីសហគមន៍ឡើយរហូតមកដល់ចុងឆ្នាំ ២០១១។

១. រដ្ឋាភិបាលត្រូវគូសបញ្ជាក់អំពីភាពផ្ទុយគ្នានៅក្នុងច្បាប់ភូមិបាល និងច្បាប់ស្ដីពីព្រៃឈើ និងជម្រុញឲ្យដំណើរការនេះឈានទៅមុខ ដែលអនុញ្ញាតឲ្យមានការចុះបញ្ជីដីប្រពៃណីរបស់សហគមន៍។[៨៨]

[៨៨] សូមមើលនៅផ្នែកទាក់ទងនឹងសិទ្ធិជនជាតិដើមភាគតិច និងសិទ្ធិដីធ្លី

២. រដ្ឋាភិបាលត្រូវបំភ្លឺជាបន្ថែមទៀតអំពីសហគមន៍ណាខ្លះដែលអាចចុះបញ្ជីដីធ្លីជាពិសេសបញ្ហាសហគមន៍ដែលត្រូវបានកំណត់ថា «ខ្មែរ» (មិនថាជាតិពិន្ទុពិតប្រាកដរបស់ពួកគេជាអ្វីនោះទេ) ដែលនៅក្រោមគោលការណ៍ណែនាំបច្ចុប្បន្ននេះ មិនមានសិទ្ធិទទួលដីជាសម្ហូហភាព។
៣. សហគមន៍ត្រូវតែប្រឹងប្រែងសុំចុះបញ្ជី ដើម្បីបានទទួលសិទ្ធិដីធ្លីសហគមន៍ បើទោះជាដំណើរការនេះទាមទារពេលវែង និងមានភាពខ្វះចន្លោះច្រើនក៏ដោយ។
៤. អង្គការមិនមែនរដ្ឋាភិបាលត្រូវផ្តល់ជាជំនួយដល់សហគមន៍ ដោយសារសហគមន៍មានការយល់ដឹងតិចតួច អំពីដំណើរការដែលទាក់ទងនឹងការដាក់ពាក្យសុំសិទ្ធិលើដីសម្ហូហភាព។

## សម្បទានដីសេដ្ឋកិច្ចទៅអនាគត

ជាបឋម ពុំគួរមានការផ្តល់ដីសម្បទានសេដ្ឋកិច្ចនៅក្នុងតំបន់ព្រៃឡង់ថែមទៀតឡើយ។ ប៉ុន្តែ ក្រុមហ៊ុនណាមួយដែលគ្រោងអភិវឌ្ឍន៍សម្បទានត្រូវតែបើកឲ្យមានការពិភាក្សាជាចំហជាមួយសហគមន៍ មកពីទីកន្លែងដែលគ្រោងកំណត់ជាដីសម្បទានសេដ្ឋកិច្ចតាំងពីដើមដំបូង និងផ្តល់ជាជម្រើសជំនួសសម្រាប់សហគមន៍ដែលនឹងបាត់បង់ធនធានរបស់ពួកគេ។ ប្រសិនបើដីសម្បទានសេដ្ឋកិច្ចមួយកន្លែងនឹងបង្កអោយមានការទន្ទ្រានមកលើដីធ្លីរបស់ប្រជាជន គេត្រូវផ្តល់សំណងឲ្យបានត្រឹមត្រូវ។ ឧទាហរណ៍អំពីសំណងដែលមិនគ្រប់គ្រាន់ សំណងជាសាច់ប្រាក់ដែលបានផ្តល់ដោយក្រុមហ៊ុនដីសម្បទាននៅខេត្តរតនគិរី គ្រាន់តែនាំមកនូវកំណើនការបាត់បង់ដីធ្លីរបស់ប្រជាជននៅក្នុងសហគមន៍ទាំងនោះតែប៉ុណ្ណោះ។ ដូចគ្នានេះដែរ រាល់ការផ្តល់ដីធ្លីឡើងវិញ ដូចដែលគ្រោងអនុវត្តនៅខេត្តរតនគិរី ត្រូវតែពិចារណាអំពីគុណភាពដី ដោយសារការប្តូរព្រៃដើមដែលសំបូរអនុផលព្រៃឈើជាមួយព្រៃរេចរឹល ឬព្រៃដែលមានគុណភាពទាប ជាប្រការដែលមិនអាចទទួលយកបានឡើយ។

ជម្រើសដែលគួរតែអនុវត្ត រួមមានបណ្តាជម្រើសដែលក្រុមហ៊ុនខ្លះនៅខេត្តរតនគិរីបានប្រើប្រាស់ នៅតាមទីកន្លែងដែលអ្នកភូមិត្រូវបានផ្តល់ឱកាសដើម្បី

អភិវឌ្ឍន៍ «កសិដ្ឋានរួមគ្នា»។ ទោះបីជាជម្រើសបែបនេះឃ្លាតឆ្ងាយពីដំណោះស្រាយដែលល្អឥតខ្ចោះក៏ដោយ តែកសិដ្ឋានទាំងនេះពិតជាផ្តល់សក្តានុពលសម្រាប់គ្រួសារនានាក្នុងការទទួលផលនៅក្នុងរយៈពេលវែង។[៨៩]

## អនុសាសន៍ផ្សេងទៀត

អង្គការមិនមែនរដ្ឋាភិបាល គួរតែធ្វើការស៊ើបអង្កេតជាបន្ថែមទៀតអំពីសកម្មភាពរបស់ក្រុមហ៊ុនសម្បទានសេដ្ឋកិច្ចនៅកន្លែងដទៃទៀត ក្នុងតំបន់ព្រៃឡង់ ជាពិសេសស្ថានភាពនៅក្នុងខេត្តក្រចេះ ដោយសារមានព័ត៌មានយ៉ាងតិចតួចតែប៉ុណ្ណោះអំពីទីកន្លែងនេះ នៅក្នុងពេលបច្ចុប្បន្ន។

រាជរដ្ឋាភិបាលត្រូវតែពន្យល់អំពីដំណើរការបច្ចុប្បន្ន សម្រាប់ជនចំណាកស្រុក ជាពិសេសនៅក្នុងស្រុកថាឡាបរិវ៉ាត់ នៃខេត្តស្ទឹងត្រែងដែលទំនងជាមានកិច្ចប្រឹងប្រែងរួមគ្នា ក្នុងការដាក់តាំងជាទីលំនៅសម្រាប់ប្រជាជនដែលគ្មានដីធ្លីមកពីខេត្តដទៃ។

**អនុសាសន៍ទាំងអស់ត្រូវមានកិច្ចប្រឹងប្រែងរួមគ្នាពីគ្រប់ភាគីទាំងអស់ ដែលរួមទាំងរាជរដ្ឋាភិបាលកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ ក្នុងការបញ្ឈប់សកម្មភាពកាប់ឈើល្មើសច្បាប់បែបអនាធិបតេយ្យដែលកំពុងកើតមាននៅទូទាំងតំបន់ព្រៃឡង់។**

**<u>ភាពចាំបាច់បន្ទាន់នៃបញ្ហាទាំងនេះ មិនអាចគូសបញ្ជាក់ឲ្យបានខ្លាំងគ្រប់គ្រាន់ឡើយ។</u>**

---

[៨៩] របាយការណ៍របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា «ដីសម្បទានសេដ្ឋកិច្ច និងសហគមន៍មូលដ្ឋាន» ខែសីហា ឆ្នាំ២០១១

# ឯកសារយោង


**Losing Ground – Forced Evictions and Intimidation in Cambodia:** *September 2009 NGO Forum/Cambodian Human Rights Action Committee.*

**Still Losing Ground – Forced Evictions and Intimidation in Cambodia:** *2010 NGO Forum/Cambodian Human Rights Action Committee.*

**Rights of Indigenous Peoples in Cambodia:** *February 2010, NGO Forum, Indigenous People NGO Network, Asian Indigenous Peoples Pact, Cambodian Human Rights Action Committee, Human Rights Task Force.*

**Land Grabbing & Poverty in Cambodia: The Myth of Development:** *May 2009, Licadho,*

**Economic Land Concessions and Local Communities:** *August 2011, NGO Forum.*

**REDD + in the Prey lang Area - A feasibility study:** *March 2011, Stavros Papageorgiou, Jenny Hewson, David Emmett, Marc Steininger. Conservation International.*

**A Floral and Faunal Biodiversity Assessment of Prey Lang:** *November 2007, Annette Olsson & David Emmett, Conservation International, Forest & Landscape, University of Copenhagen, Forestry Administration.*

**USAid Rapid Socio-Economic And Hydrological Assessment of Prey Lang Forest:** *April 29th 2011, Advanced Engineering Consultants Ltd.*

**Human-Wildlife Conflict in and Around Seima Biodiversity Area, Mondulkiri and Kratie Provinces, Cambodia:** *2007, Kara Scally, Tom Evans and Nut Meng Hor.*

**REDD+ and Conservation of Prey Lang Forest Cambodia – Summary of Scientific Findings, 2007-2010:** *Ida Theilade, Lars Schmidt.*

**Cambodia's Family Trees - Illegal logging and the stripping of public assets by Cambodia's elite:** *June 2007, Global Witness.*

**National Level Network on Extractive Industry Social and Environmental Impacts – Baseline soil and water quality testing Preah Vihear and Stung Treng Provinces Completion Report:** *December 2010, Resource Development International Cambodia.*

**Country for Sale – Welcome to Cambodia**: *February 2009, Global Witness.*

**Productive Strategies for Poor Rural Households to Participate Successfully in Global Economic Processes – Regional Scan: Mekong Delta and the Philippines:** *June 2006, Priya Deshingkar, IRDC/RPE.*

**Global Forest Resources Assessment 2010 Country Report Cambodia:** *Forestry Department Food and Agriculture Organization of the United Nations.*

**United Nations Annual Report 2010, Cambodia - Empowered lives Resilient Nations:** *United Nations.*

**Eviction and Resistance in Cambodia - Five women tell their stories:** *2011, Amnesty International.*

**Land Governance For Equitable and Sustainable Development Land Acquisition By Non-Local Actors and Consequences for Local Development - Impacts of Economic Land Concessions on the Livelihoods of Indigenous Communities in Northeast Provinces of Cambodia:** *March 2011, Men Prachvuthy, Royal University of Phnom Penh, Department of Tourism, Mekong Institute of Cambodia, LandAc Netherlands Academy of Land Governance for Equitable and Sustainable Development Utrecht.*

**Indigenous and tribal peoples' perceptions of poverty and poverty reduction strategies in Cambodia:** *2005, Kristina Chhim, Center for Advanced Study, Phnom Penh, International Labour Organization.*

**National Forest Programme 2010-2029 and associated "Background Document":** *Forestry Administration, Ministry of Agriculture Forests and Fisheries, Royal Government of Cambodia.*

**National Policy on The Development of Indigenous Peoples:** *April 24th 2009, Ministry of Rural Development, Royal Government of Cambodia.*

**Sub-Decree of Registration of Lands of Indigenous Communities:** *June 9th 2009, Council for Land Policy, Royal Government of Cambodia.*

**Sub-decree on Procedures for Registration of Indigenous Communities:** *Royal Government of Cambodia.*

**Sub Decree on Economic Land Concessions:** *16th December 2005, Royal Government of Cambodia.*

**Sub-Decree on Community Forestry Management:** *17th October 2003, Royal Government of Cambodia.*

**Sub-Decree On Rules and Procedures on Reclassification of State Public Properties and Public Entities:** *July 28th 2006, Royal Government of Cambodia.*

**Prakas on Guideline for Conducting Environmental Impact Assessment Report:** *March 2009, Royal Government of Cambodia.*

**Anukret on Environmental Impact Assessment:** *August 2009, Royal Government of Cambodia.*

**Law on Land:** *February 2002, Ministry of Land Management, Urban Planning and Construction, Royal Government of Cambodia.*

**Law on Forestry:** *July 30th 2002, Royal Government of Cambodia.*

**Achieving Cambodia's Millennium Development Goals – Update 2010:** *Ministry of Planning, Royal Government of Cambodia.*

## វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

អាសយដ្ឋាន: ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១ ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រ ២២៩៥ ភ្នំពេញ-៣
ទូរស័ព្ទលេខ: (៨៥៥-២៣) ២១៤ ៤២៩
ទូរសារលេខ: (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីមែល: **ngoforum@ngoforum.org.kh**
គេហទំព័រ: **www.ngoforum.org.kh**